

# ពន្លឺ

# ធម្មទេសនា

រៀបរៀងដោយ

ជយានន្ទោ ជួន ចិន្តា

ចន្ទត្ថេរោ រួន សារ៉ុន

ព.ស.២៥៥០ គ.ស.២០០៦

ទទួលបានពីលោក ចៅ ឃុនសំរឹម ផលក្រុណាខ្មែរ
ដើម្បីដាក់ចូលក្នុង elibrary of Cambodia.
កញ្ញា 2015.



# ពន្លឺធម្មទេសនា

រៀបរៀងដោយ

ជយានន្ទោ ជួន ចិន្តា

ចន្ទត្ថេរោ រួន សារ៉ុន

បោះពុម្ពលើកទី ១

ព.ស.២៥៥០ គ.ស.២០០៦

## រាយនាមអ្នកត្រួតពិនិត្យ និង កែសម្រួល :

-ព្រះគ្រូសិរីសុវណ្ណាអនុគណស្រុកថ្មគោល

ព្រហ្មាភិរក្ខិតោ **ហេង សុខន**

-ព្រះគ្រូវិន័យធរស្រុកថ្មគោល ខន្តិបេ្យមោ **ឃុត អង**

-ភិក្ខុ **ចន ជឿន** លេខាអនុគណស្រុកថ្មគោល

-ភិក្ខុ **គង គុសល** សមណៈសិស្សពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង

-ភិក្ខុ **ជឿស ចាយ** សមណៈសិស្សពុទ្ធិកវិទ្យាល័យ អ៊ឹង ធួង

## ដកស្រង់ចេញអំពីគម្ពីរ :

-ព្រះត្រៃបិដក

-អដ្ឋកថា

-មង្គលត្ថទីបនី

-ធម្មបទ

-ប្រជុំនិទានជាតក

# មាតិកា

| អត្ថបទ | ទំព័រ |
|---|---|
| ១-បុណ្យកតញ្ញូកតវេទី | ១ |
| ២-នាមរបស់មាតាបិតា ៤ យ៉ាង | ៣ |
| ៣-សង្គហធម៌របស់មាតាបិតា ៥ យ៉ាង | ១២ |
| ៤-សង្គហធម៌របស់បុត្រធីតា ៥ យ៉ាង | ១៥ |
| ៥-រឿងស្តេចជីវី | ២១ |
| ៦-រឿងមិត្តវិន្ទុក | ២៤ |
| ៧-បុណ្យទក្ខិណានុប្បទាន | ២៩ |
| ៨-ទក្ខិណានុប្បទានប្រកបដោយអង្គ ៣ យ៉ាង | ៣៤ |
| ៩-រឿងវេលាមព្រាហ្មណ៍ | ៣៩ |
| ១០-រឿងជាណុស្សោណិព្រាហ្មណ៍ | ៤៤ |
| ១១-រឿងភិក្ខុជាញាតិនឹងប្រេត | ៥០ |
| ១២-បុណ្យឆ្លោង | ៥៣ |
| ១៣-កំណើត ៤ យ៉ាង | ៥៥ |
| ១៤-ជាតិទុក្ខមាន ១០ យ៉ាង | ៦១ |
| ១៥-រូបមាន ២ យ៉ាង | ៧២ |

១៦-បុណ្យកឋិនទាន ៨៣

១៧-រឿងភិក្ខុ ៣០ រូប ៨៥

១៨-កឋិនទានប្លែកអំពីចីវរទានដោយហេតុ ៥ យ៉ាង ៨៨

១៩-បុណ្យចូលព្រះវស្សា ៩២

២០-វស្សូបនាយិកា ការចូលវស្សា ២ យ៉ាង ៩៤

២១-រឿងនាងឧម្មាទន្តី ៩៦

២២-កំណើតនៃសំពត់សាដក ៩៩

# អារម្ភកថា

សៀវភៅ ពន្លឺធម្មទេសនា នេះ ខ្ញុំព្រះករុណា អាត្មាភាពទាំងពីរអង្គបានរៀបរៀងជាលើកដំបូងបង្អស់ ដោយយល់ឃើញថា ព្រះពុទ្ធសាសនារបស់យើងមានការខ្វះខាតសៀវភៅក្បួនច្បាប់ជាច្រើន មិនសូវសំបូរដល់ការសិក្សារៀនសូត្ររបស់ធម្មកថិកអ្នកបួសថ្មី ដែលមានសេចក្តីលំបាកក្នុងការស្វែងរកគម្ពីរធម៌មកបញ្ចេញបញ្ចូល តម្រូវតាមកម្មវិធីបុណ្យពុទ្ធបរិស័ទ ហេតុដូច្នេះហើយបានជាខ្ញុំព្រះករុណា អាត្មាភាពទាំងពីរអង្គ បានដកស្រង់ក្បួនច្បាប់ចេញអំពីគម្ពីរធំតូច ដើម្បីអោយងាយស្រួលដល់ធម្មកថិកថ្មី ដែលសំដែងធម៌ទេសនាប្រោសពុទ្ធបរិស័ទ អោយដើរតាមគន្លងធម៌របស់ព្រះដ៏មានបុណ្យដើម្បីអោយយល់នូវគុណប្រយោជន៍ និងតម្លៃនៃព្រះពុទ្ធសាសនា ដែលបានផ្សាយទូទៅពេញសកលលោក ។

ម្យ៉ាងទៀតដើម្បីអោយលោកអ្នកអានយល់ដឹងអំពីបុណ្យខ្លះៗ ដែលជាប់ទាក់ទងនឹងព្រះពុទ្ធសាសនា អាស្រ័យហេតុនេះ បើសិនជាខ្ញុំព្រះករុណា អាត្មាភាពរៀបរៀងមានការខុសឆ្គាំឆ្គងដោយអចេតនាប្រការណាមួយ សូមព្រះធម្មកថិក និងពុទ្ធបរិស័ទ លោកអ្នកអានមេត្តាជួយកែតម្រូវដោយកុសលចេតនាផងចុះ ។

កុសលជាធម្មទានដ៏ប្រសើរនេះ សូមលើកឧទ្ទិស្សថ្វាយជូនចំពោះសម្តេច

ព្រះមហាសុមេធាធិបតី ជោតញ្ញាណោ ជួន ណាត ដែលបានសាងនូវគុណប្រយោជន៍ដ៏ច្រើនបំផុតក្នុងព្រះពុទ្ធសាសនា ព្រមទាំងសាងនូវប្រយោជន៍ជាសាធារណៈសំរាប់សង្គមខ្មែរ ព្រះអង្គគឺជាបិតាអក្សរសាស្ត្រ ធ្វើអោយព្រះសង្ឃ ពុទ្ធបរិស័ទ សោកស្តាយព្រះអង្គពន់ពេក មួយទៀតសូមជូនចំពោះលោកអ្នកជួយឧបត្ថម្ភគាំទ្រ និងលោកអ្នកអានអោយបានទទួលនូវមហាកុសលគ្រប់ៗគ្នា ។

# បុណ្យកតញ្ញូកតវេទី

ចត្តារោ ធម្មា ធម៌គឺពរទាំងឡាយ ៤ ប្រការគឺ :

១.អាយុ សូមអោយមានអាយុវែងមួយ

២.វណ្ណ សូមអោយមានពណ៌សម្បុរកាយល្អមួយ

៣.សុខ សូមអោយបានសុខកាយសប្បាយចិត្តមួយ

៤.ពល សូមអោយមានកម្លាំងកាយ,កម្លាំងសទ្ធាមួយ

ពុទ្ធពរទាំងឡាយ ៤ ប្រការនេះ វឌ្ឍន្តុ ចូរចំរុងចំរើនកើតមានដល់ បណ្តារស់លោកជាពុទ្ធបរិស័ទទាំងឡាយ ដែលជាម្ចាស់ដើមទានប្រធានដើមបុណ្យ ដែលមានចិត្តជ្រះថ្លាលើកនឹកឃើញនូវគុណូបការៈនៃមាតាបិតា បាន ប្រារព្ធធ្វើនូវ "បុណ្យកតញ្ញូកតវេទី" ឡើង ហើយបានអារាធនានិមន្តព្រះករុណាអាត្មាភាព ឱ្យជាអ្នកសំដែងនូវព្រះធម៌ទេសនា អាត្មាភាពក៏ព្រមទទួលភារកិច្ចជាអ្នកសំដែង ប៉ុន្តែបើសិនជាអាត្មាភាពសំដែងទៅហើយ មានការហើសហួសខ្វះខាតដោយបទពាក្យ អក្ខរៈ ព្យញ្ជនៈ ភាសាបាលី ត្រង់សេចក្តីណាមួយ សូមញាតិញោមជាពុទ្ធបរិស័ទ ខន្តីអភ័យទោសនូវសាធុទោសទាំងឡាយដល់អាត្មាភាពផង គ្រាន់នឹងបានលើកឡើងនូវព្រះធម៌មកសំដែង តាមបញ្ញាចេះចាំតិចតួចស្តួចស្តើង សូមចំរើនពរ និងជូនពរ ។

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

(សូត្រ ៣ ចប់)

ខ្ញុំព្រះករុណា សូមលំអុតលំឱនកាយវាចាចិត្ត ក្រាបថ្វាយបង្គំ ធមស្ការ ចំពោះគុណព្រះរតនៈត្រ័យទាំង ៣ មាន ពុទ្ធរតនៈ ធម្មរតនៈ សង្ឃរតនៈ ដោយសេចក្ដីគោរព ។

**កតញ្ញុំ ធម្មំ ទេសេស្សាមិ** បន្ទាប់អំពីបទធមស្ការ ដោយសង្ខេបបែបខ្លីនេះទៅ អាត្មាភាពសូមលើកយកនូវបុណ្យកតញ្ញូកតវេទី មកសំដែងរំលែកញែកប្តូចតទៅនេះ :

ពាក្យថា "**កតញ្ញូកតវេទី**" ចែកចេញជា ២ បទ គឺ "**កតញ្ញូ**" ១ បទ និង "**កតវេទី**" ១ បទ ។

**កតញ្ញូ** ប្រែថា អ្នកដឹងនូវឧបការៈគុណ, **កតវេទី** ប្រែថា អ្នកធ្វើតប, រួមទាំងពីរបទនេះមកបានជា **កតញ្ញូកតវេទី** ប្រែថា អ្នកដឹងនូវឧបការៈគុណ ហើយធ្វើតបវិញ ។

ធម្មតាទេ បុគ្គលដែលកើតមកក្នុងលោកនេះ ទោះបុរសក្ដី ស្ត្រីក្ដី គ្រហស្ថក្ដី បព្វជិតក្ដី ដែលបានទទួលនូវផលប្រយោជន៍ និងសេចក្ដីសុខសេចក្ដីចំរើននោះ ដោយសារមានអ្នកដទៃបានជួយទំនុកបំរុងជ្រោមជ្រែងឧបត្ថម្ភដល់ខ្លួនអោយបានសំរេចនូវប្រយោជន៍ណាមួយ ហើយជនទាំងអស់នោះ

ឈ្មោះថាជាមានឧបការៈគុណដល់ខ្លួនយើង ដូច្នេះហើយយើងមិនត្រូវបំភ្លេចចោលនូវគុណបំណាច់ ពីសេចក្ដីល្អដែលគេបានធ្វើមកលើខ្លួននោះឡើយ គឺយើងត្រូវមានស្មារតីភ្ញាក់រលឹកនឹកឃើញជានិច្ចថា អាត្មាអញគង់មានថ្ងៃខែឆ្នាំណាមួយធ្វើតបវិញមិនខាន ផ្ទុយទៅវិញបុគ្គលគ្រាន់តែដឹងថាអ្នកនេះមានគុណ អ្នកនោះមានគុណ ហើយមិនបានធ្វើតប ក៏មិនបានឈ្មោះថាកតវេទីបុគ្គលដែរ ។ ម្យ៉ាងទៀត មាតាបិតាដែលបានចិញ្ចឹមបីបាច់ថែរក្សាទំនុកបំរុងកូនចៅក្នុងត្រកូលពីតាឈ្មោះថា ជាបុព្វការីជនរបស់កូន ពីព្រោះលោកទាំងពីរនាក់បានធ្វើនូវឧបការគុណមុន ដូច្នេះហើយបានជាបណ្ឌិតទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ទ្រង់ត្រាស់សំដែងទុកនៅក្នុងសុត្តន្តបិដកអង្គុត្តរនិកាយ ចតុក្កនិបាត ទុតិយបណ្ណាសក បត្តកម្មវគ្គ ភាគ ៤២ ទំព័រ ១៧៣ ថា:

## នាមរបស់មាតាបិតា ៤ យ៉ាង គឺ :

ម្នាលភិក្ខុទាំងឡាយ មាតាបិតាទាំងឡាយ ដែលពពួកបុត្រណាបូជាហើយក្នុងផ្ទះ ត្រកូលទាំងនោះឈ្មោះថា ប្រកបដោយព្រហ្មៈជាព្រហ្មផងជាបុព្វាចារ្យផង ជាបុព្វទេពផង ជាអាហុនេយ្យបុគ្គលផង ។

ម្នាលភិក្ខុទាំងឡាយពាក្យថា ព្រហ្មនុ៎ះ បុព្វាចារ្យនុ៎ះ បុព្វទេពនុ៎ះ អាហុនេយ្យបុគ្គលនុ៎ះ ជាឈ្មោះរបស់មាតាបិតាទាំងឡាយ ។

## មាតាបិតាជាព្រហ្មរបស់បុត្រធីតា

បានជាព្រះដ៏មានព្រះភាគទ្រង់ឱ្យនាមមាតាបិតាជាព្រះព្រហ្មនោះ

ពីព្រោះលោកទាំងពីរនាក់មាននូវព្រហ្មវិហារធម៌ ៤ ចំពោះកូនប្រុសស្រីផង :

**១.មេត្តា** សេចក្តីស្រឡាញ់ស្និទ្ធស្នាលរាប់អានចំពោះកូន ។ "មេត្តាចិត្តនេះមានសត្វជាអារម្មណ៍" ព្រោះលោកទាំងពីរនាក់ កាលដែលបានផ្សាជាភរិយាស្វាមីហើយ គាត់មានសេចក្តីប្រាថ្នាម្យ៉ាង គឺចង់បានបុត្រ ដើម្បីបន្តពូជពង្សវង្សត្រកូលរបស់ខ្លួន ។ មាតាបិតាទាំងឡាយ កាលបើដឹងថាមានសត្វចុះចាប់បដិសន្ធិនៅក្នុងផ្ទៃពោះនៃមាតាហើយ បិតាដែលជាស្វាមីតែងតែស្វែងរកនូវទ្រព្យសម្បត្តិ និងថ្នាំសង្កូវព្រមទាំងចំណីអាហារ ដើម្បីយកមកផ្គត់ផ្គង់ភរិយារបស់ខ្លួន និងមិនឱ្យធ្វើការងារណាធ្ងន់ហើយ និងលំបាកផងដែលជាហេតុនាំឱ្យប៉ះពាល់ដល់ទារកនៅក្នុងផ្ទៃ ហេតុនេះហើយបានជាឪពុកស៊ូទ្រាំនឿយហត់គ្រប់បែបយ៉ាង ទោះពេលយប់ ឬ ពេលថ្ងៃ ក្តៅរងា ជិតឆ្ងាយយ៉ាងណានោះទេ តែងតែខំប្រឹងប្រែងជានិច្ច អោយតែភរិយា និងបុត្ររបស់ខ្លួនបាននូវសេចក្តីសុខ ជួនកាលការងារខ្លះ ជាការងាររបស់ស្ត្រីដែលឪពុកមិនដែលធ្លាប់ធ្វើ តែឪពុកខំព្យាយាមធ្វើឱ្យទាល់តែបាន ។ រីឯមាតាវិញគាត់តែងតែថ្នាក់ថ្នមថែរក្សាសុខភាព អោយបានល្អសូម្បីតែការបរិភោគអាហារក្តី ធ្វើការងារផ្សេងៗក្តី គាត់តែងតែប្រុងប្រយ័ត្នដើម្បីកុំឱ្យប៉ះទង្គិចដល់ទារកនៅក្នុងផ្ទៃ ព្រោះទឹកចិត្តគាត់មានការស្រឡាញ់បុត្រស្មើនឹងជីវិតរបស់ខ្លួន ។

**២.ករុណា** សេចក្តីអាណិតអាសូរ ។

“មានរូបសំលេងជាអារម្មណ៍” មាតាបិតាទាំងឡាយ តែងមានចិត្តអាណិតអាសូរដល់ទារកដ៏តូចរបស់គាត់ ដែលទើបប្រសូត្រចេញអំពីឧទរ គាត់តែងតែថែរក្សាថ្នាក់ថ្នមកូនដោយសេចក្តីប្រុងប្រយ័ត្ន សូម្បីតែស្រមោចសង្ហាក៏គាត់មិនឱ្យបៀតបៀនលើរូបកូនគាត់បានឡើយ ។ ម្យ៉ាងវិញទៀត មាតាបិតាតែងមានទឹកចិត្តអាណិតកូនជាខ្លាំងដែលជាទារកទើបនឹងធ្លាក់ ពុំដែលបានប៉ះពាល់ស្គាល់រសជាតិធាតុអាកាសខាងក្រៅ ហើយក៏មិនអាចអត់ទ្រាំបាន ក៏ស្រែកទ្រហោយំក្នុងខណៈពេលនោះឯង ធ្វើឱ្យហឫទ័យរបស់មាតាបិតាក្តុកក្តួលស្រណោះស្រណោកពន់ពេក រកអ្វីប្រៀបផ្ទឹមពុំបានឡើយ ក៏ម្នីម្នាប្រវប្រវារកក្រណាត់ដ៏ល្អល្អះមកបណ្ដប់ ព្រមទាំងអោបក្រសោបកូនដាក់លើដើមទ្រូងរបស់ខ្លួន ។

## កំណាព្យ អាសូរចិត្តអាណិតម៉ែ

គួរអាសូរចិត្តអាណិតម៉ែ អស់ ៩ ខែម៉ែពរផ្ទៃ
ស៊ូទ្រាំចាញ់គភ៌ញ៉ាំរល្ហិតល្ហៃ អាស្រ័យបុត្រាផ្ញើជីវិត ។
ម្លឹងហើយម៉ែនៅនឹកស្រឡាញ់ លំបាកម្ដេចមេញ្ញឥតបើគិត
ទន្ទឹងឱ្យតែខែមកជិត ចិត្តពិតចង់ឃើញបុត្រពិសី ។
ពេលឆ្លងទន្លេម៉ែឈឺណាស់ ឈឺរឿយៗឈឺក្រាស់ហួសឧបមេយ្យ
ស្ទើផុតជីវិតចាកលោកីយ៍ វិស័យមច្ចុរាជមករងចាំ ។
ពេលឆ្លងទន្លេផុតវាលធំ ម៉ែស្ដាប់កូនយំម៉ែចំណាំ

សំលេងកូនតូចដូចបណ្តាំ ផ្សះផ្សាំទ្រូងម៉ែឱ្យល្ហែពិត ។
ម៉ែចិញ្ចឹមកូនម៉ែថ្នាក់ថ្នម បំពេបីបមថ្នមប្រណិត
ឆ្លងកាត់ពំណាក់នៃលោហិត ផ្តិតដោយឱរ៉ាបីថ្នាស្អាត ។

## ពាក្យ មេ ទាំងអស់ប្រដូចនឹងម៉ែ

ភ្នំព្រះសុមេរុគឺជាមេភ្នំ ធំក្រៃលែងធំទ្រត្រើយប្រាន
តែចង់នៅតូចជាងម៉ែកល្យាណ ព្រោះម៉ែទ្រហានព្រះព្រហ្មមុខបួន។
ម៉ែពិតជាធំនៅក្នុងលោកា មេទ័ពខ្លាំងក្លាសំពះម៉ែខ្លួន
ទោះស្តេចចក្រពត្តិគ្រងទ្វីបទាំងបួន អំណាចមាំមួនតែនៅខ្លាចម៉ែ ។
ពាក្យមេក្នុងលោកមានច្រើនពេកក្រៃ មេជើងមេដៃមេស្រុកមេស្រែ
ពាក្យមេទាំងនោះប្រដូចនឹងម៉ែ ពាក្យមេហ្វូងហែគឺម៉ែទាំងអស់។
ព្រោះម៉ែជាធំម៉ែអ្នកបង្កើត ម៉ែឱ្យកំណើតម៉ែឱ្យបៅដោះ
ម៉ែបង្ហាត់កូនម៉ែមានចិត្តស្មោះ ម៉ែគឺជាកោះនៃជីវិតកូន ។

## ព្រះគុណម៉ែ

គុណម៉ែតាំងតែគភ៌ចាប់ផ្តើម ទ្រាំពរពោះផើមទ្រាំលំបាក
ដើរដេកដូចរោគតាមឥតស្រាក ទម្រាំកូនចាកចេញពីផ្ទៃ ។
ពេលឆ្លងទន្លេម៉ែឈឺខ្លាំង ចិត្តតាំងកាយប្រឹងព្រមដោយភ័យ
មិនដឹងយ៉ាងណាចិត្តមមៃ នឹកភ័យក្រែងកូនសូន្យសង្ខារ ។
លុះកូនបានកើតជាទារក ម៉ែទើបជញ្ជក់សព្វកាយា

បីបមផ្ទាក់ថ្នមពេញហត្ថា　មេត្តាប្រៃឈាមជាទឹកដោះ ។
នៅពេលកូនឈឺម៉ែរក្សា　បីផ្ទប់ឱរ៉ាដោយចិត្តស្មោះ
កូនឈឺម៉ែភ័យមុខស្លាំងអស់　មិនសម្រាន្តសោះវាស់ៗព្រឹក ។
នៅពេលកូនជាម៉ែសប្បាយ　ចិត្តម៉ែមិនណាយមានតែនឹក
ឃ្លាតឆ្ងាយបន្តិចចិត្តវរឹក　រលឹករកកូនវិលវិញភ្លាម ។
អង្គុយកកិលក្រោកឈរដើរ　ទៅតាមដំណើរម៉ែព្យាយាម
ខំបង្ហាត់កូនដោយមិនទាម　ក្នុងនាមជាគ្រូឧត្តមប្រៃ ។
ជុះនោមហូបចុកស្លៀកដណ្តប់　ចំណេះចេះសព្វប្រចាំថ្ងៃ
សម្តីភាសាមារយាទថ្លៃ　កូនកុំសង្ស័យព្រែងឥតគ្រូ ។
កូនចេះមួយមុខម៉ែអរម្តង　អួតប្រាប់អ្នកផងមិនចាំសួរ
ម៉ែឡើយយ៉ាងណាមិនគិតគួរ　បន្ទូរកង្វល់ដោយផ្ទាល់កូន ។
កូនធំបន្តិចបែបរាងរឹង　កូនខ្លះទទឹងអាងជីដូន
ម៉ែខឹងអន់ចិត្តមុខស្រពោន　វាយកូនរួចគិតអាណិតក្រោយ។
កូនល្អម៉ែសុខព្រែកត្អូង　បានដូចម៉ែផ្សងសូមអំណោយ
ដូចបានកែវមិព្វទេវតាឱ្យ　ឬដូចបានសោយសុខសួគ៌ា ។
ពេលកូនបានសុខម៉ែសុខផង　ពេលកូនមានហ្មងម៉ែពុំជា
កូនក្រលំបាកម៉ែរងា　គ្រប់គ្រាម៉ែគិតកូនប្រុសស្រី ។
កូនខូចអាក្រក់ក្នុងភូមិឃុំ　គេជុំគេស្អប់សព្វសាយសុស

ម៉ែអឺងព្រាកបថាកូនខុស តែម៉ែសន្តោសព្រោសប្រណី ។
ម៉ែគឺជាព្រះរបស់កូន ជាក្បូនជីវិតមនុស្សប្រុសស្រី
ម៉ែមានគុណធ្ងន់ហួសពោលស្តី គ្មានអ្វីជំនួសម៉ែបានឡើយ ។

## ពាក្យថាៈម៉ែ

ពាក្យម៉ែមានន័យសំខាន់ខ្លាំងណាស់ ប្រជុំគុណក្រាស់ក្រៃជាងធរណី
ពាក្យម៉ែពិរោះគ្រប់ឃើប្រើថពី ល្អដូចសិរីពេញលោយរុក្ខា ។
ព្រៃធំមានសត្វជាគ្រឿងលំអ ភរិយាបវរលំអរភស្តា
ទីបលោកល្អស្រស់ក៏ព្រោះសុរិយា សត្វក្នុងលោកាល្អព្រោះមានម៉ែ។

**៣.មុទិតា** សេចក្តីទោទន់ទៅរកកូន "មានមិត្តជាអារម្មណ៍" មាតាបិតា នៅពេលដែលឃើញកូនចេះក្រឡាប់ ចេះដើរ ចេះរត់ទៅមក ព្រមទាំងចេះស្រដីចរចារជាដើម ធ្វើឱ្យមាតាបិតាសប្បាយរីករាយញញឹម ព្រោយទោរទន់ទៅរកកូន ភ្លេចអស់ទុក្ខសោក នឿយហត់គ្រប់បែបយ៉ាង ។

**៤.ឧបេក្ខា** សេចក្តីតាំងចិត្តជាកណ្តាលមិនឱ្យមានសោមនស្ស និងទោមនស្ស "មានកម្មជាអារម្មណ៍" កាលណាបើកូនមានវ័យសមល្មម និងរោងគូស្រករហើយ មាតាបិតាតែងតែផ្សំផ្គុំអោយមានភរិយាស្វាមី និង ចែកចាយទ្រព្យសម្បត្តិឱ្យកូនតាមកម្លាំងសមត្ថភាព ដើម្បីជាដើមទុនក្នុងការ ប្រកបមុខរបរចិញ្ចឹមជីវិត ។

ដោយឡែកនៅក្នុងលោកយើងនេះ ក៏មានម្ដាយឪពុកមួយចំនួន ដែលជាអ្នកទីទាល់ក្រ មិនមានលទ្ធភាព និងគ្មានទ្រព្យសម្បត្តិដើម្បីចែកឱ្យកូនបានឡើយ អាស្រ័យហេតុនេះហើយ បុត្រធីតាទាំងឡាយមិនត្រូវអាក់អន់ស្រពន់ចិត្តប្រកាន់ខឹងនឹងមាតាបិតាទេ ព្រោះគ្មានមាតាបិតាណាមួយស្អប់ខ្ពើមកូនឡើយ គាត់តែងតែសញ្ជឹងរិះគិតរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីអនាគតកូនៗ ពោលគឺគាត់តែងតែប្រាថ្នាចង់ឱ្យកូនបានសេចក្ដីសុខចំរើន មានកិត្តិយសថ្កុំថ្កើងមានទ្រព្យសម្បត្តិ ស្ថិតស្ថេរនៅក្នុងសង្គម ប៉ុន្តែប្រសិនបើគាត់ជួយកូនពុំបាននោះទេ គាត់ទាំងពីរនាក់ក៏មានការឈឺចាប់ មានការតូចចិត្តស្អិតទ្រូង លំបាកចិត្តស្ទើរតែឆ្កួតលីលា ព្រោះអាណិតអាសូរដល់កូនគាត់ជាពន្លឹក មានពេលខ្លះគាត់គិតអ្វីក៏ចេញ គាត់គិតតែការលើកដល់ផលកម្មរបស់សត្វ ហើយក៏ដាំងចិត្តជាកណ្ដាលៗ ទោះសុខក្ដីទុក្ខក្ដីមានកម្មជាបច្ច័យ ។ ដូចបានពោលទុកមកខាងដើមនេះ គឺថាមាតាបិតាជាព្រះព្រហ្មរបស់បុត្រធីតា ។

## មាតាបិតាជាបុព្វាចារ្យរបស់បុត្រធីតា

បានជាលោកពោលថា មាតាបិតាជាបុព្វាចារ្យ ពីព្រោះលោកទាំងពីរនាក់គឺជាគ្រូអាចារ្យដំបូង ដែលបានបង្ហាត់បង្រៀននូវបឋមវិជ្ជាដែលជាមូលដ្ឋានរបស់មនុស្ស និងសង្គម ដូចជាការបង្ហាត់ឱ្យកូនចេះអង្គុយ ចេះឈរ ចេះដើរ និងចេះហូបចុកជាដើម ពុំនោះសោតបង្ហាត់កូនឱ្យចេះនិយាយស្ដីហៅថា មីង មា ពូ អ៊ុំ យាយតាទៀតផង ។ ដល់ពេលដែលបុត្រធីតា

មានអាយុ ៧ឆ្នាំ ឬ ៨ឆ្នាំ ទើបមាតាបិតាបញ្ជូនឱ្យកូនទៅសិក្សាចំណេះវិជ្ជាទាំងផ្លូវលោក និងផ្លូវធម៌អំពីសំណាក់គ្រូអាចារ្យខាងក្រៅ មានការសិក្សាអំពីអក្សរសាស្ត្រ លេខគណិត តាមសង្គមមនុស្សដែលពេញនិយម ដូច្នេះហើយសឱ្យឃើញថា មាតាបិតាជាបុព្វាចារ្យ គឺជាគ្រូអាចារ្យខាងដើមរបស់បុត្រធីតា ។

## មាតាបិតាជាបុព្វទេពរបស់បុត្រធីតា

បានជាលោកពោលថា មាតាបិតាជាបុព្វទេពនោះ គឺជាទេវតាខាងដើមរបស់ប្រុសស្រី ព្រោះលោកទាំងពីរនាក់បានបីបាច់ថែរក្សាកូនចាប់តាំងពីក្នុងផ្ទៃរហូតដល់ប្រសូត្រ លុះប្រសូត្រចេញមកម្ដាយតែងថែរក្សា ដោយការបំពៅបោះ និងបញ្ចុកនំចំណី បាយទឹកដល់កូនព្រមទាំងភ្លូតទឹកឱ្យកូន សូម្បីតែកូនបន្ទោបង់នូវទឹកមូត្រលាមក ដាក់មកលើខ្លួនគាត់ក៏ដោយ មាតាបិតាមិនមានការខ្ពើមរអើមឡើយ ឬក៏មានបុគ្គលណាមួយមកធ្វើបាបកូនរបស់ខ្លួនគាត់តែងតែការពារជានិច្ច មិនអោយគេជេរប្រទេចកូនបានឡើយ ពុំនោះសោតគាត់ការពារមិនឱ្យគេវាយដំកូនថែមទៀតផង ។ ម្យ៉ាងទៀតបុត្រធីតាទាំងឡាយ បានស្គាល់នូវទេវតា ៣ ពួកទៀត ដែលមានសម្មតិទេវតា ទេវតាដោយសេចក្ដីសន្មត់មានព្រះមហាក្សត្រជាដើម, ឧបបត្តិទេវតា ទេវតាដោយកំណើតបុណ្យ, វិសុទ្ធិទេវតា ទេវតាដោយសេចក្ដីបរិសុទ្ធ មានព្រះអរហន្តាខីណាស្រពជាដើម កូនបានស្គាល់នោះក៏ព្រោះតែមាតាបិតាបានណែ

នាំប្រាប់ ទើបកូនទាំងអស់បានស្គាល់ ដូច្នេះហើយទើបលោកពោលទុកថា មាតាបិតាជាបុព្វទេព គឺជាទេវតាខាងដើមរបស់បុត្រធីតា ។

## មាតាបិតាជាអាហុនេយ្យបុគ្គលរបស់បុត្រធីតា

បានជាលោកពោលទុកថា មាតាបិតាជាអាហុនេយ្យបុគ្គល ព្រោះលោកគឺជាអ្នកដែលគួរទទួលនូវទេយ្យវត្ថុដែលកូនប្រុសស្រីគោរពបូជា មានការជូនបាយទឹកនំចំណី សំពត់អាវសារស្បៃជាដើម ។ ហេតុនេះហើយបានជាព្រះដ៏មានបុណ្យ ទ្រង់ត្រាស់សំដែងទុកនៅក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ទុតិយបណ្ណាសកៈ បត្តកម្មវគ្គ ភាគ ៤២ ទំព័រ ១៧៤ :

**ពហុបការា ភិក្ខវេ មាតាបិតរោ បុត្តានំ អាបាទកា បោសកា ឥមស្ស លោកស្ស ទស្សេតារោតិ ។**

ប្រែថា ម្នាលភិក្ខុទាំងឡាយ ព្រោះថាមាតាបិតាទាំងឡាយមានឧបការៈច្រើន ជាអ្នករក្សា ជាអ្នកចិញ្ចឹម ជាអ្នកបង្ហាញនូវលោកនេះដល់បុត្រទាំងឡាយ ។ ទើបទ្រង់ត្រាស់សំដែងបន្តទៀតថា :

**ព្រហ្មាតិ មាតាបិតរោ បុព្វាចរិយាតិ វុច្ចរេ អាហុនេយ្យា ច បុត្តានំ បជាយ អនុកម្បកា ។**

ប្រែថា មាតាបិតាទាំងឡាយជាអ្នកអនុគ្រោះដល់ពួកបុត្រ ហៅថាជាព្រះព្រហ្មផង ហៅថាជាបុព្វាចារ្យផង ជាអាហុនេយ្យបុគ្គលផងរបស់

បុត្រទាំងឡាយ ។

អោ សាធុជន ហៃសាធុសប្បុរសទាំងឡាយ មាតាបិតាមិនត្រឹមតែជាអ្នកប្រកបដោយព្រហ្មវិហារធម៌ទាំង ៤ ប៉ុណ្ណោះទេ លោកទាំងពីរថែមទាំងមាននូវសង្គហធម៌ទាំងឡាយ ៥ សង្គ្រោះមកលើបុត្រធីតាថែមទៀតផង ។

## សង្គហធម៌របស់មាតាបិតា ៥ យ៉ាង គឺ :

**១.បាបា និវារេន្តិ** មាតាបិតាតែងតែហាមប្រាមកូនអោយវៀរចាកនូវអំពើបាបទាំងឡាយដែលនាំឲ្យគេស្អប់ខ្ពើម ពោលគឺវៀរចាកការកាប់សម្លាប់សត្វ បៀតបៀនរាងកាយអ្នកដទៃ លួចឆក់ប្លន់កេងប្រវ័ញ្ចទ្រព្យសម្បត្តិអ្នកដទៃ ការប្រព្រឹត្តល្មើសរំលោភប្រពៃណីលើប្រពន្ធកូនអ្នកដទៃ ការកុហកភូតភរបោកអ្នកដទៃ ព្រមទាំងវៀរចាកនូវការសេពគ្រឿងស្រវឹង វីគ្រឿងញៀនផ្សេងៗ មានអាភៀន យ៉ាម៉ា មួយអន្លើដោយល្បែងពាលហាវ៉ាសែគ្រប់ប្រភេទដែលនាំមកនូវសេចក្ដីវិនាសអន្តរាយដល់ខ្លួនឯង និងសង្គមជាតិ ដូចនេះហើយមាតាបិតាតោងប្រញាប់ប្រញាល់ទូន្មានកូនតាំងអំពីនៅតូចក្រុចឆ្មាអោយចេះខ្លាចនូវអំពើបាបទាំងពួង សមដូចបុរាណសុភាសិតមួយឃ្លាពោលថា : ដំរែកទាន់នៅខ្ចី ទូន្មានកូនចៅទាន់នៅក្មេងវ័យ ។

**២.កល្យាណេ និវេសេន្តិ** មាតាបិតាតែងតែដឹកនាំកូនឱ្យធ្វើអំពើជាបុណ្យកុសល អំពើសុចរិតយុត្តិធម៌ ដូចជាការធ្វើទាន រក្សាសីល

ការចេះគោរពម្តាយឪពុក ព្រះសង្ឃ ចាស់ព្រឹទ្ធាចារ្យគ្រូបាអាចារ្យជាដើម ពុំនោះសោតមាតាបិតាតែងតែពន្យល់ណែនាំផ្លូវផលអានិសង្សរបស់បុណ្យកុសល ដែលកូនបានធ្វើ ហើយកាលដែលធ្វើបុណ្យជារឿយ ៗ នោះតែងនាំមកនូវសេចក្តីសុខសប្បាយ ហើយជាទីស្រឡាញ់នៃមនុស្ស និងទេវតា ។ ទេវតាទាំងឡាយតែងតែថែរក្សាឃុំគ្រងទាំងយប់ទាំងថ្ងៃ ហើយមានកេរ្តិ៍ឈ្មោះល្បីរន្ធឺសុះសាយ ជាពិសេសនោះបន្ទាប់ពីស្លាប់ទៅវិញតែងកើតក្នុងសុគតិភព ។

**៣.សិប្បំ សិក្ខាបេន្តិ** កាលបើកូនមានវ័យសមគួរនឹងសិក្សាហើយ ម្តាយឪពុកតែងតែខ្នះខ្នែងបញ្ជូនកូនឱ្យទៅរៀនសូត្រនៅតាមសាលានានា និងជួយជំរុញលើកទឹកចិត្តឱ្យកូនស្រឡាញ់ពេញចិត្តចំពោះការសិក្សា ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ ជាពិសេសមុខវិជ្ជាដែលសង្គមត្រូវការប្រើប្រាស់សព្វថ្ងៃ។ មិនត្រឹមតែប៉ុណ្ណោះ គាត់ថែមទាំងពន្យល់អំពីផលវិបាកនៃភាពល្ងិតល្ងង់ដែលជាមាគ៌ាមួយឈានទៅរកភាពអន់ថយ ភាពថោកទាប មិនអាចថែរក្សា ឬលើកស្ទួយជីវភាពគ្រួសារឱ្យរុងរឿងថ្កុំថ្កើងបានឡើយ អាស្រ័យហេតុនេះហើយមានតែភាពចេះដឹងប៉ុណ្ណោះសោតដែលធ្វើឱ្យយើងមានកិត្តិយសថ្លៃថ្លា មានគេគោរពរាប់អាន និងអាចជួយលើកស្ទួយវង្សត្រកូល ជាតិសាសនាឱ្យបានរុងរឿងចំរើនជាភិយ្យោភាព ។

**៤.បតិរូបេន ទារេន សំយោជេន្តិ** មាតាបិតាកាលបើដឹងថា កូនរបស់ខ្លួនចំរើនវ័យធំល្មមមានគូស្រករហើយ គាត់តែងតែរៀបចំទុក

ដាក់កូនទៅឱ្យមានភរិយាស្វាមីទៅតាមសមត្ថភាព ធនធានពូជពង្សវង្សត្រកូល និងតាមប្រពៃណីរបស់ខ្លួន ។

**៥.សមយេ ទាយជ្ជំ និយ្យាទេន្តិ** មាតាបិតាតែងតែចែកទាយាទទ្រព្យសម្បត្តិមរតករបស់ខ្លួនឱ្យកូនតាមសម័យកាល និច្ចសម័យ ១ កាលសម័យ ១ ។ និច្ចសម័យ មាតាបិតាតែងតែចែកទ្រព្យឱ្យកូនជានិច្ច និងជារឿយមិនរំលងខាន ១ ។ កាលសម័យ មាតាបិតាចែកទ្រព្យឱ្យកូនតាមកាល នៅពេលដែលកូនបែកមានគ្រួសារហើយ ។

សរុបសេចក្តីមក គឺមាតាបិតាជាអ្នកប្រកបដោយព្រហ្មវិហារធម៌ ៤ ព្រមទាំង សង្គហធម៌ ៥ ទៅលើបុត្រធីតាគ្រប់រូបទាំងអស់ ព្រោះលោកទាំងពីរបានចិញ្ចឹមបីបាច់រក្សាជាអ្នកមានឧបការៈគុណដ៏ធំធេង ពុំអាចគណនាបានឡើយ ដូច្នេះបុត្រធីតាទាំងឡាយគប្បីដឹងថា មាតាបិតាគឺជាអនន្តគុណ គុណធ្ងន់ដ៏ក្រៃលែង អនេកប្បគុណ គុណច្រើនរាប់មិនអស់ អសមគុណ គុណប្រៀបស្មើពុំបាន អប្បមាណគុណ គុណប្រមាណមិនបាន ។ ដូច្នេះហើយបានជាលោកអ្នកប្រាជ្ញទាំងឡាយ មានសេចក្តីប្រៀបធៀបឧបមាថា : អោយយកផែនដីធ្វើជាក្រដាស ភ្នំសុមេរុធ្វើជាដងពាកា មហាសមុទ្រទឹកធ្លធ្វើជាទឹកខ្មៅ ឱ្យសរសេររៀបរាប់គុណមាតាបិតា ឱ្យគ្រាអស់ផែនដី និងវិចវិលភ្នំព្រះសុមេរុ ព្រមទាំងរីងស្ងួតមហាសមុទ្រទឹកធ្ល ក៏មិនអាចរៀបរាប់អស់គុណនៃមាតាបិតាផង ហេតុនេះបានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែង

ថា : **តេហិ អត្តនោ មាតាបិតូនំ នប្បមជ្ជិតព្វំ** អ្នកទាំងឡាយមិនគប្បីប្រមាថមើលងាយចំពោះមាតាបិតារបស់ខ្លួនទេ ព្រោះមាតាបិតាជាអ្នកមានគុណធំធ្ងន់ ហើយគួរតែគោរពប្រតិបត្តិស្រឡាញ់រាប់អាន គោរពខ្លាចទាំងយប់ទាំងថ្ងៃ ។

ហេតុនេះហើយបុត្រធីតាដែលជា "កតញ្ញូកតវេទីបុគ្គល" គប្បីមើលឃើញនូវគុណរបស់លោកទាំងពីរ ហើយតបគុណលោកវិញ ដោយពិត្រូវបំពេញនូវសង្គហធម៌ សង្គ្រោះមាតាបិតាវិញ :

**សង្គហធម៌របស់បុត្រធីតា ៥ យ៉ាង គឺ :**

**១.ភតោ នេសំ ភរិស្សាមិ** បុត្រធីតា គប្បីចិញ្ចឹមថែរក្សាមាតាបិតាវិញដោយការផ្គត់ផ្គង់ទំនុកបំរុងដោយបច្ច័យ ៤ របស់មាតាបិតា មានការជូននូវសំលៀកបំពាក់ បាយ ទឹក នំចំណី កន្ទេល មុង ភួយ ពូកព្រំ និងថ្នាំកែរោគគ្រប់បែបយ៉ាង ដែលបុត្រធីតាត្រូវធ្វើ និងត្រូវបំពេញនូវភារកិច្ចរបស់ខ្លួន ដូចជាមានគាថាដែលព្រះលោកនាថទ្រង់ត្រាស់សំដែងទុកក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ទុតិយបណ្ណាសក បត្តកម្មវគ្គ ភាគ ៤២ ទំព័រ ១៧៤ ថា :

**តស្មា ហិ នេ នមស្សេយ្យ សក្ករេយ្យាថ បណ្ឌិតោ អន្នេន អថបានេន វត្ថេន សយនេន ច ឧច្ឆាទនេន**

**នហាបនេ ឧច្ឆាទនេន ធោវនេន ចាតិ** ព្រោះហេតុនោះ បណ្ឌិតត្រូវតែនមស្ការ ធ្វើសក្ការៈមាតាបិតាទាំងនោះដោយបាយ ទឹក សំពត់ ទីដេក គ្រឿងប៉ុសលាង ទឹកងូត និងទឹកលាងជើងទាំងពីរ ។

ហេតុនេះ បុត្រធីតាត្រូវធ្វើការគោរពឱនលំទោនចំពោះមាតាបិតាដោយការភ្ជួតទឹក ប៉ុសលាង ព្រមទាំងជូននូវបាយទឹកដល់លោក ជាពិសេសនោះមាតាបិតាគាត់ឃើញកូនរបស់ខ្លួនក្រលំបាក គាត់មិនដែលទាមទារអំពីកូនឡើយ មានតែជួយកូនថែមទៀតផង ដូច្នេះកូនគប្បីយល់ដឹងអំពីទឹកចិត្ត មាតាបិតាគ្រប់រូបទាំងអស់មិនដែលខុសគ្នាឡើយ ។

២.**កិច្ចំ នេសំ ករិស្សាមិ** បុត្រធីតាគប្បីជួយធ្វើកិច្ចការងារមាតាបិតា បើសិនជាលោកមានធុរៈត្រូវពឹងពាក់យើង ជាធម្មតាយើងជាកូនពិតជាមានកិច្ចការងារផ្ទាល់ខ្លួនច្រើនណាស់ ប៉ុន្តែបើសិនជាមាតាបិតាមានធុរៈត្រូវពឹងពាក់នោះ ត្រូវបញ្ឈប់ការងាររបស់ខ្លួនសិន ទោះជារវល់យ៉ាងណាក៏ដោយ មិនត្រូវធ្វើព្រងើយកន្តើយ ឬ ធ្វើមិនដឹងមិនលឺនោះទេ ត្រូវតែជួយខ្វល់ខ្វាយលោកជានិច្ចនៅពេលដែលលោកត្រូវការយើង ។

៣.**កុលវំសំ ឋបេស្សាមិ** បុត្រធីតាគប្បីថែរក្សាវង្សត្រកូលឱ្យបានល្អ ត្រូវការពារកេរ្តិ៍ឈ្មោះមាតាបិតារបស់ខ្លួន និងលើកតម្កើងវង្សត្រកូលឱ្យមានឈ្មោះពីរោះល្បីល្បាញ និងក្រអូបសុះសាយក្នុងសង្គម បុត្រធីតា

ត្រូវប្រព្រឹត្តអាកប្បកិរិយា មារយាទឱ្យបានល្អសមរម្យ ទោះការនិយាយស្តី ការដើរ ដេក ឈរ អង្គុយជាដើម មិនតែប៉ុណ្ណោះសោតត្រូវស្គាល់ ពីឋានៈរៀងៗខ្លួន ខ្ពស់ ទាបរបស់មនុស្ស កុំឱ្យត្រូវដូចពាក្យបុរាណពោលថា: "ជីកឿយជៀតរេង កូនរ៉ែងឆ្លងត្បិតមេបា" ហេតុនេះបុត្រធីតាត្រូវប្រព្រឹត្តក្នុងសីលធម៌ សុជីវធម៌ជានិច្ច ព្រមទាំងប្រព្រឹត្តក្នុងសង្គមឱ្យបានល្អប្រសើរឡើង ។

**៤.នាយទី បដិបទ្ទានិ** បុត្រធីតាគប្បីគោរពប្រតិបត្តិមាតាបិតាឱ្យបានល្អ ពិសេសគឺមាតាបិតាពេលដែលគាត់មានវ័យចាស់ជរាហើយ ព្រោះជាចង់ឱ្យយើងជាកូនចាំបំរើគាត់គ្រប់ពេលណាទាំងអស់ ទោះវេលាយប់ក្តី ថ្ងៃក្តី ចង់ឱ្យកូនទៅជិតខ្លួនជានិច្ច ព្រោះមាតាបិតាខ្លះគាត់ចាស់ស្ទើរតែធ្វើអ្វីលែងកើតទៅហើយ ហេតុនេះយើងជាកូនត្រូវចេះច្របាច់ ចក់ដៃជើងជូនគាត់ និងកិច្ចការផ្សេងទៀត ដោយសុចរិតទៀតត្រង់ជានិច្ច មិនត្រូវធ្វើព្រងើយកន្តើយពាក្យទ្រគោះបោះបោក មាន "ដេរមាន់បង្អើរ ដេរឆ្កែបញ្ឈឺ ដេរឱ្យម្តាយឮ ម្តាយស្រក់ទឹកភ្នែក" ហេតុនេះបុត្រធីតាត្រូវប្រតិបត្តិលោកឱ្យបានល្អ ជាពិសេសនោះ ដូចជារដូវក្តៅ យើងជាកូនគប្បីដងទឹកដាក់ពាង និងជុសលាងជំរះកាយរបស់លោកទាំងពីរដោយសាប៊ូ ប្រេងម្សៅដើម្បីបំបាត់នូវគ្រឿងសៅហ្មងទាំងឡាយ កុំឱ្យដូចពាក្យកំណាព្យដែលអ្នកប្រាជ្ញចងក្រងថា:

ខែផល្គុនចេត្រ ថ្ងៃក្តៅក្រមៀត ឆ្ងាយទឹកហិនហោច
ម៉ែឪចាស់ៗ ក្តៅណាស់អាណោច មិនរកទឹកស្រោច

ឪពុកម្ដាយសោះ ។

មិនមានថ្នមថ្នាក់ មិនដងទឹកដាក់ ពាងដោយសង្គ្រោះ
ដល់ពេលគាត់ស្លាប់ នោះស្រាប់តែស្មោះ អប់ទឹកក្បួមនោះ
ហៅលើកចំអាស់ ។

ម៉ែឪរស់នៅ មិននាំគ្នាទៅ ធ្វើការប្រវាស់
ដាក់វេនក្រោយមុន តបគុណគាត់ចាស់ ស្លាប់ហើយធ្វើណាស់
ដណ្ដើមគ្នារុស ។

បួចស្រែកកញ់រណើ ងាកមើកបេមើ មិនដឹងត្រូវខុស
ទើបកូនវង្វា ស្មារលាទោសខុស ម៉ែឪនៅរស់
មិនដែលវង្វា ។

កាលមានជីវិត នោះកូនមិនគិត ម្ដេចទៅវេរា
ម្ដាយឪចូទ្ធាន កូនគ្មានបូជា បំពេញសទ្ធា
អោយម្ដាយស្មារទាន ។

ស្ដាប់ធម៌ទេសនា ឱ្យម្ដាយជ្រះថ្លា រកសុគតិនិព្វាន
ប្រើម្ដាយធ្វើឆ្នាំ នៅចាំចង្ក្រាន ឱ្យទៅស្មោទាន
ឱ្យអាប់មកវិញ ។

**៥.ឧក្ខិណានុប្បទានំ** បុត្រធីតាគប្បីដឹងថានៅពេលដែលមាតា បិតា គាត់ធ្វើមរណៈកាលទៅកាន់លោកខាងមុខ យើងជាកូនត្រូវធ្វើបុណ្យ

ឈាបនកិច្ច ព្រមទាំងធ្វើបុណ្យកុសលឱ្យបានញឹកញាប់ ហើយនឹងជារឿយៗ ដើម្បីឧទ្ទិស្សបុណ្យកុសលជូនលោកទាំងពីរ ។

គោ សាធចោ ហៃសាធុសប្បុរសទាំងឡាយ ប្រសិនបើជាបុត្រធីតាណាមួយបានដឹងនូវគុណូបការៈចំពោះមាតាបិតា ហើយបំពេញនូវតួនាទីរបស់ខ្លួនឱ្យបានល្អ ហើយថែមទាំងឱ្យប្រសើរថែមទៀតផង ពីព្រោះបំពេញសម្បទាផងមិនទៅលើមាតាបិតាថែមទៀតទើបល្អប្រសើរ ។

## សម្បទាធម៌ ៤ យ៉ាង គឺ ៖

១.សទ្ធាសម្បទា ដល់ព្រមដោយសទ្ធា ប្រសិនជាមាតាបិតា ជាអ្នកគ្មានសទ្ធា ជឿលើអំពើកម្ម ហើយនិងផលទេ បុត្រធីតា គប្បីដឹកនាំគាត់ទាំងពីរនាក់ឱ្យមានសទ្ធាឡើង ។

២.សីលសម្បទា ដល់ព្រមដោយសីល ប្រសិនជាមាតាបិតា ជាអ្នកទ្រុស្តសីល មានការសម្លាប់សត្វជាដើម បុត្រធីតាគប្បីពន្យល់ណែនាំគាត់ទាំងពីរនាក់ឱ្យរក្សាសីលឡើង ។

៣.ចាគសម្បទា ដល់ព្រមដោយការលះ ប្រសិនជាមាតាបិតា ជាអ្នកកំណាញ់ស្វិតស្វាញ មិនចេះចំណាយធនធានធ្វើទាននោះទេ បុត្រធីតា គប្បីពន្យល់ណែនាំគាត់ឱ្យចេះលះបង់ទ្រព្យសម្បត្តិធ្វើទានឡើង ។

៤.បញ្ញាសម្បទា ដល់ព្រមដោយបញ្ញា ប្រសិនជាមាតាបិតា

ជាអ្នកមិនចូលចិត្តស្តាប់ធម៌ទេសនា ឬ ការសិក្សាធម៌អាថ៌នោះទេ គប្បីដឹកនាំគាត់ឱ្យចេះស្តាប់ធម៌ និងសិក្សារៀនសូត្រដើម្បីជាទីចំរើនដោយបញ្ញា ។

ហេតុនេះបានជាមានព្រះគាថាដែលសម្តែងទុកក្នុងសុត្តន្តបិដក អង្គុត្តរ-និកាយ ទុកនិបាត បឋមបណ្ណាសក សមចិត្តវគ្គ ភាគ ៤០ ទំព័រ ១៣៨ ថា :

**យោ ច ខោ ភិក្ខវេ មាតាបិតរោ អស្សទ្ធេ សទ្ធាសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ ទុស្សីលេ សីលសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ មច្ឆរឹ ចាគសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ ទុប្បញ្ញេ បញ្ញាសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ ឯត្តាវតា ខោ ភិក្ខវេ មាតាបិតុន្នំ កតញ្ច ហោតិ បដិកតញ្ចាតិ ៕**

ម្នាលភិក្ខុទាំងឡាយ បើកុលបុត្រណាមួយ ដឹកនាំមាតាបិតាដែលមិនមានសទ្ធាឱ្យកាន់យក ឱ្យអាស្រ័យនៅ ឱ្យតាំងនៅក្នុងសទ្ធាសម្បទា, បើទ្រុស្តសីលឱ្យកាន់យក ឱ្យអាស្រ័យនៅ ឱ្យតាំងនៅក្នុងសីលសម្បទា, បើកំណាញ់ឱ្យកាន់យក ឱ្យអាស្រ័យនៅ ឱ្យតាំងនៅក្នុងចាគសម្បទា, បើឥតបញ្ញាឱ្យកាន់យក ឱ្យអាស្រ័យនៅ ឱ្យតាំងនៅក្នុងបញ្ញាសម្បទា ហេតុ

មានប្រមាណប៉ុណ្ណោះ ទើបហៅថា ធ្វើ ឬ ចាធ្វើ ឧបដ្ឋស់មាតា និង បិតាមែន ។

បុត្រធីតាណាបានបដិបត្តិចំពោះមាតាបិតាដោយសង្គហធម៌ ៥ និង សម្បទាធម៌ ៤ នេះហើយ រមែងជាអ្នកមិនច្យុតចាកអត្ថភាពឡើយ ទោះបី ជាបុគ្គលនោះជួបប្រទះអន្តរាយគ្រោះថ្នាក់យ៉ាងណាក៏ដោយ ក៏អាចរួចចាក ទុក្ខទោស និងភ័យអន្តរាយទាំងពួងបាន ដូចមានខិទានដែលសំដែងទុកក្នុង គម្ពីរមង្គលត្ថទីបនី ភាគ ២ ទំព័រ ២៦៣ ថា :

## រឿងស្តេចដំរី

កាលពីព្រេងនាយ ព្រះបរមពោធិសត្វនៃយើងទ្រង់បានសោយព្រះជាតិ ជាស្តេចដំរី មានព្រះសរីរកាយសសុទ្ធ មានដំរី ៨០០០០ ជាបរិវារបាន ចិញ្ចឹមមាតាដែលចាស់ជរាមានចក្ខុងងឹតទាំងគូ សម្រេចសម្រាន្តឥរិយាបថក្នុង ហេមពាន្តប្រទេស ។ ក្នុងកាលជាខាងក្រោយ ទ្រង់ចេញចោលបរិវារ ទាំងអស់ ហើយនាំមាតាទៅអាស្រ័យទៀបស្រះមានផ្កាឈូក នាជើងភ្នំឈ្មោះ ចណ្ឌោរណៈ ឱ្យមាតាបិតនៅក្នុងល្អាកភ្នំនោះ ខ្លួនបំរើដោយគោរព ។ សម័យមួយ ព្រានព្រៃម្នាក់នៅក្នុងក្រុងពារាណសី ដើរចូលក្នុងព្រៃដើម្បី បរបាញ់សត្វស្លាបក្សា ស្រាប់តែវង្វេងផ្លូវអស់មួយសប្តាហ៍ ក៏យំរៀបរាប់ឮរ ពាច់ ហើយទៅដល់ទីនោះ ។ ស្តេចដំរីអាណិតព្រានព្រៃក៏ឱ្យឡើងជិះលើខ្នង របស់ខ្លួន ទើបនាំត្រឡប់ទៅកាន់ផ្លូវមនុស្សវិញ ។ ឯព្រានព្រៃនោះជាមនុស្ស

អព្រៃយផ្សរជាតិ អបលក្ខណ៍ ទ្រើស្តស្ទូរទុរយស បានត្រឡប់ទៅកាន់ក្រុង ពារាណសីវិញ ក៏នាំរឿងនោះទៅថ្វាយព្រះចៅម្ចាស់ផែនដីឱ្យទ្រង់ជ្រាប ព្រោះដំរីមង្គលរបស់ព្រះអង្គទើបតែស្លាប់ថ្មីៗ ។ ទ្រង់ក៏កើតសេចក្តីរីករាយត្រេកអរយ៉ាងពន្លឹក ទើបចាត់ឱ្យហ្មដំរីម្នាក់ឱ្យទៅចាប់ដំរីពោធិសត្វ ហើយនាំយកមកអោយនៅក្នុងរោងមង្គលនាបរមរាជវាំង មិនតែប៉ុណ្ណោះទ្រង់បានប្រទានអាហារភោជន មានរសឆ្ងាញ់ពិសារច្រើនមុខដល់ដំរី ។ ឯដំរីមិនព្រមទទួលព្រះរាជអំណោយនោះសោះ ព្រោះខ្លួនមិនបានស្វែងរកចំណីមកចិញ្ចឹមមាតាដែលនៅក្នុងព្រៃភ្នំ ហើយថ្លែងសេចក្តីថ្វាយថា បពិត្រមហារាជ ទូលព្រះបង្គំជាអ្នកចិញ្ចឹមមាតាដែលមានចក្ខុអន្ធការ មាតាទូលព្រះបង្គំ បើឃ្លាតខ្ញុំព្រះអង្គហើយ មុខជាស្លាប់ដោយពិត ខ្ញុំព្រះអង្គមិនត្រូវការដោយឥស្សរយសដែលកើតឡើងក្នុងទីកំពាំងមាតាប៉ុណ្ណោះទេ មាតាទូលព្រះបង្គំអត់អាហារគម្រប់ ៧ ថ្ងៃ និងថ្ងៃនេះហើយ ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ហើយ ក៏ថ្លែងគាថា ថា :

**មុញ្ចេថេតំ មហានាគំ យោយំ ភរតិ មាតរំ សមេតុ មាតរា នាគោ សហ សព្វេហិ ញាតិភិ ។**

រីអ្នកចូរលែងដំរីធំនេះ ព្រោះជាសត្វចេះចិញ្ចឹមមាតា មហានាគអើយនៅឱ្យសុខា រួបរួមមាតា និងញាតិសន្តាន ។

កាលព្រះពោធិសត្វ រួចចាកចំណងហើយ បានសំដែងគាថាទសរាជ

ធម៌ថ្វាយព្រះរាជាបន្តិច ហើយចេញពីទីនោះ ទៅកាន់សំណាក់មាតាក្នុងថ្ងៃនោះឯង ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងគុណនៃព្រះពោធិសត្វយ៉ាងក្រៃលែង ទើបចាត់ឲ្យគេធ្វើស្រុកមួយក្បែរបទុមស្រះនោះ ហើយតាំងវត្តមើលថ្លីជាប់ជានិច្ច ពេលជាខាងក្រោយ មាតាព្រះពោធិសត្វធ្វើមរណៈកាល ទ្រង់ក៏ចាត់ធ្វើឈាបនកិច្ចសរីរៈនោះ ហើយកសាងអាស្រមបទមួយឈ្មោះករណ្ឌកៈ ទើបឃ្លាតត្រឡប់ទៅកាន់នគរវិញ ។ កាលនោះ ឥសី ៥០០ ចុះពីភ្នំហេមពាន្តមកនៅក្នុងទីនោះ ។ ព្រះរាជាក៏សុំបរិឲ្យៗនូវវត្តមើលបន្តិមដល់ពួកឥសី កាលបើពោធិសត្វស្លាប់ហើយ ទ្រង់ក៏ធ្វើបញ្ញើបណ្ដាយថ្វ ប៉ុន្មាព្រះពោធិ-សត្វ ហើយធ្វើសក្ការៈបូជាជានិច្ច ។ អ្នកជម្ពូទ្វីបទាំងឡាយ កំណត់កាលមួយឆ្នាំ តែងតែធ្វើបុណ្យរំលឹកវិញ្ញាណក្ខន្ធបរិពោធិសត្វម្តង ។ បុណ្យនោះឈ្មោះថា បុណ្យប្រត្តូងបរិ ។

នែ សាធុជន ដែលជាពុទ្ធបរិសទាំងឡាយ ការលើកឡើងនូវបុគ្គលាធិដ្ឋានមក ដើម្បីបញ្ជាក់ឲ្យឃើញថា ការទំនុកបម្រុងបម្រើមាតាបិតាដោយគោរពនោះ ទោះបីជាមានទុច្ចទោសយ៉ាងណាក៏ដោយ ក៏រមែងរួចចាកទុច្ចទោសនោះបាន ហើយបុគ្គលនោះទោះស្លាប់ទៅ រមែងកើតក្នុងស្ថានសួគ៌ សមដូចព្រះគាថាដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងទុកក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត បត្តកម្មវគ្គ ភាគ ៤២ ទំព័រ ១៣៥ ថា :

**តាយ នំ បារិចរិយាយ មាតាបិតូសុ បណ្ឌិតា**
**ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ ។**

ព្រោះការប្រតិបត្តិក្នុងមាតាបិតានោះឯង បណ្ឌិតទាំងឡាយតែងសរសើរនូវបុគ្គលនោះក្នុងលោកនេះឯង លុះស្លាប់ទៅហើយ រមែងរីករាយក្នុងស្ថានសួគ៌ ។

ផ្ទុយទៅវិញ បើបុត្រធីតាណា ប្រទូស្តរាយចំពោះមាតាបិតារបស់ខ្លួន មានជេរប្រទេច វាយដំធ្វើបាក់ រហូតឈានដល់ការកាប់សម្លាប់ជាដើមទៀត ដោយមិនបានប្រតិបត្តិឱ្យត្រូវតាមតួនាទីរបស់ខ្លួនទេ រមែងជួបប្រទះតែសេចក្តីទុក្ខក្នុងបច្ចុប្បន្ន អ្នកប្រាជ្ញទាំងឡាយតែងតិះដៀល ព្រមទាំងញាតិមិត្តជិតខាងគេមិនរាប់អាន ធ្វើដំណើរទៅណាមកណាតែងមានឧបសគ្គចង្រៃ ជាពិសេសទៀតនោះ សូម្បីតែបងប្អូនបង្កើតរបស់ខ្លួនផ្ទាល់ក៏មិនទុកចិត្តទៀតផង ។ ម្យ៉ាងទៀត បើកូននោះស្លាប់ទៅហើយ រមែងជួបទុក្ខក្នុងអបាយភូមិទាំង ៤ ណាមួយមិនខានឡើយ ។ សមដូចនិទានរឿងដែលសំដែងទុកក្នុងមង្គលត្ថ-ទីបនី ភាគ ២ ថា :

## រឿងមិត្តវិន្ទុក

មានសេចក្តីដំណាលថា ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ មានសេដ្ឋីបុត្រម្នាក់ឈ្មោះ មិត្តវិន្ទុកៈ មានទ្រព្យសម្បត្តិ ៨០ កោដិ

ក្នុងក្រុងពារាណសី ជាបុគ្គលទ្រុស្តសីល មាតាបិតាជាសោតាបន្នបុគ្គល ។ លុះចំណេរជាខាងក្រោយមក បិតារបស់មិត្តវិន្ទុកៈ ក៏បានធ្វើមរណៈកាលទៅ បុរសមិត្តវិន្ទុកៈ បាននិយាយនឹងមាតាថា បពិត្រលោកម៉ែ ខ្ញុំនឹងធ្វើជំនួញដោយសំពៅ ។ មាតានិយាយថា នែបា អ្នកជាកូនតូចមួយ ឯទ្រព្យក្នុងផ្ទះនេះមានច្រើនណាស់ ចំណែកឯសមុទ្រ មានទុក្ខ និងសំពៅ មួយអន្លើដោយខ្យល់ព្យុះ និងរលកធំៗច្រើនណាស់កូនកុំទៅឡើយ ។ បុរសឈ្មោះមិត្តវិន្ទុកៈ នោះនិយាយថា ខ្ញុំនឹងទៅឥឡូវនេះ ម៉ែមិនអាចឃាត់ខ្ញុំបានទេ ។

ទោះបីម្ដាយចាប់ដៃរបស់ខ្លួនក៏ដោយ ក៏នាយមិត្តវិន្ទុកៈនោះ ក៏រលាស់ដៃព្រមវាយម្ដាយឱ្យដួលហើយ បន្ទាប់មកក៏ឈោងកន្លងម្ដាយ ស្ទុះឆ្ពោះទៅកាន់សមុទ្រដោយសំពៅ ។ ក្នុងថ្ងៃទី ៧ នាវាក៏បានឈប់នៅនឹងថ្កល់ ព្រោះអាស្រ័យបាបរបស់មិត្តវិន្ទុកៈ ។ ពួកអ្នកសំពៅក៏នាំគ្នាចាប់ស្លាកដោយគិតថា “ក្នុងទូកនេះ នឹងមានមនុស្សកាឡកិណ្ណី” ។ លុះមនុស្សទាំងឡាយនោះចាប់ស្លាកអស់រយៈពេល ៣ ដង ឯស្លាកកាឡកិណ្ណីនោះ ក៏ធ្លាក់ទៅក្នុងដៃរបស់មិត្តវិន្ទុកៈអស់វារៈទាំង ៣ ដង ។

គ្រានោះ មនុស្សទាំងឡាយក៏ឱ្យក្បូនដល់បុរសនោះ ហើយក៏បណ្ដែតចោលលើខ្នងសមុទ្រនោះទៅ ។ នាយមិត្តវិន្ទុកៈក៏អណ្ដែតត្រសែតទៅតាមកក្បូនដល់កោះមួយដោយលំដាប់បានឃើញនគរមួយមានទ្វារបួនលើកោះនោះ ។ បានលឺថា ប្រទេសនោះឈ្មោះថា ឧស្សទនរក ជាទីកន្លែងដែលសត្វកើត

ក្នុងនរកជាច្រើនសោយកម្ម ។ តែនគរនុ៎ះ បានប្រាកដឡើងដល់នាយមិត្តវិន្ទុកៈ ដូចជានគរដែលគេប្រដាប់តាក់តែង ហើយដោយកំលាំងនៃកម្ម គឺការវាយប្រហារដល់ម្ដាយ ។ នាយមិត្តវិន្ទុកៈនោះគិតថា "អាត្មាអញនឹងបានជាស្ដេចសោយរាជ្យក្នុងនគរនេះ" ដូច្នេះហើយ ទើបដើរចូលទៅបានឃើញសត្វនរកមួយ មានកងចក្រដ៏មុតវិលលើក្បាលនៃសត្វនរកកំពុងស្រែកយំ ។

គ្រានោះ កងចក្រដ៏មុតលើក្បាលនៃសត្វនរកនោះ បានប្រាកដដល់មិត្តវិន្ទុកៈ ដូចជាផ្កាឈូក, គ្រឿងចំណង ៥ យ៉ាងពួដ៏ទ្រូង (នៃសត្វនរក) បានប្រាកដដូចជាគ្រឿងប្រដាប់ទ្រូង ឈាមដែលហូរចេញពីសរីរៈ (នៃសត្វនរក) បានប្រាកដដូចជាខ្លឹមចន្ទន៍សំរាប់លាប, សំឡេងថ្ងូរយំ (នៃសត្វនរក) បានប្រាកដដូចជាសំឡេងនៃតូរ្យតន្ត្រី ។ នាយមិត្តវិន្ទុកៈនោះ ចូលទៅជិតសត្វនរកនោះហើយពោលថា "ម្នាលបុរសដ៏ចំរើនអ្នកបានសៀតផ្កាឈូកយូរណាស់ហើយ ចូរអ្នកឱ្យផ្កាឈូកនោះដល់ខ្ញុំមក" ។ សត្វនរកពោលថា "សំឡាញ់អើយ នេះមិនមែនផ្កាឈូកទេ នេះគឺជាកងចក្រដ៏មុតទេតើ" ។ មិត្តវិន្ទុកៈពោលថា "អ្នកពោលយ៉ាងនេះ ព្រោះអ្នកមិនប្រាថ្នានឹងឱ្យដល់ខ្ញុំ" ។ សត្វនរកគិតថា កម្មរបស់អាត្មាអញនឹងអស់ហើយ ឯបុរសនេះក៏គប្បីជាអ្នកវាយប្រហារមាតាបិតា ដូចជាអញដែរហើយ បានជាមក ព្រោះហេតុនោះ អញនឹងឱ្យកងចក្រដ៏មុតដល់បុរសនោះ, ដូច្នេះហើយពោលថា "ម្នាលអ្នកដ៏ចំរើន សូមអ្នកអញ្ជើញមក សូមអ្នកទទួលយកផ្កាឈូកនេះចុះ" ដូច្នេះហើយ

កំពោះកងចក្រដ៏មុតនោះ ទៅលើក្បាលនៃមិត្តវិន្ទុកៈនោះ ។ កងចក្រនោះវិលទៅប្លូចជាកិនកំទេចនូវអំបែងក្បាលនៃមិត្តវិន្ទុកៈនោះ ។

ក្នុងខណៈនោះ នាយមិត្តវិន្ទុកៈ ដឹងថារបស់នោះជាកងចក្រដ៏មុត ទើបពោលថា "ចូរអ្នកទទួលយកនូវកងចក្រដ៏មុតរបស់អ្នកវិញទៅ" ដូច្នេះហើយ ដល់នូវវេទនា ស្រែកថ្ងូរញយំ សត្វនរកនោះក៏អន្តរធានបាត់ទៅ ។ ឯនាយមិត្តវិន្ទុកៈ សោយសេចក្តីទុក្ខក្នុងឧស្សទនរកនោះរស់កាលយ៉ាងយូរ ដោយផលនៃអកុសលកម្ម គឺការប្រហារដល់មាតា កាលបើផលកម្មអស់ហើយ ទើបទម្លាក់កងចក្រដ៏មុតចោលចេញហើយ ទៅតាមយថាកម្ម ។

ដូច្នេះបុត្រធីតាណាមួយ បានប្រព្រឹត្តជាមនុស្សអកតញ្ញូ មិនដឹងគុណមាតាបិតានោះទេ ជីវិតតែប្រទុស្តរាយ ចំពោះលោកទាំងពីរនាក់ ទេវតានៅខាងក្រៅផ្ទះដាក់ផ្កាសារឱ្យជួបប្រទះតែសេចក្តីវិនាស និងសេចក្តីអន្តរាយផ្សេងៗជាទៃទៀត ពុំនោះសោតរមែងសោយសេចក្តីទុក្ខក្នុងបច្ចុប្បន្ន និងអនាគតមិនលែងឡើយ ។

## អកតញ្ញូ

(ស្នាព្រះហស្តក្រោយបង្អស់របស់សម្តេចសង្ឃរាជ ជោតញ្ញាណោ ជួន ណាត)

អកតញ្ញូ ពុំដឹងគុណគ្រូ មាតាបិតា
និងអ្នកមានគុណ ឯទៀតណាៗ ចិត្តវាហានក្លា

រករឿងចាប់ទោស ។

នោះអ្នកមានគុណា មានចិត្តជាបុណ្យ អត់ឱនសន្ដោស

សង្គ្រោះឱ្យវា រួចចាកទុក្ខទោស វានៅតែកោស

រួសរករឿងទៀត ។

ទោះឈើផែនដី ទាំងមូលឱ្យខ្ចី វានៅតែឃ្លៀត

រករឿងវាវិញ ដោយការជ្រែកជ្រៀត នាំជនឯទៀត

ឱ្យចូលដៃផង ។

នេះគឺជនពាល គំនិតឆោលរាល អាក្រក់កន្លង

ទោះព្រះសម្ពុទ្ធ វិសុទ្ធឥតហ្មង ក៏អាចចំលង

វាពុំបានឡើយ ។

ហេតុនេះ បុត្រធីតាទាំងឡាយគប្បីជាអ្នកប្រតិបត្តិមាតាបិតាឱ្យបានល្អ ទើបជាការប្រសើរ ហើយទេវតាទាំងឡាយដែលនៅខាងក្រៅផ្ទះ រមែងឱ្យពរជ័យដល់បុគ្គលនោះមិនខានឡើយ មួយសោតក៏ជាទីស្រឡាញ់រាប់អាននៃបណ្ឌិតទាំងឡាយដែរ ហើយបុគ្គលណាដែលមានកតញ្ញូកតវេទីនោះ រមែងបានទទួលអានិសង្សដ៏ច្រើនមិនខានឡើយ ។

## អានិសង្សកតញ្ញូ ៤ យ៉ាង គឺ :

**១.កុសលមូលតា** ជាឫសគល់នៃកុសលធម៌ទាំងពួង

២.បធានតា ជាប្រធាននៃបារមី ៣០,មានទានបារមីជាដើម

៣.បុញ្ញាភិសន្ទនោ ជាទីចម្រើនដោយបុណ្យកុសល

៤.សម្បត្តិ សមិទ្ធន្តា ជាទីសំរេចនូវសម្បត្តិ ៣ ណុន

បុគ្គលជាបុត្របីតាដែលបាននូវសម្បត្តិទាំងអស់នេះ ក៏ព្រោះតែមាននូវ "កតញ្ញូកតវេទី" នោះឯង ។ ហេតុដូច្នេះហើយ បានជាព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងទុកក្នុងមង្គលសូត្រថា :

មាតាបិតុឧបដ្ឋានំ ការបម្រើមាតាបិតាដោយធម៌ជាមង្គលមួយដ៏ឧត្តម ។

## បុណ្យទក្ខិណានុប្បទាន

ពាក្យថា ទក្ខិណានុប្បទាន ជាពាក្យប្រមូលរបស់ភាសាបាលីពីរបទ គឺ ទក្ខិណា+អនុប្បទាន ។ ទក្ខិណា ប្រែថា ខាងស្តាំខាងត្បូង, ទានដែលបុគ្គលជឿកម្ម និងផលហើយឱ្យ គឺជាឈ្មោះនៃបុណ្យកុសល ។ វិគ្គហៈថា ទាតព្វាតិ ទក្ខិណា វត្ថុដែលគេត្រូវឱ្យឈ្មោះថា ទក្ខិណា ។

កម្មផលំ សទ្ទហិត្វា ទាតព្វានំ ទក្ខិណា ទានដែលបុគ្គលគប្បីជឿនូវផលរបស់កម្ម ហើយទើបលះឱ្យឈ្មោះថាទក្ខិណា ។ បានសេចក្តីថា បុគ្គលឯណានីមួយ ទោះបុរសក្តី ស្ត្រីក្តី ដែលមានជំនឿជឿជាក់

យ៉ាងមាំនូវផលរបស់កុសលកម្ម មានទានជាដើមថា ការឱ្យទានជាហេតុធ្វើឱ្យមានទ្រព្យសម្បត្តិចម្រើនរុងរឿង មិនវិនាសអន្តរាយ ដោយប្រការណាមួយ ហើយគឺជាគ្រឿងកំចាត់បង់នូវចិត្តមិនស្អាត គឺសេចក្តីកំណាញ់នោះ និងជឿជាក់ច្បាស់ថា ការមិនឱ្យទានជាហេតុនាំឱ្យក្រីក្រលំបាក ហើយខំខ្នះខ្នែងប្រមែប្រមូលទ្រព្យសម្បត្តិមក ហើយបែងចែករំលែកទ្រព្យនោះ ឱ្យដល់អ្នកកំសត់ទុគ៌ត ស្មូមយាចក សមណៈព្រាហ្មណ៍ ភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា តាមកម្លាំងសទ្ធាយ៉ាងនេះឈ្មោះថា ទក្ខិណា ។ **អនុប្បទាន** ប្រែថា តាមឧទ្ទិសដោយ ។ ដូច្នេះពាក្យថា **ទក្ខិណានុប្បទាន** ប្រែថា ទក្ខិណាទានដែលបុគ្គលតាមឧទ្ទិសឱ្យដល់បុគ្គលដែលស្លាប់ទៅហើយ ឬ អំណោយដែលគេឧទ្ទិសទក្ខិណាទានចំពោះបុគ្គលដែលទៅកាន់បរលោកហើយ ។

ព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់ដឹង និងឃើញច្បាស់នូវសេចក្តីទុក្ខ និងសេចក្តីស្រេកឃ្លានដ៏ខ្លាំងក្លារបស់ពួកសត្វអ្នកចូលទៅកាន់កំណើត ជាប្រេតវិស័យ មិនឃើញមានហេតុដែលនាំឱ្យបានសម្បត្តិដូចជា កសិកម្ម ពាណិជ្ជកម្ម គោរក្ខកម្មជាដើម ក្នុងប្រេតភូមិនោះមិនមានឡើយ ពួកប្រេតទាំងនោះអាចញ៉ាំងជីវិតឱ្យរស់នៅបាន ដោយសារផលនៃទានដែលញាតិមិត្តសម្លាញ់ឧទ្ទិសឱ្យអំពីលោកនេះប៉ុណ្ណោះ ។ ម្យ៉ាងទៀត ពួកប្រេតនោះ សូម្បីដើរត្រេចស្វែងរកជួបជនជាញាតិហើយ ក៏មិនអាចស្រែកសុំអង្វរថា សូមលោកមេត្តាឱ្យនូវសំពត់ខោអាវ អាហារបិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ ដល់

ពួកយើងដូច្នោះពុំបានឡើយ ព្រោះហេតុដូច្នោះហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងទុកក្នុងតិរោកុឌ្ឌសូត្រ រំលឹកដល់ជនជាញាតិថា :

**អទាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ បេតានំ ទក្ខិណំ ទជ្ជា បុព្វេ កតមនុស្សរំ ។**

បុគ្គលកាលរលឹកឃើញនូវឧបការៈគុណដែលលោកធ្វើទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះជាញាតិមិត្ត និងជាសម្លាញ់របស់អញ ដូច្នេះ ហើយគួរឱ្យទក្ខិណាទានចំពោះប្រេតទាំងឡាយ ។

បណ្ដាបទនោះ ២ បទថា "**ទក្ខិណំ ទជ្ជា**" មានសេចក្ដីថា កុលបុត្រកាលនឹករលឹក គឺកាលតាមរលឹកនូវឧបការគុណដែលលោកធ្វើហើយក្នុងកាលមុនគ្រប់យ៉ាង យ៉ាងនេះថា "អ្នកនោះបានឱ្យទ្រព្យ ឬ ស្រូវឈ្មោះនេះដល់អញ" ថា "អ្នកនោះបានធ្វើកិច្ចការ ឈ្មោះនេះដល់អញ" ថា "អ្នកឯណោះឈ្មោះថាជាញាតិរបស់អញ ព្រោះជាអ្នកទាក់ទងគ្នាខាងមាតា ឬ ខាងបិតា" ថា "អ្នកឯណោះឈ្មោះថាជាមិត្រ ព្រោះជាអ្នកអាចជួយការពារ ដោយអំណាចនៃសេចក្ដីស្រឡាញ់" ដូច្នេះនឹងថា "បុគ្គលឯណោះជាសម្លាញ់ដែលលេងដីជាមួយនឹងគ្នា" ដូច្នេះ គប្បីអោយ គឺគប្បីប្រគល់ឱ្យនូវទានចំពោះប្រេតទាំងឡាយ ។ បាលីថា "**ទក្ខិណា ទជ្ជា**" ដូច្នេះ

ខ្លះក៏មាន ។ ក្នុងបទថា “**ទេយ្យំ**” នោះ គប្បីជ្រាបវិគ្រោះដូចតទៅ សម្បត្តិណាដែលបុគ្គលគប្បីឱ្យ ហេតុនោះ សម្បត្តិនោះឈ្មោះថា **ទេយ្យំ** ប្រែថា សម្បត្តិដែលបុគ្គលគប្បីឱ្យ ។ សម្បត្តិដែលបុគ្គលគប្បីឱ្យនោះជាអ្វី ? គឺជាទក្ខិណាដើម្បីប្រេតទាំងឡាយ ។ ទក្ខិណានោះអ្នកណាគប្បីឱ្យ ? គឺកុលបុត្រអ្នកនឹករលឹកឃើញអត្ថាធិប្បាយថា អ្នកដែលតាមរលឹកនូវឧបការគុណដែលលោកធ្វើហើយក្នុងកាលមុន ដោយន័យជាដើមថា “អ្នកនោះបានឱ្យនូវរបស់នេះដល់អញ...” ដូច្នេះ ។

ព្រោះហេតុនោះហើយ បុគ្គលគ្រប់រូបគប្បីធ្វើទក្ខិណាទានឧទ្ទិសផលដល់ពួកញាតិឱ្យបានទាន់ពេល ហេតុដូច្នោះហើយ បានជានៅក្នុងអដ្ឋកថាតិរោកុឌ្ឌសូត្រ បានពន្យល់ថា បុគ្គលជាញាតិគប្បីតាមឱ្យនូវទក្ខិណាទានដល់ញាតិអ្នកធ្វើមរណកាលទៅចាប់ផ្ដើមតាំងអំពីថ្ងៃទី ៣ បន្ទាប់ពីថ្ងៃស្លាប់ទៅ។

តាមសេចក្ដីនេះ សម្ដែងឱ្យឃើញថា បុគ្គលជាញាតិអាចធ្វើទក្ខិណានុប្បទានក្រោយអំពីញាតិស្លាប់ទៅបាន ៣ ថ្ងៃ ថ្ងៃណាមួយក៏អាចធ្វើបាន។

ម្យ៉ាងទៀត បើតាមសង្កេតពិនិត្យទៅ មិនឃើញមានហេតុដទៃណាមួយដែលធ្វើឱ្យពពួកញាតិគប្បីធ្វើប្រយោជន៍ឱ្យសម្រេចដល់ប្រេតជាញាតិដោយបានឆាប់រួសរាន់ទាន់ចិត្ត ដូចទក្ខិណាទាននោះឡើយ ។ សមដូចព្រះពុទ្ធដីកាក្នុងតិរោកុឌ្ឌសូត្រថា :

**ឧន្នតេ ឧទកំ វុដ្ឋំ យថា និន្នំ បវត្តតិ ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។**

ទឹកធ្លាក់ចុះលើទីទួល រមែងហូរទៅកាន់ទីទំនាប ដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយ អំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ។

បណ្តាបទទាំងនោះ បទថា **“ឧន្នតេ”** បានដល់លើទីទួល គឺលើភូមិភាគដែលខ្ពស់ ។ បទថា **“វុដ្ឋំ”** បានដល់ទឹកដែលភ្លៀងទាំងឡាយបង្អុរចុះហើយ ។ ពីរបទថា **“និន្នំ បវត្តតិ”** មានសេចក្តីថា រមែងហូរទៅ គឺរមែងហូរធ្លាក់ចុះទៅកាន់ភូមិភាគដែលទំនាប ។ បទថា **“ឧបកប្បតិ”** បានដល់រមែងកើត គឺរមែងប្រាកដបានដល់មិនប្រាសចាកអំពីការកើតផល ។ ព្រោះថា បេតលោកជាទីតាំងនៃការសម្រេចនៃផលទានប្រៀបដូចជាទីទំនាបជាទីតាំងនៃការហូរធ្លាក់ចុះទៅនៃទឹកដូច្នោះឯង ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ទាននោះរមែងសម្រេចផល សត្វដែលស្ថិតនៅក្នុងទីណា ទីនោះឯងហៅថា ទីដ៏សមគួរ ។

**យថា វារិវហា បូរា បរិបូរេន្តិ សាគរំ ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ ។**

ផ្លូវទឹកទាំងឡាយ មានទន្លេ និងស្ទឹងជាដើមដ៏ពេញ រមែងញ៉ាំង

សាគរឱ្យពេញព្រៀបដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះរមែង សម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ ។

ភោ សាធវោ ហេសាធុសប្បុរសផងទាំងឡាយ ការដែលយើងធ្វើទានមានបាយ ទឹក នំចំណី ដើម្បីឧទ្ទិសចូលទានដែលបានធ្វើនោះឱ្យសម្រេចដល់ពួកញាតិ ទាល់តែយើងធ្វើអោយប្រកបដោយអង្គទាំង ៣ ទើបសម្រេចប្រយោជន៍ដល់ពួកប្រេតទាំងនោះបាន ។

## ទក្ខិណានុប្បទានប្រកបដោយអង្គ ៣ គឺ :

**១.ទក្ខិណេយ្យសម្បទា** ដល់ព្រមដោយទក្ខិណេយ្យបុគ្គល។

**២.ទាយកានំ ឧទ្ទិស្សេន** ទាយកដែលជាញាតិបានឧទ្ទិសចំណែកបុណ្យឱ្យ ។

**៣.បេតានំ អត្តនោ អនុមោទនេន** ប្រេតមកអនុមោទនាដោយខ្លួនឯង ។

## អត្ថាធិប្បាយថា

**១.ទក្ខិណេយ្យសម្បទា** ដល់ព្រមដោយទក្ខិណេយ្យបុគ្គល គឺបុគ្គលអ្នកញ៉ាំងទក្ខិណាទានឱ្យមានផលច្រើន បានដល់ព្រះសង្ឃ និងលោកអ្នកមានសីល ។ បុគ្គលអ្នកធ្វើទានសុទ្ធតែជាអ្នកចង់បាននូវផលានិសង្សច្រើន ជាមិនខានឡើយ ជាពិសេសនោះ គឺប្រាថ្នាចង់ឱ្យផលនៃទាននោះសម្រេច

ដល់ពួកញាតិ មានមាតាបិតាជាដើម ដែលស្លាប់បាត់បង់ជីវិតទៅហើយនោះ ឱ្យបានទទួលនូវអានិសង្សដែលញាតិមិត្តកូនចៅបានធ្វើឱ្យ ដើម្បីឱ្យលោកទាំងនោះបានមកកើតក្នុងទីដ៏សមរម្យ មានមនុស្ស ទេវតាជាដើម ហេតុដូច្នោះហើយ អ្នកធ្វើទានទាំងឡាយត្រូវធ្វើទានតាមរយៈ អ្នកមានសីលមានព្រះសង្ឃជាដើម ព្រោះព្រះសង្ឃមានអានុភាពដល់ទក្ខិណានុប្បទាន ២ យ៉ាងគឺ :

១.ព្រះសង្ឃជាស្រែបុណ្យដ៏ប្រសើរ អាចញ៉ាំងទាយកអ្នកមានពូជស្រូវគឺចេតនាធម៌ សូម្បីតិចតួចក៏អាចសម្រេចនូវបុណ្យកុសលដ៏ច្រើន ។ បើមិនមានព្រះសង្ឃមកធ្វើជាបដិគ្គាហកៈនៃទក្ខិណានុប្បទាននោះទេ ទាយកធ្វើដូចម្ដេចនឹងបាននូវបុណ្យកុសល ឧទ្ទិសដល់ប្រេតជាញាតិបាន ព្រោះព្រះសង្ឃជាស្រែបុណ្យរបស់ទាយកអ្នកឱ្យទាន មិនមានស្រែបុណ្យណាឱ្យប្រសើរជាងបានឡើយ សមដូចវារៈបាលីក្នុងគម្ពីរវុឌ្ឍោទ័យថា :

**សង្ឃោ លោកេ សុខេត្តំវ ឧប្បាទិ មហប្ផលំ**

ព្រះសង្ឃក្នុងលោក ជាស្រែបុណ្យមានដីជាដីល្អ ពូជស្រូវគឺទានដែលបុគ្គលសាបព្រោះ "ដីឱ្យ" ទៅហើយរមែងមានផលកើតចំរើនច្រើនណាស់ ។ សមនឹងព្រះគាថាក្នុងតិរោកុឌ្ឌសូត្រ ថា :

**អយញ្ច ខោ ទក្ខិណា ទិន្នា សង្ឃម្ហិ សុបតិដ្ឋិតា ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ ។**

លុះតែទក្ខិណាទាននេះ ដែលបុគ្គលបានឱ្យហើយ តម្កល់ទុកដោយប្រពៃហើយក្នុងព្រះសង្ឃ ទើបសម្រេចផលដោយរួសរាន់ ដើម្បីប្រយោជន៍ដល់ប្រេតនោះអស់កាលជាអង្វែង ។

២.ព្រះសង្ឃជាអ្នកមានសីល មានវត្តបដិបត្តិល្អ មានការប្រព្រឹត្តតាមគន្លងព្រះធិព្វលោកុត្តរធម៌ជាដើម អាចញ៉ាំងចិត្តរបស់ពួកប្រេតឱ្យជ្រះថ្លាត្រេកអរបាន ។

## ពាក្យថាសង្ឃមានន័យ ២ យ៉ាង គឺ :

ន័យទី ១ សង្ឃក្នុងព្រះធម៌ គឺ សង្ឃរតនៈ សំដៅយកព្រះអរិយបុគ្គល ៨ ពួកដែលបានសម្រេចនូវ :

-សោតាបត្តិមគ្គ ១ សោតាបត្តិផល ១

-សកទាគាមិមគ្គ ១ សកទាគាមិផល ១

-អនាគាមិមគ្គ ១ អនាគាមិផល ១

-អរហត្តមគ្គ ១ អរហត្តផល ១

ដែលជាសាវករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ អ្នកប្រតិបត្តិល្អ អ្នកប្រតិបត្តិត្រង់ អ្នកប្រតិបត្តិប្រពៃ បដិបត្តិដើម្បីដឹងច្បាស់អរិយសច្ចធម៌ បដិបត្តិដើម្បីគួរដល់ការថ្វាយបង្គំ ការបូជាជាដើម ។

(ដកស្រង់ចាកអដ្ឋកថាសុមង្គលវិលាសិនី សាមញ្ញផលសូត្រ)

ន័យទី ២ សង្ឃក្នុងព្រះវិន័យ សំដៅយកពួកនៃបព្វជិត គឺភិក្ខុ

សាមណេរក្នុងព្រះពុទ្ធសាសនា បើសង្ឃក្នុងសង្ឃកម្ម សំដៅយកភិក្ខុតាំងអំពី ៤ រូបឡើងទៅ ។

នៅក្នុងមជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ ទក្ខិណាវិភង្គសូត្រ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សំដែងទានដែលដល់ហើយក្នុងសង្ឃមាន ៧ ប្រភេទគឺ :

១.អោយទានក្នុងសង្ឃទាំងពីរផ្នែក មានព្រះពុទ្ធជាប្រមុខ

២.អោយទានក្នុងសង្ឃទាំងពីរផ្នែក កាលតថាគតបរិនិព្វានទៅហើយ

៣.អោយទានក្នុងព្រះភិក្ខុសង្ឃទាំងអស់

៤.អោយទានក្នុងភិក្ខុនីសង្ឃទាំងអស់

៥.និមន្តកំណត់ចំនួនភិក្ខុ ឬ ភិក្ខុនី ឡើងអំពីសង្ឃហើយឱ្យទាន

៦.និមន្តកំណត់ចំនួនភិក្ខុឡើងអំពីសង្ឃ ហើយឱ្យទាន

៧.និមន្តកំណត់ចំនួនភិក្ខុនីឡើងអំពីសង្ឃ ហើយឱ្យទាន

សង្ឃទានទាំង ៧ ប្រភេទនេះ ចំពោះ ៤ ប្រភេទខាងដើម ទ្រង់សំដែងតាមអធ្យាស្រ័យរបស់ទាយក អ្នកដល់ព្រមដោយសទ្ធា និងភោគទ្រព្យ និងធ្វើទានដល់សង្ឃទាំងពីរផ្នែកដោយមិនកំណត់ចំនួនក៏បាន ចំណែក ៣ ប្រការខាងចុង ទ្រង់សំដែងតាមអធ្យាស្រ័យរបស់ទាយកអ្នកមានសទ្ធា តែមិនដល់ព្រមដោយភោគទ្រព្យ និងកំណត់ចំនួនភិក្ខុតាមដែលត្រូវការអំពីសង្ឃ ហើយឱ្យក៏បាន ។

តាមពុទ្ធវចនៈនេះ ក្នុងបច្ចុប្បន្នទាយកអាចធ្វើទានចំពោះសង្ឃបានត្រឹមតែពីរប្រភេទ គឺប្រភេទទី ៣ និង ប្រភេទទី ៦ ។

ពិតណាស់ញាតិញោមជាពុទ្ធបរិស័ទទាំងឡាយ ព្រះសម្មាសម្ពុទ្ធជាអម្ចាស់ មិនដែលសរសើរចំពោះបុគ្គលដែលធ្វើទាន ចំពោះបុគ្គលនោះទេ ទោះបីជាការធ្វើនោះមានទេយ្យវត្ថុដ៏ល្អប្រណីតក៏ដោយ ក៏មិនប្រសើរដែរ ផ្ទុយទៅវិញព្រះអង្គទ្រង់ត្រាស់សរសើរជានិច្ច ចំពោះបុគ្គលណាដែលធ្វើទានចំពោះសង្ឃ ទោះបីទេយ្យវត្ថុនោះសៅហ្មងក៏ដោយ ឱ្យតែបុគ្គលមានសេចក្តីកោតក្រែងគោរពចំពោះទានរបស់ខ្លួននោះ ក៏តែងមានផលច្រើនជាងបើបុគ្គលធ្វើទានចំពោះបុគ្គលដែរ ។

ក្នុងអដ្ឋកថា ទម្ពល្លិវិមាន សំដែងទុកថា :

បុគ្គលណាធ្វើទានក្នុងសម្មតិសង្ឃ ដោយហោចទៅសូម្បីគោត្រភូសង្ឃ ហើយមានចិត្តនៅត្រង់ចំពោះព្រះអរិយសង្ឃ បុគ្គលនោះឈ្មោះថាឱ្យល្អហើយ គោរពបូជាល្អហើយ ជាគ្រឿងបូជាដ៏ធំ ព្រោះទក្ខិណាទាននោះចាត់ជាសង្ឃទានដែលមានផលដ៏ច្រើន ។

ពាក្យថា "**គោត្រភូសង្ឃ**" សំដៅដល់ភិក្ខុដែលបានទទួលចូលរួមធ្វើសង្ឃកម្មតាមព្រះវិន័យ តែមានការប្រព្រឹត្ត និងចិត្តគំនិតដូចជាគ្រហស្ថ មិនសិក្សា មិនបដិបត្តិតាមព្រះធម៌ ព្រះវិន័យ សល់ត្រឹមតែចម្រៀកសំពត់លឿងបន្តិចពាក់ទុកត្រង់ត្រចៀក ឬ ចងកដៃ ទុកជាគ្រឿងសំគាល់ថានៅ

កាន់ភេទជាភិក្ខុ ។ គោត្រភូភិក្ខុ គឺអ្នកដែលឆ្លងគោត្រអំពីគោត្រភិក្ខុមកជាគ្រហស្ថ មានការរស់នៅដូចជាគ្រហស្ថ តែនៅសម្គាល់ខ្លួនថាជាភិក្ខុ ។

ហេតុដូច្នោះហើយ បានជានៅក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ នវកនិបាត វេលាមសូត្រ ភាគ ៤៩ ទំព័រ ៧៧ ថា :

## រឿងវេលាមព្រាហ្មណ៍

កាលដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងប្រារព្ធចំពោះលោកអនាថបិណ្ឌិកគហបតីដែលជាឯតទគ្គលើសឧបាសកទាំងឡាយអ្នកឱ្យទាន ជាអ្នកឧបដ្ឋាកទំនុកបម្រុងព្រះពុទ្ធជាម្ចាស់ និងភិក្ខុសង្ឃដោយបច្ច័យបួន បានកសាងវត្តជេតពន អស់ទ្រព្យ ៥៤ កោដិ ដោយទិញដីអស់ ១៨ កោដិ តម្លៃកសាងអស់ ១៨ កោដិ ពេលសម្ពោធឆ្លងវិហារអស់ ១៨ កោដិ លោកអនាថបិណ្ឌិកសេដ្ឋីពេញចិត្តត្រេកអរក្នុងការឱ្យទាន ដោយប្រាសចាកសេចក្ដីកំណាញ់ ព្រោះជាអរិយសាវកថ្នាក់សោតាបន្ន រហូតអស់ទ្រព្យសម្បត្តិ ព្រមជាមួយអកុសលកម្មក្នុងអតីតឱ្យផល ធ្វើឱ្យរណ្ដៅទ្រព្យដែលកប់ទុកវិនាសអស់ទៅ និងត្រូវពួកអ្នកជំនួញបោកប្រាស់ឋានៈរបស់លោកត្រូវធ្លាក់ទាបចុះ ប៉ុន្តែគាត់នៅតែឱ្យទានជារឿយៗជានិច្ចមិនដែលដាច់ ដោយការជឿកម្ម និងផលរបស់កម្មយ៉ាងមាំមួន ។

ថ្ងៃមួយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរលោកអនាថបិណ្ឌិកគហបតីថា ម្នាលគហបតី ទានក្នុងត្រកូលរបស់អ្នក នៅតែឱ្យដែរឬ ? លោក

អនាថបិណ្ឌិកគបថា បពិត្រព្រះអង្គដ៏ចំរើន ទានក្នុងត្រកូលរបស់ខ្ញុំព្រះអង្គ នៅតែឱ្យដែរ តែទាននោះឯងសៅហ្មង គឺបាយចុងអង្ករ និងទឹកជ្រក់ជាគម្រប់ពីរ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលគហបតី បុគ្គលឱ្យទានសៅហ្មងក្តី ឱ្យទានថ្លៃថ្លាក្តី តែឱ្យទាននោះមិនគោរព មិនធ្វើសេចក្តីកោតក្រែងហើយឱ្យ មិនឱ្យដោយដៃខ្លួនឯង គឺចោលឱ្យ យល់ថាមិនមានផលហើយឱ្យ វិបាករបស់ទាននោះ នោះកើតក្នុងត្រកូលណា ត្រកូលណាមិនមានចិត្តបង្អោនទៅដើម្បីបរិភោគភោជនាហារដ៏ថ្លៃថ្លា មិនបង្អោនទៅដើម្បីប្រើប្រាស់សំពត់ដ៏ថ្លៃថ្លា មិនបង្អោនទៅដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា មិនបង្អោនទៅដើម្បីប្រើប្រាស់កាមគុណដ៏ថ្លៃថ្លា ម្យ៉ាងទៀតពួកជនណាជាកូនក្តី ជាទាសៈក្តី អ្នកបម្រើក្តី កម្មកររបស់បុគ្គលនោះក្តី ជនទាំងនោះរមែងមិនផ្ទង់ត្រចៀកស្តាប់ តែងបញ្ជូនចិត្តទៅកាន់អារម្មណ៍ដទៃ ។ ដំណើរនោះ ព្រោះហេតុអ្វី ? ម្នាលគហបតី ព្រោះថាវិបាកនៃកម្មទាំងឡាយ ដែលបុគ្គលធ្វើដោយសេចក្តីមិនគោរពរមែងមានយ៉ាងនេះ ។

ម្នាលគហបតី បុគ្គលឱ្យទានសៅហ្មងក្តី ឱ្យទានថ្លៃថ្លាក្តី តែឱ្យទាននោះដោយគោរព ធ្វើសេចក្តីកោតក្រែងហើយឱ្យ ឱ្យដោយដៃខ្លួនឯង គឺមិនចោលឱ្យ យល់ថាមានផលហើយទើបឱ្យ វិបាកនៃទាននោះ នោះកើតក្នុងត្រកូលណា ត្រកូលណាមានចិត្តបង្អោនទៅ ដើម្បីបរិភោគភោជនាហារ

ដ៏ថ្លៃថ្លា បង្អោនទៅដើម្បីប្រើប្រាស់សំពត់ដ៏ថ្លៃថ្លា បង្អោនទៅដើម្បីប្រើប្រាស់យានដ៏ថ្លៃថ្លា បង្អោនទៅដើម្បីប្រើប្រាស់កាមគុណដ៏ថ្លៃថ្លា ម្យ៉ាងទៀត ពួកជនណាជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបម្រើក្តី កម្មកររបស់បុគ្គលនោះក្តី ជនទាំងនោះរមែងផ្ទង់ត្រចៀកស្តាប់ មិនបញ្ជូនចិត្តទៅកាន់អារម្មណ៍ដទៃឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ? ម្នាលគហបតី ព្រោះថាវិបាករបស់កម្មទាំងឡាយ ដែលបុគ្គលធ្វើដោយសេចក្តីគោរព រមែងមានយ៉ាងនេះឯង ។

ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សំដែងបន្ត ដោយទ្រង់នាំរឿងក្នុងអតីតជាតិដែលព្រះអង្គទ្រង់សោយព្រះជាតិជាវេលាមព្រាហ្មណ៍ បានពិចារណាឃើញដោយបញ្ញាថា ទ្រព្យសម្បត្តិទាំងនេះមិនមានសារៈ មិនអាចជាប់តាមខ្លួនទៅបរលោកបានឡើយ កាលអស់ជីវិតទៅហើយ ដូចបុញ្ញជនដែលលោកទៅខ្លួនទទេ កាលប្រាថ្នា និងកាន់យកសារៈអំពីវត្ថុដែលគ្មានសារៈ ទើបធ្វើមហាទាន ។

ក្នុងមហាទាននោះ វត្ថុណាមួយដែលជនទាំងឡាយ ត្រូវការឈ្មោះថាខ្វះខាតរមែងមិនមាន ដូចជាមាសប្រាក់ ដំរី សេះ គោ ស្រីក្រមុំ កែវមណី កុណ្ឌល បល្ល័ង្ក សំពត់ ខាទនីយភោជនីយាហារ ។ល។ មួយមុខ ៗ ៨៤០០ វត្ថុ ។

វេលាមព្រាហ្មណ៍ ធ្វើមហាទានដូចទឹកហូរក្នុងស្ទឹង អស់រយៈពេល

៧ ឆ្នាំ ៧ ខែ តែទាននោះមិនមានទក្ខិណេយ្យបុគ្គលដែលបរិសុទ្ធសូម្បីត្រឹមតែម្នាក់ បដិគ្គាហកៈសុទ្ធតែជាលោកិយមហាជនទាំងអស់ ។ ទើបព្រះអង្គទ្រង់ត្រាស់សំដែងផលនៃកុសលក្រៃលែងឡើងតាមលំដាប់ថា ទានដែលបុគ្គលធ្វើចំពោះអរិយបុគ្គលថ្នាក់សោតាបន្នត្រឹមតែម្នាក់ មានផលច្រើនជាងវេលាមព្រាហ្មណ៍ឱ្យហើយអស់ ៧ ឆ្នាំ ៧ ខែនោះ ។ ទានដែលបុគ្គលធ្វើហើយចំពោះសកទាគាមីម្នាក់មានផលច្រើនជាង ធ្វើហើយដល់សោតាបន្នបុគ្គល ១០០ នាក់ ទានដែលបុគ្គលថ្វាយហើយចំពោះអនាគាមីម្នាក់...... អរហន្តមួយរូប....... ព្រះបច្ចេកពុទ្ធមួយអង្គ........ ទានដែលបុគ្គលថ្វាយហើយដល់ព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ មានផលច្រើនជាងទានដែលថ្វាយចំពោះព្រះបច្ចេកពុទ្ធ ១០០ អង្គ ទានដែលថ្វាយចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រមុខមានផលច្រើនជាងថ្វាយចំពោះព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ ។ ការដែលបុគ្គលកសាងវិហារ ប្រគេនសង្ឃមកអំពីទិសទាំង ៤ មានផលច្រើនជាងទាន (និច្ចភត្ត) ដែលថ្វាយសង្ឃមានព្រះពុទ្ធជាប្រមុខ ការដែលបុគ្គលមានចិត្តជ្រះថ្លានូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈ ជាទីពឹងនោះមានផលច្រើនជាងទានដែលបុគ្គលកសាងវិហារប្រគេនព្រះសង្ឃមកអំពីទិសទាំង ៤ ការដែលបុគ្គលមានចិត្តជ្រះថ្លាចំពោះព្រះរតនៈត្រៃ ហើយសមាទានសិក្ខាបទទាំង ៥ (សីល៥) មានផលច្រើនជាងការដល់ព្រះរតនៈត្រៃជាសរណៈ ការដែលបុគ្គលចម្រើននូវមេត្តាចិត្ត (សមថភាវនា) អោយបោះពាល់សូម្បីអស់កាលត្រឹមតែមួយ

រូតទឹកដោះគោប៉ុណ្ណោះ មានផលច្រើនជាងការដែលបុគ្គលមានចិត្តជ្រះថ្លាក្នុងព្រះរតនៈត្រៃ ហើយសមាទានសិក្ខាបទទាំង ៥ ។ ទីបំផុតព្រះអង្គទ្រង់ត្រាស់សម្តែងថា : ការដែលបុគ្គលចម្រើនអនិច្ចសញ្ញា មានផលច្រើនជាងការដែលបុគ្គលចម្រើនមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរូតទឹកដោះគោនោះទៀត ។ ដូច្នេះការអប់រំចម្រើនអនិច្ចសញ្ញាជាកុសលដែលមិនមានកុសលដទៃណាប្រៀបផ្ទឹមបាន ព្រោះជាការចម្រើនបញ្ញាឱ្យឃើញច្បាស់នូវព្រះនិព្វានដែលជាធម៌រំលត់ទុក្ខទាំងពួង ។ ដូច្នេះផល ឬ អានិសង្សខ្ពស់បំផុតក្នុងព្រះពុទ្ធសាសនា ទើបមិនមែនៈ ការបាននូវបញ្ចកាមគុណ ឬ ឥដ្ឋារម្មណ៍ជារបស់ទិព្វទេ ។ តែដែលពិតនោះ គឺដើម្បីអស់ទៅនៃកិលេសដោយសមុច្ឆេទប៉ុណ្ណោះ ។

ការចម្រើនកុសលដែលមានអានិសង្សច្រើន គឺជាកុសលដែលប្រព្រឹត្តទៅដើម្បីលុះខាត់កិលេស បើលះកិលេសបានច្រើនប៉ុណ្ណោះ ផលក៏ប្រណីតតាមបំរាប់នោះ តែបើមានសេចក្តីយល់ឃើញខុសថា ធ្វើកុសលដើម្បីត្រូវការផល ក៏មិនមានផល ឬ អានិសង្សច្រើនប៉ុនគ្នានឹងកុសលដើម្បីលុះខាត់កិលេសដែរ ព្រោះជាកុសលនៅលាយឡំដោយសេចក្តីសៅហ្មង មានលោភៈ និងសេចក្តីវង្វេងជាដើម ។

សេចក្តីសំខាន់នោះ ការដែលបុគ្គលថ្វាយទានចំពោះព្រះសង្ឃសំខាន់បំផុតត្រូវស្តាប់ព្រះធម៌ ហើយធ្វើសេចក្តីគោរពកោតក្រែងក្នុងព្រះសង្ឃ កាល

បើដូច្នោះ ទានដែលបុគ្គលឱ្យហើយក្នុងសង្ឃ រមែងមានអានិសង្សច្រើនសូម្បី មិនបាច់បញ្ចេញវាចាប្រគេនក៏ដោយ ។

**២.ទាយកានំ ឧទ្ទិស្សេន** ទាយកដែលជាញាតិបានឧទ្ទិស ចំណែកបុណ្យឱ្យទាយកដែលជាអ្នកឱ្យទានតបៀតាំងចិត្តឧទ្ទិសបុណ្យកុសលចំពោះ ឈ្មោះលោកអ្នកដ៏មានគុណ មានមាតាបិតាព្រមទាំងញាតិទាំង ៧ សន្ដាន ដូចជាឈ្មោះ ក ឬ ខ ជាដើម ដើម្បីឱ្យអស់លោកទាំងនោះ មកទទួលយកចំណែកបុណ្យដែលញាតិមិត្តបងប្អូនកូនចៅបានធ្វើក្នុងឱកាសនេះ ប៉ុន្តែបើសិនជាទាយកអ្នកធ្វើទានមិនបានឧទ្ទិសចំណែកបុណ្យកុសលនោះឱ្យទេ ពពួកប្រេតដែលជាញាតិមិត្តក៏មិនអាចទទួលចំណែកបុណ្យបានដែរ លុះត្រាតែជនជាញាតិ ឬ សំឡាញ់ឧទ្ទិសឱ្យទើបទទួលបាន ។ ហើយការឧទ្ទិសនោះសោត មិនសុទ្ធតែបានទាំងអស់នោះទេ គឺមានកន្លែងដែលគួរផល់ខ្លះ មិនគួរផល់ខ្លះ ឬ ទីសមគួរ និងទីមិនសមគួរ ។

សេចក្ដីនេះ មានសម្ដែងនៅក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត ជាណុស្សោណិវគ្គ ភាគ ៥១ ទំព័រ ១៣៤ :

## រឿងជាណុស្សោណិព្រាហ្មណ៍

កាលនោះព្រះអង្គទ្រង់ត្រាស់សំដែងប្រារព្ធ ចំពោះព្រាហ្មណ៍ឈ្មោះ ជាណុស្សោណិព្រាហ្មណ៍ដែលមានសេចក្ដីដំណាលថា :

លំដាប់នោះ ជាណុស្សោណិព្រាហ្មណ៍ បានចូលទៅគាល់ព្រះដ៏មាន

ព្រះភាគ លុះចូលទៅដល់ហើយ ធ្វើសេចក្តីរីករាយជាមួយព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក នាំឱ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះជាណុស្សោណិព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគថាបពិត្រព្រះគោតមដ៏ចំរើន យើងជាព្រាហ្មណ៍តែងតែឱ្យទាន តែងធ្វើអំពើដែលគេគប្បីធ្វើដោយសទ្ធា ហើយឧទ្ទិសថា ទាននេះសូមឱ្យសំរេចផលដល់ប្រេតទាំងឡាយជាញាតិសាច់សាលោហិត ពួកប្រេតទាំងឡាយជាញាតិសាច់សាលោហិតសូមបរិភោគនូវទាននេះ បពិត្រព្រះគោតមដ៏ចំរើន ចុះទាននោះនឹងសម្រេចផលដល់ប្រេតទាំងឡាយជាញាតិសាច់សាលោហិតដែរឬទេ ? ប្រេតទាំងឡាយជាញាតិសាច់សាលោហិតនោះ នឹងបានបរិភោគនូវទាននោះបានដែរឬទេប ?

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា : ម្នាលព្រាហ្មណ៍ ទាននោះសម្រេចផលក្នុងទីគួរ មិនសម្រេចផលក្នុងទីមិនគួរ ។ បពិត្រព្រះគោតមដ៏ចំរើន ទីដែលគួរតើដូចម្តេច ? ទីដែលមិនគួរតើដូចម្តេច ? ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកច្រើនដោយអភិជ្ឈាមានចិត្តព្យាបាទ មានសេចក្តីយល់ឃើញខុស បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅក៏ទៅកើតក្នុងនរក អាហារណាដែលជាអាហារសំរាប់សត្វទាំងឡាយក្

ក្នុងនរក សត្វនរកនោះតែងតែញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងនរកនោះដោយអាហារនោះ សត្វនរកដែលស្ថិតនៅក្នុងទីណា ទីនោះឯងហៅថាទីមិនគួរ ។ ម្នាលព្រាហ្មណ៍ មួយទៀតបុគ្គលខ្លះក្នុងលោកនេះជាអ្នកសម្លាប់សត្វ......។ល។ មានសេចក្តីយល់ឃើញខុស បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅក៏ទៅកើតក្នុងកំណើតនៃសត្វតិរច្ឆាននោះ ក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ សត្វតិរច្ឆាននោះស្ថិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលរបស់សត្វដែលស្ថិតនៅក្នុងទីណា ទីនោះហៅថាទីមិនគួរ ។ ម្នាលព្រាហ្មណ៍ ចំណែកឯបុគ្គលខ្លះក្នុងលោកនេះជាអ្នកវៀរស្រឡះចាកបាណាតិបាត ចាកអទិន្នាទាន ចាកមុសាវាទ ចាកបិសុណាវាចា ចាកផរុសវាចា ចាកសម្ផប្បលាបៈ ជាអ្នកមិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវ បុគ្គលនោះលុះបែកធ្លាយរាងកាយទៅក៏ទៅកើតក្នុងពួកមនុស្ស អាហារណាជាអាហារសម្រាប់ពួកមនុស្ស បុគ្គលនោះក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយអាហារនោះ បុគ្គលនោះឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលរបស់សត្វដែលឋិតនៅក្នុងទីណា ទីនោះឯងហៅថាទីមិនគួរ ។ ម្នាលព្រាហ្មណ៍ មួយទៀតបុគ្គលខ្លះក្នុងលោកនេះ ជាអ្នកវៀរចាកស្រឡះចាកបាណាតិបាត.........។ល។ មានសេចក្តីត្រូវការ បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅក៏ទៅកើតក្នុងពួកទេវតា អាហារណាជាអាហារសម្រាប់

ពួកទេវតា ទេវតានោះញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះមិនសម្រេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនោះឯងហៅថាទីមិនគួរ ។ ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះជាអ្នកសម្លាប់សត្វលួចទ្រព្យគេ.....។ល។ មានសេចក្តីយល់ឃើញខុស បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅក៏ទៅកើតជាបិត្តិវិស័យ អាហារណាជាអាហារសំរាប់សត្វទាំងឡាយដែលកើតក្នុង បិត្តិវិស័យប្រេតនោះ ក៏ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយសារអាហារនោះ ប្រេតនោះឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ឬ ពួកមិត្តអាមាត្យក្តី ញាតិសាលោហិតក្តី ឧទ្ទិសឱ្យនូវទានណាដល់ប្រេតនោះ អំពីលោកនេះ ប្រេតនោះក៏ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងទីនោះ ដោយសារអាហារនោះ ប្រេតនោះឋិតនៅក្នុងទីនោះ ដោយសារអាហារនោះ ម្នាលព្រាហ្មណ៍ ទាននោះសំរេចផលដល់សត្វដែលឋិតនៅក្នុងទីណា ទីនោះឯងហៅថាទីគួរ ។ ជាណុស្សោ-ណិព្រាហ្មណ៍ ក្រាបទូលសួរថា បពិត្រព្រះគោតមដ៏ចំរើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ តើអ្នកណាបរិភោគទាននោះ ? បពិព្រាហ្មណ៍ ពួកប្រេតដែលជាញាតិសាលោហិតដទៃទៀតរបស់អ្នកគេ ជាប់ទៅកើតក្នុងទីនោះមិនខាន ប្រេតទាំងនោះឯងបរិភោគទាននោះ ។ បពិត្រព្រះគោតមដ៏ចំរើន ចុះប្រសិនបើប្រេតជាញាតិសាលោហិតនោះ មិនបានទៅកើតក្នុងទីនោះទេ ទាំងពួកប្រេតជាញាតិសាលោហិត

ដទៃទៀតរបស់ពួកគេ ក៏មិនបានទៅកើតក្នុងទីនោះដែរ តើអ្នកណាបរិភោគទាននោះ ។ នែព្រាហ្មណ៍ ទីណាដែលស្លាប់ចាកប្រេតទាំងឡាយជាញាតិសាលោហិត ដោយកាលជាយូរអង្វែងនេះ ទីនោះមិនមែនជាហេតុ មិនមែនជាឱកាស គឺថាមិនធ្លាប់មានឡើយ ។ ម្នាលព្រាហ្មណ៍ មួយទៀត ធម្មតាអ្នកឱ្យទាន មិនមែនជាអ្នកគ្មានផលទេ ។....ទីបំផុតជាណុស្សោណិព្រាហ្មណ៍ក៏បានប្រកាសខ្លួនថាជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិតក្នុងទីចំពោះព្រះភ័ក្ត្រព្រះដ៏មានព្រះភាគ ។

ទានដែលបុគ្គលបានធ្វើហើយ ដើម្បីឧទ្ទិសនូវកុសលដល់ពួកញាតិទាំងឡាយ ប៉ុន្តែពួកញាតិទាំងឡាយនោះពុំបានទទួលយកនូវអំណោយ គឺបុណ្យកុសលនោះទេ ទាយកអ្នកឱ្យទានមិនមែនជាឥតប្រយោជន៍ទេ គឺកុសលផលបុណ្យនោះ រមែងត្រឡប់មកម្ចាស់ដើមវិញមិនខានឡើយ ។

**៣.បេតានំ អត្តនោ អនុមោទនេន** ប្រេតមកអនុមោទនាដោយខ្លួនឯង ពិតប្រាកដណាស់ពុទ្ធបរិស័ទទាំងឡាយ បុគ្គលដែលបានស្លាប់ទៅហើយ ដោយបានដឹងបានឮនូវដំណឹងថា ញាតិមិត្តគេបានធ្វើបុណ្យកុសលឧទ្ទិសទៅឱ្យ សូមពួកញាតិអនុមោទនាយកនូវបុណ្យកុសលដែលយើងបានធ្វើឱ្យនេះចុះ ប៉ុន្តែប្រសិនជាពួកញាតិដែលយកកំណើតជាប្រេតវិស័យនោះបែរជាមិនចេះអនុមោទនាទេ ព្រាកដជាមិនអាចសំរេចផលបានឡើយ ។

ហេតុដូច្នេះហើយ បុគ្គលគ្រប់រូបគប្បីរៀនត្រេកអរ រៀនអនុមោទនា

នឹងបុណ្យកុសលឱ្យបានច្រើនទុកក្នុងខន្ធសន្តាន ព្រោះនេះជាទីពឹងរបស់ខ្លួនដូច ជាពុទ្ធភាសិតបានពោលទុកថា :

**អត្តា ហិ អត្តនោ នាថោ** ខ្លួនជាទីពឹងរបស់ខ្លួនឯង ។ បើសិនជាយើងគ្រប់រូបគ្រប់អង្គចេះអនុមោទនាវិញ នឹងជួយខ្លួនឯងបានសមដូច ជាព្រះអដ្ឋកថាចារ្យ លោកសំដែងទុកក្នុងបិដ្ឋធីពលិកបេតវត្ថុថា :

**អយញ្ហិ តត្ថ ធម្មតា យំ បេតេ ឧទ្ទិស ទានេ ទិន្នេ បេតា ចេ អនុមោទន្តិ តាវទេវ តស្ស ផលេន បេតា ភុញ្ជន្តិ** ប្រែថា ទានដែលទាយកឧទ្ទិសចំពោះអ្នកស្លាប់ទៅ (ប្រេត) ប្រសិនបើអ្នកស្លាប់ទៅ បានអនុមោទនារីករាយ អ្នកស្លាប់ទៅ រមែងបានសោយផលក្នុងខណៈនោះភ្លាមៗ ដោយផលនៃទក្ខិណាទាននោះ នេះជាធម្មតាក្នុងកិច្ចឧទ្ទិសចំពោះអ្នកស្លាប់ទៅ (ប្រេត) ។ ប៉ុន្តែបើទាយកជា អ្នកធ្វើបុណ្យទក្ខិណានុប្បទាន ប្រាសចាកអង្គទាំងបីនេះណាមួយហើយ ព្រោះជាមិនបានសំរេចផលដល់ប្រេតជាញាតិសាលោហិតបានឡើយ ទាល់តែធ្វើ ប្រកបដោយអង្គទាំងបីនេះឱ្យបានគ្រប់គ្រាន់ ទើបអាចសំរេចបានជាប្រយោជន៍ ដល់ប្រេតញាតិបាន ដូចមាននិទានមួយដែលមានសំដែងទុកក្នុងបេតវត្ថុ ខុទ្ទក និកាយអដ្ឋកថា ថា :

# រឿងភិក្ខុជាញាតិនឹងប្រេត

កាលកន្លងទៅហើយ ក្នុងក្រុងពារាណសី មានព្រះរាជាមួយព្រះអង្គ ព្រះនាមកិត្តវាស សោយរាជ្យក្នុងនគរនោះ មានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមបទុម្មកុមារ ។ ព្រះរាជបុត្រអង្គនោះ បានមើលងាយព្រះបច្ចេកពុទ្ធមួយព្រះអង្គ ដោយប្រកាន់មានះឱ្យព្រះបច្ចេកពុទ្ធថ្វាយបង្គំខ្លួន ក៏ឈោធចុះពីលើខ្នងដំរីទៅកញ្ឆក់យកបាត្រពីព្រះបច្ចេកពុទ្ធដែលកំពុងនិមន្តបិណ្ឌបាត្រ បោកបំបែកជាន់កំទេចចោល ធ្វើឱ្យលោកអត់ចង្ហាន់ ។ ព្រះបច្ចេកពុទ្ធក៏និមន្តទៅកាន់ញកភ្នំនន្ទមូលវិញ ។ រឿងនេះសង្ខេបតែប៉ុណ្ណេះ ដល់ព្រះរាជកុមារនោះទីវង្គតទៅ ក៏ធ្លាក់ទៅកើតក្នុងអវិចីមហានរករស់ ៨៤០០០ ឆ្នាំ ដល់អស់ផលកម្ម មកកើតជាប្រេតអត់ឃ្លាន ។ ដល់មកសម័យពុទ្ធកាលនេះ បានមកកើតនាត្រកូលអ្នកនេសាទម្នាក់នៅអាណាខេត្តក្រុងសាវត្ថី ឈ្មោះហិរិកកុមារ ជាបុគ្គលរលឹកជាតិបាន ។ កុមារនេះតាំងពីដឹងក្តីឡើងកាលណា រលឹកឃើញសេចក្តីទុក្ខដែលខ្លួនបានកើតក្នុងនរកប្រេត ក៏កើតសេចក្តីខ្លាចបាបជាទីបំផុត ។ ក្នុងគ្រួសារហិរិកកុមារ មានមុខរបរតែមួយ គឺរបរនេសាទត្រីរាល់តែថ្ងៃមាតាបិតា និងបងៗ នាំកុមារទៅដាក់លប ដាក់លោយ ចងសន្ទូចបង់សំណាញ់ជាដើម ។ កុមារចេះលបចាប់ត្រីរស់ៗបោះចោលទៅក្នុងទឹកហើយចេះតែនិយាយថាបាបៗ ទោះបីមាតាបិតាបងៗ ជេរស្តីវាយដូចម្តេចក្តីក៏នៅតែធ្វើដូច្នោះទៀត ។ បើមុកឱ្យនៅផ្ទះលួចដុតលបលោយចោលអស់ ។

មាតាបិតាខឹងខ្លាំង ក៏បណ្ដេញចេញពីផ្ទះ ឈប់ឱ្យនៅជាមួយ ។ កុមារក៏ចេញពីផ្ទះដើរតាមផ្លូវទៅ ឯប្រុសមានសេចក្ដីអាណិតយំសោកអង្វរមាតាបិតាឱ្យហៅមកវិញ តែមាតាបិតាមិនព្រម ។ លុះកុមារដើរឆ្ងាយផុតពីភូមិទៅបានជួបនឹងព្រះអានន្ទកំពុងបិណ្ឌបាត្រ ក៏ចេះតែដើរតាមដរាបដល់វត្ត ។ លោកសួរដឹងថា មាតាបិតាលះបង់ចោលហើយ ក៏បំបួសជាសាមណេរតាមសេចក្ដីសុំរបស់កុមារនោះ ។ ដល់បួសហើយ ទៅបិណ្ឌបាត្រមិនបានសោះ ដោយផលបាបកាលកើតជាខ្ញុំកុមារវាយបំបែកបាត្រព្រះបច្ចេកពុទ្ធនោះឯង ។ ថ្ងៃមួយព្រះអានន្ទនាំទៅថ្វាយបង្គំព្រះសម្ពុទ្ធ ព្រះអង្គទ្រង់ជ្រាបនូវកម្មពៀរហើយ ដោយប្រាប់ឱ្យដងទឹកប្រគេនភិក្ខុសង្ឃឆាន់ស្រង់រាល់ៗថ្ងៃ ពួកភិក្ខុមានសេចក្ដីអាណិត ក៏ឱ្យបាយចំណីតាំងពីពេលនោះមក ។ ដល់អាយុបាន ២០ ឆ្នាំ ព្រះអានន្ទឱ្យឧបសម្បទាជាភិក្ខុ មិនយូប៉ុន្មានក៏បានសម្រេចអរហត្តផលជាព្រះអរហន្តមួយក្នុងលោក ។

កាលជាខាងក្រោយមក លោកបាននាំភិក្ខុ ១២ រូបទៅធ្វើសមណៈធម៌លើកំពូលភ្នំសានុវាសី ។ ឯមាតាបិតាបងប្អូនគ្រួសាររបស់លោក ដល់អស់អាយុទៅបានកើតជាប្រេត អត់ឃ្លាននៅចន្លោះភ្នំនោះ មានមាត់តូចប៉ុនរន្ធម្ជុល កើតបំពៅស្អុយរលួយពេញខ្លួន មានសេចក្ដីស្រេកឃ្លានជាខ្លាំង ផឹកទឹកស៊ីបាយមិនកើត ដោយអំណាចនៃទោសបាណាតិបាត និងសេចក្ដីកំណាញ់ដែលរារាំងដែលធ្វើបុណ្យទាន ។ ពួកប្រេតទាំងនោះដឹងថា ហរិកភិក្ខុនៅលើ

កំពូលភ្នំសានុវាសីនោះត្រូវជាកូន ជាប្អូនជាបងរបស់ខ្លួនពីជាតិមុន ដល់វេលាលោកនិមន្តចុះបិណ្ឌបាត្រ ក៏ឈរបង្ហាញខ្លួនដល់លោក ប៉ុន្តែផលកម្មដែលបណ្ដេញលោកមិនឱ្យនៅជាមួយកាលលោកនៅជាកុមារនោះ បណ្ដាលបិទបាំងមិនឱ្យលោកឃើញ ឬ គិតនឹកដល់ឡើយ ។

ថ្ងៃមួយប្រេតជាបងប្រុស ដែលយំសោកអង្វរមាតាបិតា កាលដែលមាតាបិតាបណ្ដេញលោក ត្រូវបានជួបនឹងលោក ហើយយំសោករៀបរាប់ប្រាប់ថា មាតាបិតាគ្រួសារទាំងអស់ ស្លាប់ទៅកើតជាប្រេតអត់ឃ្លានវេទនាណាស់ មានមាត់តូចប៉ុនក្លិតម្ជុល ។ លោកឮដូច្នោះហើយមានសេចក្ដីសង្វេគអាណិតអាសូរពន់ពេក ទើបលោកធ្វើទានចំពោះសង្ឃ ឧទ្ទិសផលឱ្យដល់ប្រេតទាំងនោះ ផលនោះក៏បានត្រឹមតែប្រេតជាបងប្រុសមួយប៉ុណ្ណោះ ។ ដល់ពេលខាងក្រោយមក ទើបបានសំរេចដល់ប្រេតជាមាតាបិតា និងប្រេតជាញាតិដទៃទៀត ។ ប្រេតទាំងនោះក៏បានក្លាយខ្លួនជារុក្ខទេវតាក្នុងពេលនោះរោង ដោយអំណាចទានដែលហិរិកភិក្ខុជាព្រះអរហន្តឧទ្ទិសឱ្យ ។

ហិរិកភិក្ខុ និងភិក្ខុទាំង ១២ អង្គ នាំគ្នាទៅក្រាបទូលព្រះដ៏មានព្រះភាគអំពីរឿងប្រេតនោះ ព្រះដ៏មានព្រះភាគទ្រង់ប្រជុំបរិស័ទ ហើយសំដែងធម្មទេសនាប្រារព្ធរឿងប្រេតនោះ ដល់ទីបំផុតទ្រង់ប្រកាសអរិយសច្ចធម៌ ៤ ប្រការ មនុស្ស និងទេវតាទាំងឡាយដែលបានស្ដាប់ ក៏បានសម្រេចមគ្គផលតាមនិស្ស័យរៀងខ្លួន ។

រឿងនេះចង់បញ្ជាក់ឱ្យឃើញថា បុគ្គលដែលធ្វើទានដើម្បីប្រយោជន៍ដល់ញាតិទាំងឡាយនោះ គឺមិនអាចប្រាសចាកអង្គណាមួយបានឡើយ ទាល់តែធ្វើទានប្រកបដោយអង្គទាំង ៣ ប្រការនេះ ទើបសម្រេចដល់ពពួកញាតិបាន ។ ហេតុនេះហើយ បុគ្គលជាញាតិគប្បីបំពេញបុណ្យកុសលឱ្យបានញឹកញាប់ និងជារឿយៗ ទោះការឱ្យទានក្តី រក្សាសីលក្តី ចំរើនមេត្តាភាវនាក្តី សុទ្ធតែជាការចំរើនរោយកុសលជានិច្ច ព្រោះថាបុគ្គលបានធ្វើបុណ្យជាញឹកញាប់នោះ រមែងខ្ជះខ្ជាននូវអំពើបាបទាំងឡាយ ការធ្វើបុណ្យជាទីនាំមកនូវសេចក្តីសុខដល់ខ្លួន ដូចជាពុទ្ធភាសិតបានពោលថា : **សុខោ បុញ្ញស្ស ឧច្ចយោ** ការសន្សំបុណ្យរមែងនាំមកនូវសេចក្តីសុខ ។

## បុណ្យខ្មោច

មនុស្សសត្វទាំងអស់នៅក្នុងលោក ដែលមានកម្មនាំឱ្យកើតឡើងសុទ្ធតែបានទទួលនូវផលវិបាកនៃកម្មនោះគ្រប់ៗគ្នា បុគ្គលខ្លះបានផលជាសុខក៏ត្រេកអរសប្បាយចិត្តនឹងផលនៃកម្មដែលខ្លួនបានទទួលនោះ មានបុគ្គលខ្លះរហូតពោលសរសើរអំពីបុណ្យវាសនារបស់ខ្លួនទៀតផង ក៏ដោយសារសេចក្តីទុក្ខមិនទាន់ឱ្យផល ។ តែបុគ្គលខ្លះ មិនដូច្នោះឡើយ បែរជារងសេចក្តីទុក្ខវេទនាវែកធ្ងន់ ហើយពោលត្អូញត្អែររៀបរាប់ប្រាប់អ្នកដទៃថា តើពីជាតិមុនខ្ញុំបានធ្វើកម្មអ្វី ? បានជាជាតិនេះ មានសេចក្តីទុក្ខច្រើនខុសគេ ។ ជួនកាលអ្នកខ្លះ

ដោយសារតែស៊ូទ្រាំនឹងសេចក្ដីទុក្ខនោះមិនបាន រហូតឈានដល់ការសម្លាប់ខ្លួនឯងទៀតផងក៏សឹងតែមាន ដោយសារអ្វី ? គឺដោយសារសេចក្ដីទុក្ខហ្នឹងឯង ។ សេចក្ដីទុក្ខនេះ បើសម្ដែងទៅមានច្រើនណាស់ តែសូមសម្ដែងសង្ខេប **មាន ៤ គងធំ ៗ គឺ :**

**១.ជាតិទុក្ខ** ទុក្ខព្រោះកើត

**២.ជរាទុក្ខ** ទុក្ខព្រោះចាស់

**៣.ព្យាធិទុក្ខ** ទុក្ខព្រោះឈឺ

**៤.មរណទុក្ខ** ទុក្ខព្រោះស្លាប់

**១.ជាតិទុក្ខ** ទុក្ខព្រោះកើត "**ជាតិ** (ជន-ជា+តិ) ប្រែថា កិរិយាកើត,ការកើត,កំណើត" ។ **ទុក្ខ** (ទុ+ខម+រ) ប្រែថា (ធម្មជាតិ) ដែលជនអត់ទ្រាំបានដោយក្រ ឬ កិរិយាអត់ទ្រាំបានដោយក្រ, សេចក្ដីព្រួយ, សេចក្ដីលំបាក ។ ទុក្ខព្រោះមានកំណើតកើតមកជារូបរាងកាយ គ្រាន់តែឈឺ ពាក្យថា ទុក្ខនេះមនុស្សយើងមិនសប្បាយចិត្តទៅហើយ ចុះបើទំរាំផ្ដាច់ប្រទះទុក្ខទៅវិញ តើទៅជាយ៉ាងណា ? ព្រោះជាពិបាកទ្រាំណាស់ លុះតែបុគ្គលនោះធ្លាប់មានការអប់រំបង្ហឹកចិត្តបានច្រើន ពិចារណាបានច្រើន ហើយរចេះទប់ ចេះរារាំងចិត្តឱ្យត្រឹមត្រូវក្នុងខណៈដែលលោកធម៌ទាំង ៨ កើតឡើង ។ ការល[illegible]យ លំបាកចិត្ត មានកម្ពស់ផ្សេងៗជាច្រើន

ទៀតក៏ដោយសារមានកំណើតនេះដែរ ។

## កំណើត ៤ យ៉ាង គឺ :

**១.អណ្ឌជ** កំណើតដែលកើតក្នុងស៊ុតពង

**២.ជលម្ពុជ** កំណើតដែលកើតក្នុងគភ៌

**៣.សំសេទជ** កំណើតដែលកើតអំពីញើសក្អែល

**៤.ឧបបាតិក** កំណើតដែលកើតឡើងឯង

## អធិប្បាយថា

**១.អណ្ឌជ** កំណើតដែលកើតក្នុងស៊ុតពង កំណើតនោះគឺជាកំណើតនៃសត្វតិរច្ឆានមានមាន់ជាដើម ជាសត្វមានកំណើតពីរដង គឺកើតក្នុងស៊ុតឋិតនៅក្នុងផ្ទៃនៃមេវាមួយដង លុះដល់ស៊ុតវាចាស់គ្រប់កំណត់ថ្ងៃហើយ មេវាសម្រាលចេញមកខាងក្រៅ ហើយក្រាបក្រុងអប់ឃុំស៊ុតវាឱ្យក្តៅផ្សាយទៅសព្វ ដរាបដល់រូបកូនមាន់នោះ កើតរូបទាំងអស់មានចំពុះសករូបជាដើម កើតឡើងពេញបរិបូណ៌ហើយ ទើបវាចឹកសម្បកស៊ុតនោះចេញខាងក្រៅមួយដង បានឈ្មោះថា **អណ្ឌជ** កំណើតដោយពិត ។

**២.ជលម្ពុជ** កំណើតដែលកើតក្នុងគភ៌ កំណើតនោះគឺកំណើតសត្វទាំងឡាយមានជាតិមនុស្សជាដើម ដូចមានសេចក្តីអធិប្បាយក្នុងដីកា និងយោងតាព្រះអភិធម្មត្ថសង្គហៈថា លំអងចូលឃ្លាំងល្អិតឬក្រដែលរបស់ជាតិភព

កើតអំពីទឹកដ៏ថ្លាស្អាត ដោយសេចក្តីឧបមាថា ត្រូវយកសក់របស់មនុស្សក្នុងជម្ពូទ្វីប ១ សរសៃមកច្រៀកជា ៨ ចំណៀក ហើយចោល ៧ ចំណៀកចេញ យកតែមួយចំណៀកយ៉ាងល្អិតតូចឆ្មារបំផុតបានប៉ុនសក់របស់មនុស្សក្នុងឧត្តរកុរុទ្វីប ១ សរសៃយ៉ាងល្អិតតូចឆ្មារបំផុតនោះ មកច្រៀកជា ៨ ចំណៀកទៀត ហើយចោល ៧ ចំណៀកចេញ យកតែមួយចំណៀកមកជ្រលក់នឹងប្រេងល្ងដ៏ថ្លាស្អាត ហើយលើកឡើងនៅសល់ជាតិប្រេងល្ងជាប់នឹង ចំណៀកសក់ប៉ុន្មាន ក៏ពាក្យដែលបណ្ឌិតពោលឱ្យឈ្មោះថា កលលរូបនោះមានចំនួនយ៉ាងតិចដ៏ថ្លាស្អាតយ៉ាងនោះឯង ។

ឯរូបដែលកើតឡើងដោយកុសលកម្ម និងអកុសលកម្មនោះក៏កើតឡើងព្រមជាមួយនឹងបដិសន្ធិចិត្តជាដំបូង ដូចមានសេចក្តីអធិប្បាយថា សប្តាហ៍ទី ១ កើតជាកលលរូប ចំរើនបន្តិចៗឡើងអស់វារៈ ៧ ថ្ងៃ, សប្តាហ៍ទី ២ កើតជាអព្វុទរូប ជារូបដែលមានពណ៌សម្បុរក្រហមស្រពោនៗដូចតំណក់ទឹកដែលបុគ្គលលាងសាច់ប្រឡាក់ដោយឈាម ហើយស្រក់ចុះមក, សប្តាហ៍ទី ៣ កើតជាបេសិរូប ជារូបមានសណ្ឋានដូចដុំសាច់ដែលបុគ្គលហាន់កាត់ដាច់ជាដុំៗ, សប្តាហ៍ទី ៤ កើតជាឃនរូប ជារូបដែលមានសណ្ឋានដូចសាច់ស៊ុតក្នុងស៊ុតមាន់ដ៏ក្រហមមូលទ្រវង់ទ្រវែងបន្តិច, សប្តាហ៍ទី ៥ កើតជាបសាទរូបយ៉ាងល្អិតជាខាងក្នុងទាំងប្រាំ គឺចក្ខុប្បសាទ ១ សោតប្បសាទ ១ ឃាន-ប្បសាទ ១ ជិវ្ហាប្បសាទ ១ កាយប្បសាទ ១, សប្តាហ៍ទី ៦ កើតជា

សាខារូប ដ៏ស្រដៀងជាមែកឈើខាងក្នុងយ៉ាងល្អិតទាំងប្រាំ គឺសក់ ១ រោម ១ ក្រចក ១ ធ្មេញ ១ ស្បែក ១ ក៏ក្នុងរវាងសប្តាហ៍ទី ១ មកដល់សប្តាហ៍ទី ៦ នេះរាប់បញ្ចូលក្នុងបដិសន្ធិកាល កំណត់ ៤២ ថ្ងៃកើតពាង តែបសាទរូបយ៉ាងល្អិតទាំងប្រាំ និងសាខារូបយ៉ាងល្អិតទាំងប្រាំប៉ុណ្ណោះឯង ។ សប្តាហ៍ទី ៧ កើតជាចក្ខុទសករូប គឺរូបមានចក្ខុជាគំរប់ដប់ ១ សប្តាហ៍ទី ៨ កើតជាសោតទសករូប គឺរូបមានសោតជាគំរប់ដប់ ១ សប្តាហ៍ទី ៩ កើតជាឃានទសករូប គឺរូបមានឃានរូបជាគំរប់ដប់ ១ សប្តាហ៍ទី ១០ កើតជាជិវ្ហាទសករូប គឺរូបមានជិវ្ហារូបជាគំរប់ដប់ ១ សប្តាហ៍ទី ១១ កើតជាកាយទសករូប គឺរូបមានកាយរូបជាគំរប់ដប់ ១ សប្តាហ៍ទី ១២ កើតជាភាវទសករូប គឺឥត្ថីភាវរូបទសកៈ រូបមានភាពស្រីជាគំរប់ដប់ ឬ បុមភាវទសកៈ រូបមានភាពប្រុសជាគំរប់ដប់ ១ សប្តាហ៍ទី ១៣ កើតជាវត្ថុទសករូប គឺរូបមានហទយរូបជាគំរប់ដប់ ១ សប្តាហ៍ទី ១៤ កើតជាជីវិតនវករូប គឺរូបមានជីវិតជាគំរប់ប្រាំបួន ១ ក៏ក្នុងសប្តាហ៍ទាំង ៨ តាំងពីសប្តាហ៍ទី ៧ មកដល់សប្តាហ៍ទី ១៤ កើតជារូប ៨៩ ដោយរាប់បញ្ចូលគ្នាទាំងរូបស្រីរូបប្រុស បើរាប់រូបស្រី និងប្រុសញែកដាច់ចេញពីគ្នា កើតបានតែរូប ៧៩ រូបនេះ បានឈ្មោះថា កម្មសមុដ្ឋានកលាបៈជាសំណុំរូបកើតឡើងព្រមដោយកម្លាំងនៃកុសលកម្ម និងអកុសលកម្មតាក់តែងឱ្យកើតឡើងក្នុងបវត្តិកាលកំណត់ ៥៦ ថ្ងៃនេះ ។ សប្តាហ៍ទី ១៥ កើតជា

សុទ្ធដ្ឋករូប គឺរូបមានឱជារូបគំរប់ ៨ សុទ្ធ ១, សត្តាហ៍ទី ១៦ កើតជាកាយវិញ្ញត្តិនវករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានកាយវិញ្ញត្តិរូបជាគំរប់ ៩ មួយ, សត្តាហ៍ទី ១៧ កើតជាវចីវិញ្ញត្តិទសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានវចីវិញ្ញត្តិរូប និងសទ្ទរូបជាគំរប់មួយ ១ សត្តាហ៍ទី ១៨ កើតជាឯកាទសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានវិការរូប៣ជាគំរប់ ១១ មួយ សត្តាហ៍ទី ១៩ កើតជាទ្វាទសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានកាយវិញ្ញត្តិរូប ១ និងវិការរូប ៣ ជាគំរប់ ១២ មួយ, សត្តាហ៍ទី ២០ កើតជាតេរសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានវចីវិញ្ញត្តិរូប ១ សទ្ទរូប ១ វិការរូប ៣ ជាគំរប់ ១៣ មួយ ក្នុងសត្តាហ៍ទាំង ៦ នោះកើតជារូប ៦៣ រូបគត់ បានឈ្មោះថា ចិត្តសមុដ្ឋានកលាបៈ សំណុំរូបកើតឡើងព្រមដោយកម្លាំងនៃចិត្តតាក់តែងកើតឡើងក្នុងបវត្តិកាលកំណត់ ៤២ ថ្ងៃគត់។

សត្តាហ៍ទី ២១ កើតជាសុទ្ធដ្ឋករូបទាំង ៨ សុទ្ធចំរើនឡើងមួយ សត្តាហ៍ទី ២២ កើតជាសុទ្ធនវករូប គឺអដ្ឋរូបទាំង ៨ សុទ្ធ មានសទ្ទរូបជាគំរប់ ៩ មួយ, សត្តាហ៍ទី ២៣ កើតជាឯកាទសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានវិការរូប ៣ ជាគំរប់ ១១ មួយ សត្តាហ៍ទី ២៤ កើតជាទ្វាទសករូប គឺរូបអដ្ឋករូបទាំង ៨ សុទ្ធ មានសទ្ទរូប និងវិការរូប ៣ ជាគំរប់ ១២ មួយ ក្នុងសត្តាហ៍ទាំង ៤ នេះ កើតជារូប ៤០ គត់ បានឈ្មោះថា ឧតុសមុដ្ឋានកលាបៈ ជាសំណុំរូបកើតឡើងព្រមដោយ

កម្លាំងនៃរដូវតាក់តែងឱ្យកើតឡើងក្នុងបវត្តិកាលកំណត់ ២៨ ថ្ងៃគត់ ។

សប្តាហ៍ទី ២៥ កើតជាសុទ្ធដ្ឋករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានបឋវីធាតុរូបជាដើម កើតពេញបរិបូណ៌ឡើង ១, សប្តាហ៍ទី ២៦ កើតជាឯកាទសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានវិការរូប ៣ ជាចំរប់ ១១ មួយ ក្នុងសប្តាហ៍ទាំង ២ នេះ កើតជារូប ១៩ គត់ បានឈ្មោះថា អាហារសមុដ្ឋានកលាប ជាសំណុំរូបកើតឡើងព្រមដោយកម្លាំងនៃអាហារតាក់តែងឱ្យកើតឡើងក្នុងបវត្តិកាលកំណត់ ១៤ ថ្ងៃគត់ ។ ទាបន័យបរមត្ថព្រះអភិធម្មនេះ ដោយសភាពពិតថា ជាតិមនុស្សទាំងឡាយដែលជាផលម្តុជកំណើត កើតបិតនៅក្នុងគភ៌នៃមាតា ដែលនឹងមានរូបកាយពេញបរិបូណ៌ប្រាកដថាជាស្ត្រី និងបុរសនោះ បើគិតក្នុងបវត្តិកាលតាំងពីសប្តាហ៍ទី ៧ មកដល់.......សប្តាហ៍ទី ២០ បានចំនួន ១៤០ ថ្ងៃគត គិតជាខែបាន ៤ ខែ និង ២០ ថ្ងៃគត់ បើគិតក្នុងបដិសន្ធិកាលតាំងពីចាប់បដិសន្ធិជាកលលៈ រូបបាន ៦ សប្តាហ៍ទៀត មានចំនួន ១៨២ ថ្ងៃ គិតជាខែបាន ៦ ខែ និង ២ ថ្ងៃគត់ ។

ឯកុមារតូចដែលស្ថិតនៅក្នុងផ្ទៃនៃមាតានោះ អង្គុយត្រពោមក្បាលជង្គង់ ដៃឱបចង្កាដាក់លើក្បាលជង្គង់ បែរមុខឈមទៅកាន់ឆ្អឹងខ្នងនៃមាតា មាតារបស់ទារកនោះ បរិភោគនូវភោជនមួយអន្លើដោយបាយ និងទឹកឯណា ទារកតូចដែលនៅផ្ទៃនៃមាតានោះ ញ៉ាំងអត្តភាពឱ្យចំរើនឡើងដោយឱជារស

នៃរោគជននោះឯង យកគ្រាំក្នុងគភ៌នៃមាតាសោយទុក្ខវេទនាជាទម្ងន់លុះដល់គភ៌ចាស់កំណត់បាន ៨,៩,១០ ខែ ទើបប្រសូតចេញមកអំពីផ្ទៃនៃមាតា ប្រកបដោយសេចក្ដីទុក្ខលំបាកយ៉ាងខ្លាំងពន់ពេកណាស់ បើកុមារតូចនៅក្នុងផ្ទៃពុំទាន់ដល់កំណត់ថ្ងៃខែទេ គភ៌នៅខ្ចី ហើយប្រសូតចេញមកអំពីផ្ទៃនៃមាតា កុមារតូចនោះច្រើនតែស្លាប់ ពុំបានរស់នៅឡើយ ។ ម្យ៉ាងទៀតសត្វទាំងឡាយដែលចាប់បដិសន្ធិក្នុងផ្ទៃមាតាហើយឋិតនៅបាននោះ លុះតែប្រកបព្រមដោយកាលទាំងពីរ គឺមាតាបិតុសន្និបាតកាល កាលដែលមាតាបិតាប្រជុំព្រមគ្នា ១ មាតុឧតុសម្បានកាល កាលដែលមាតាមានរដូវកើតឡើងព្រម ១ ទើបសត្វចាប់បដិសន្ធិបាន បើពុំទាន់ប្រកបព្រមដោយកាលទាំងពីរនេះទេ សត្វនោះនៅរង់ចាំឋិតនៅកំណត់ ៧ ថ្ងៃជាធម្មតាបានឈ្មោះថា **ជលម្ពុជ** កំណើតដោយពិត ។

៣.**សំសេទជ** កំណើតដែលកើតអំពីញើសក្អែល កំណើតនោះ គឺកំណើតសត្វទាំងឡាយ ដែលកើតដោយសភាវធម៌ ទាំងឡាយ ៤ មាន កម្មជាដើម ប្រជុំព្រមគ្នាអាស្រ័យនឹងញើសក្អែលមានប្រមាណពិចពន់ពេក មានញើសក្អែលក្នុងផ្កាឈើ និងដើមឈើ ឬ មន្ទិលគភ៌ជាដើម ហើយតាក់តែងឱ្យរូបកើតឡើង មានទឹកស្លេស្ម ឬ ទឹកមាត់របស់ខ្លួនជាអាហារ ចិញ្ចឹមរូបទាំងអស់ មានចក្ខុទសករូបជាដើម ឱ្យចំរើនធំឡើងពេញបរិបូណ៌

មួយរំពេច បានឈ្មោះថា **សំសេទជ** កំណើតដោយពិត ។

**៤.ឧបបាតិក** កំណើតដែលកើតឡើងឯង កំណើតនោះ គឺកំណើតសត្វទាំងឡាយ ដែលអាស្រ័យនឹងភពកើតឡើង ដោយសភាវធម៌ទាំងឡាយ ៤ មានកម្មជាដើមប្រជុំព្រមគ្នាតាក់តែងរូបទាំងអស់ ឱ្យកើតឡើងមួយរំពេច មានទឹកមាត់ចេញអំពីបបូរមាត់របស់ខ្លួនជាអាហារ ចំរើនរូបរ៉ា ឡើងពេញបរិបូណ៌ ហើយទ្រទ្រង់នូវគ្រឿងអលង្ការគ្រប់ប្រដាប់មួយរំពេច មានកំណើតជាទេវតាក្នុងស្ថានសួគ៌ ចាតុម្មហារាជិកាជាដើម បានឈ្មោះថា **ឧបបាតិក** កំណើតដោយពិត ។

## ជាតិទុក្ខនេះមាន ១០ យ៉ាងទៀត គឺ :

-សត្វអង្គុយសង្កត់លើអាហារចាស់ ក្បាលទូលអាហារថ្មីនៃមាតា អង្គុយច្រហោងដៃទាំងពីរឱបជង្គង់ផ្ទប់ចង្កា បែរខ្នងទៅខាងផ្ទៃមាតា បែរមុខទៅខាងឆ្អឹងខ្នងមាតា ដូចជាស្វាអង្គុយនៅក្នុងប្រហោងឈើ នៅវេលាដែលមានភ្លៀងធំនោះឯង ព្រោះសុករុំព័ទ្ធកាយរបស់ទារករឹតរួតមិនអាចសណ្ដូកលោត ដែលលាតជើងចេញបាន សោយទុក្ខវេទនានៅក្នុងឧទរប្រទេសនៃមាតាពន់ប្រមាណណាស់ ទុក្ខស្មើនឹងសត្វដែលសោយទុក្ខនៅក្នុងស្ថាននរកដ៏ងងឹតមាន ក្លិនអសុភអាប់អួនៅក្នុងផ្ទៃមាតា គួរឱ្យខ្ពើមរអើមជាទីបំផុត ទាំងតេជោធាតុមាតាដុតកំដៅក្តៅពន់ប្រមាណ បីដូចជាដុំសាច់ដែលបុគ្គលចំហុយនៅក្នុងឆ្នាំង

សត្វទាំងឡាយដែលនៅក្នុងគភ៌មាតាសោយទុក្ខជាទម្ងន់យ៉ាងនេះ ដូចផ្កាទាំងអស់ សេចក្តីទុក្ខយ៉ាងនេះឈ្មោះថា **គព្ភោក្កន្តិកមូលកទុក្ខ** ចាត់ជាជាតិទុក្ខប្រការទីមួយ ។

-បើមាតាដើរទៅហើយភ្លាត់ជួលចុះក្តី ប្រែត្រឡប់ខ្លួនក្រោកឡើងអង្គុយចុះក្តី សត្វដែលនៅក្នុងគភ៌នោះ ភ្ញាក់តក់ស្លុតរន្ធត់ខ្លាំង សោយទុក្ខខ្លាំងក្លាណាស់ ទុក្ខយ៉ាងនេះឈ្មោះថា **គព្ភបរិហារមូលកទុក្ខ** ចាត់ជាជាតិទុក្ខប្រការទីពីរ ។

-នៅក្នុងពេលសត្វដែលនៅក្នុងគភ៌មាតា យកទទឹងក្នុងផ្ទៃមាតា សម្រាលចេញមិនរួច សោយទុក្ខជាទម្ងន់ពន់ប្រមាណ ទុក្ខយ៉ាងនេះឈ្មោះថា **គព្ភវិបត្តិមូលកទុក្ខ** ចាត់ជាជាតិទុក្ខប្រការទីបី ។

-នៅពេលខ្យល់កម្មជវាត បក់ត្រឡប់សត្វក្នុងផ្ទៃឱ្យមានជើងឡើងលើ ក្បាលចុះក្រោមធ្លាក់ចុះខាងក្រោម ធ្លាក់ចុះទៅតាមទ្វារកំណើត ដូចជាបុគ្គលធ្លាក់ចុះទៅក្នុងជ្រោះភ្នំដ៏ជ្រៅពន្លឹក គួរឱ្យខ្លាចតក់ស្លុតរន្ធត់ជាខ្លាំង នៅពេលចេញពីទ្វារយោនីនោះ ក៏សែនទុក្ខលំបាកខ្លាំងណាស់ យ៉ាងនេះឈ្មោះថា **គព្ភជាយិកមូលកទុក្ខ** ចាត់ជាជាតិទុក្ខប្រការទីបួន ។

-បើទារកសម្រាលចេញពីផ្ទៃមាតាមកហើយ បុគ្គលទទួលយកទៅជំរះមន្ទិលដុះលាងឈឺផ្សា ដូចជាចាក់ដោយម្ជុល និងរូតមុខកាំបិតដែលមុត

ឈឺផ្សាសព្វសារពាង្គកាយ ទុក្ខនេះឈ្មោះថា **គព្ភនិក្ខមនមូលកទុក្ខ** ចាត់ជាជាតិទុក្ខប្រការទីប្រាំ។

-នៅពេលដែលទារកកើតចម្រើនឡើង ជួនកាលបុព្វកម្មអំពីខាងដើម ឯណានីមួយតាមមកឱ្យផលជាទុក្ខទោស ត្រូវអាជ្ញាចាប់ចងត្រូវពិន័យវាយដំ ទាត់ធាក់ ត្រូវគុកច្រវាក់ខ្នោះឃ្នាង រហូតដល់ជីវិតក៏មាន ជួនកាលសម្លាប់ខ្លួនឯងក៏សឹងមាន យ៉ាងនេះឈ្មោះថា **អត្តូបក្កមមូលកទុក្ខ** ចាត់ជាជាតិទុក្ខប្រការទីប្រាំមួយ ។

-មួយទៀតកាលបើកើតមកហើយ ត្រូវគ្រឿងសាស្ត្រាវុធអ្នកដទៃប្រហារក្តី ត្រូវធ្នូស្នាក្តី យ៉ាងនេះឈ្មោះថា **បរូបក្កមមូលកទុក្ខ** ចាត់ជាជាតិទុក្ខប្រការទីប្រាំពីរ ។

-នៅក្នុងបណ្តាទុក្ខទាំងពួងដែលកើតមានដល់បុគ្គល ដែលកើតមកក្នុងលោកសព្វសត្វគ្រប់រូប អាស្រ័យមានជាតិជាបច្ច័យ ទុកជាសត្វនរកសោយទុក្ខវេទនាផ្សេងៗ មានភ្លើងឆេះខ្លោចរំលាយនោះ ក៏ព្រោះតែមានជាតិជាបច្ច័យឱ្យបដិសន្ធិដែរ យ៉ាងនេះឈ្មោះថា **ទុក្ខ** ចាត់ជាជាតិទុក្ខប្រការទីប្រាំបី ។

-ម្យ៉ាងទៀត ទោះជាសត្វតិរច្ឆានក្តី ដែលសោយទុក្ខវេទនាលំបាកដោយបុគ្គលដទៃ បៀតបៀនមានវាយដំកាប់ចាក់សម្លាប់ ជីវិតជាដើមនោះ ក៏ព្រោះតែមានជាតិជាបច្ច័យឱ្យបដិសន្ធិ យ៉ាងនេះចាត់ជាជាតិទុក្ខប្រការទី

ប្រាំបួន ។

-មួយទៀតសត្វដែលកើតក្នុងកំណើតជាបេតវិស័យនោះក្តី ដែលទទួល តែសេចក្តីស្រេកឃ្លានទ្រាំខ្យល់ ទ្រាំកម្តៅថ្ងៃជាដើម ចាត់ជាជាតិទុក្ខប្រការ ទីដប់ ។

**២.ជរាទុក្ខ** ទុក្ខព្រោះចាស់ "**ជរ** (ជរ+អ+អា-ឥ)ធម្មជាតិ, ចាស់,គ្រាំគ្រា, **ជរា** វិគ្គហៈថា **ជរតីតិ**-ជរា ។ **ជជ្ជរិត** ដ៏ជរា ឱ្យគ្រាំគ្រាហើយ, ដែលគ្រាំគ្រាហើយព្រោះជរា ។

ឯជរាទុក្ខនោះព្រះអង្គទ្រង់ត្រាស់សំដែងថា **ភិក្ខវេ** ម្នាលភិក្ខុ ទាំងឡាយ ជរាឯណាដែលតថាគតទេសនាទុកក្នុងនិទ្ទេសវារ ជរានោះមាន សភាពដូចម្តេច ? ជរាឯណាដែលមានសភាពធ្វើឱ្យឥន្ទ្រិយគ្រាំគ្រាវិបរិតប្រែ ប្រួលទៅ មានធ្មេញបាក់, សក់ស្កូវ, ថ្ពាល់ផត, ស្បែកជ្រីវជ្រួញឈុរយារ ស្វិត, ភ្នែកងងឹត, ត្រចៀកថ្លង់ជាដើម គួរឱ្យសង្វេគរូបរាងកាយនេះ ។ ជរានេះបុគ្គលគ្រប់រូប មិនអាចនឹងមើលឃើញដោយមំសចក្ខុទេ លុះតែបុគ្គល ដែលប្រកបដោយបញ្ញាចក្ខុនោះ ទើបនឹងសម្លឹងឃើញច្បាស់ប្រាកដបាន ជរា នេះប្រៀបដូចជាភ្លើងឆេះព្រៃ ហើយរលត់ទៅ ភ្លើងនោះក៏មិនប្រាកដនៅពេល ដែលឆេះស្រាប់តែនៅតែផេះ និងធ្យូង ទើបប្រាកដដល់ជនទាំងឡាយ នេះ មានឧបមាដូចម្តេចមិញ ជរាទុក្ខនេះមិនប្រាកដដល់ជនទាំងឡាយប្លែកឯង

បុគ្គលបានឃើញនូវអ្នកឯណាដែលមានធ្មេញបាក់, សក់ស្កូវជាដើម ទើបអាចដឹងថាជរាមកដល់ប្រាកដ ពុំនោះសោតជរានោះ ដូចជាជាងតម្បាញ ដ៏ស្រីអ្នកតម្បាញនោះពួយត្រល់ទៅម្តងមួយសរសៃៗ ខាងមុខគ្រាន់តែតិចៗ ទៅខាងក្រោយគ្រាន់តែច្រើនឡើងៗ នោះមានឧបមាដូចម្តេចមិញ ជរាដែលលេបយកអាយុសត្វបន្តិចៗរាល់កាលរាល់វេលាមិនចេះឈប់ មិនចេះបង្អង់ពេលណាខណៈសោះឡើយ ក៏មានឧបមេយ្យដូច្នោះឯង ។

អធិប្បាយថា អ្នកដែលកើតមកជាមនុស្សមានអាយុខេយ្យ កំណត់ ១០០ ឆ្នាំ, លុះកន្លងថ្ងៃមួយទៅក៏ខ្វះអំពីកំណត់ ១០០ ឆ្នាំ ១ ថ្ងៃនៅតែ ៩៩ ឆ្នាំ ១១ ខែ ២៩ ថ្ងៃ, កន្លងទៅបាន ១ ខែ ក៏ខ្វះអំពី ១០០ ឆ្នាំ ១ ខែ នៅតែ ៩៩ ឆ្នាំ ១១ ខែ, លុះកន្លងទៅបាន ១ ឆ្នាំក៏ខ្វះអំពី ១០០ ឆ្នាំ នៅតែ ៩៩ ឆ្នាំ ក៏ជរាបណ្តញបំបរអាយុសត្វក្បៀងបញ្ជូលទៅរកសេចក្តីមរណៈជានិច្ចសព្វថ្ងៃសព្វរាត្រីមិនដែលដាច់ ។

មួយទៀត ជរានេះធ្វើឱ្យឥន្ទ្រិយទាំង ៦ គឺចក្ខុន្ទ្រិយជាដើម ប្រែប្រួលទៅជានិច្ច មានភ្នែកធ្លាប់ភ្លឺប្រែក្លាយទៅជាងងឹតជាឧទាហរណ៍ ។

-ឥន្ទ្រិយ ប្រែថា ភាវៈជាធំ,ឥស្សរភាព,អានុភាព,អំណាច ។ ឥន្ទ្រិយសព្ទនេះ មានន័យច្រើនយ៉ាងណាស់ គឺអាចប្រាប់ថា អ្វីដែលជាធំតាមមុខ តាមនាទីរបស់ខ្លួន ដូចជាភ្នែកជាធំក្នុងការមើលជាដើម ។ សេចក្តីអធិប្បាយមកនេះបញ្ជាក់ឱ្យឃើញអំពីទោសនៃជរាទុក្ខ កាលបើកើតមានហើយ

រូបរបស់យើងនឹងប្រែប្រួលទៅជាលំដាប់ គឺពីក្មេងឈានទៅរកចាស់ជរាដែលជាសភាពមួយមិនមាននរណាចង់បានចង់ជួបឡើយ ។

## ជរាមាន ២ យ៉ាង គឺ :

**១.បាកដជរា** ជរាប្រាកដ

**២.អបាកដជរា** ជរាមិនប្រាកដ

ឬហៅថា បដិច្ឆន្នជរា និង អប្បដិច្ឆន្នជរា ក៏មាន ។ **រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ** រូបរបស់សត្វទាំងឡាយតែងចាស់ជរា តែនាម និងគោត្ត មិនចូលដល់ការចាស់ជរាឡើយ ។

**៣.ព្យាធិទុក្ខ** ទុក្ខព្រោះឈឺ, ជម្ងឺ, ព្យាធិ ទុក្ខនេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទេសនាថា **តិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ព្យាធិដែលកើតឡើងក្នុងរូបកាយនៃសត្វទាំងឡាយ ក៏ព្រោះតែធាតុប្រែប្រួល គឺថាជួនកាលត្រជាក់ ជួនកាលក្តៅរោលរាល ធ្វើឱ្យរសាប់រសល់ ជម្ងឺឈឺចាប់នោះមានរោគគ្រុនក្តៅ, រោគឈឺក្បាលវិលមុខ, ឈឺពោះជាដើម ព្យាធិនេះបៀតបៀនសត្វឱ្យដល់នូវសេចក្តីទុក្ខវេទនាណាស់ ។ ហើយរូបកាយរបស់យើងគ្រប់គ្នាជាទីប្រជុំចុះនៃរោគគ្រប់ត្រកូលគ្រប់ប្រភេទ ដូច្នេះហើយបាននៅក្នុងគិរិមានន្ទសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា :

**ពហុទុក្ខោ ខោ អយំ កាយោ ពហុអាទីនវោតិ**

រូបរាងកាយនេះមានទុក្ខក៏ច្រើន មានទោសក៏ច្រើនពិតមែន ។

**ឥតិ ឥមស្មឹ កាយេ វិវិធា អាពាធា ឧប្បជ្ជន្តិ**

អាពាធ គឺជម្ងឺបម្កាត់ទាំងឡាយផ្សេងៗតែងតែកើតឡើងក្នុងកាយនេះ ដូច្នេះ ។

**សេយ្យថីទំ** អាពាធនោះ ដូចម្ដេច ?

**ចក្ខុរោគោ** គឺរោគក្នុងភ្នែក, **សោតរោគោ** រោគក្នុងត្រចៀក, **ឃានរោគោ** រោគក្នុងច្រមុះ, **ជិវ្ហារោគោ** រោគក្នុងអណ្ដាត, **កាយរោគោ** រោគក្នុងកាយ, **សីសរោគោ** រោគក្នុងក្បាល, **កណ្ណរោគោ** រោគខាងក្រៅត្រចៀក, **មុខរោគោ** រោគក្នុងមាត់, **ទន្តរោគោ** រោគត្រង់ធ្មេញ, **កាសោ** រោគក្អក, **សាសោ** រោគហឺត, **បិនាសោ** រោគក្ដៅច្រមុះ, **ឌហោ** រោគក្ដៅក្រហាយ, **ជរោ** រោគស្គាំស្គម, **កុច្ឆិរោគោ** រោគក្នុងផ្ទៃ, **មុច្ឆារោគោ** រោគខ្យល់ចាប់វិលមុខ, **បក្ខន្ទិកា** រោគធ្លាក់ឈាម, **សូលា** រោគចុកសៀត, **វិសូចិកា** រោគចុះរាគ, **កុដ្ឋំ** រោគឃ្លង់, **គណ្ឌោ** រោគពក, **កិលាសោ** រោគស្រែង, **សោសោ** រោគរីងរៃ, **អបមារោ** រោគឆ្កួតជ្រូក, **ទទ្ទុ** រោគដំនួចពិស, **កណ្ឌូ** រោគរមាស់,

**កច្ឆុ** រោគកមហ្រិន, **រខសា** រោគកញ្ជ្រិល, **វិតច្ឆិកា** រោគកមរលាយ, **លោហិតំ** រោគធ្លាក់ឈាម, **បិត្តំ** រោគប្រមាត់, **មធុមេហោ** រោគប្រមេះទឹកបាយ, **អំសា** រោគឫសដូងបាតជុំវិញទ្វារធំ, **បិឡកា** រោគរលកកែវ, **ភគន្ទលា** រោគឫសដូងបាតដុះខាងក្នុង (អ្នកថាពោលថា ឫសដូងបាតដែលដុះខាងក្នុងត្រង់ចន្លោះទ្វារធំនឹងទ្វារតូច) **ចិត្តសមុដ្ឋានាអាពាធា** អាពាធកើតអំពីប្រមាត់, **សេម្ហសមុដ្ឋានាអាពាធា** អាពាធកើតអំពីស្លេស្ម, **វាតសមុដ្ឋានាអាពាធា** អាពាធកើតអំពីខ្យល់, **សន្និបាតិកាអាពាធា** អាពាធកើតអំពីសន្និបាត គឺកំរើកប្រមាត់ស្លេស្ម និងខ្យល់ប្រជុំគ្នា, **ឧតុបរិណាមជាអាពាធា** អាពាធកើតអំពីរដូវប្រែប្រួល, **វិសមបរិហារជាអាពាធា** អាពាធកើតអំពីការផ្លាស់ប្ដូរឥរិយាបថមិនស្មើគ្នា, **ឧបក្កមិកាអាពាធា** អាពាធកើតអំពីសេចក្ដីព្យាយាម (របស់អ្នកឯទៀតមានចាប់ចងវាយកាប់ជាដើម) **កម្មវិបាកជាអាពាធា** អាពាធកើតអំពីវិបាករបស់កម្ម, **សីតំ** អាពាធកើតអំពីត្រជាក់, **ឧណ្ហំ** អាពាធកើតអំពីក្ដៅ, **ជិឃច្ឆា** អាពាធកើតអំពីសេចក្ដីស្រេកឃ្លាន, **បិបាសា** អាពាធកើតអំពីសេចក្ដីស្រេក, **ឧច្ចារោ** អាពាធកើតអំពីឧច្ចារៈ, **បស្សាវោ** អាពាធកើតអំពីបស្សាវៈ ។

សព្វថ្ងៃនេះមានមេរោគអេដស៍ និងមេរោគផ្សេងៗទៀត ។

**ឥតិ ឥមស្មឹ កាយេ អាទីនវានុបស្សី វិហរតិ**

ភិក្ខុពិចារណាឃើញជារឿយៗជាទោសក្នុងរូបកាយនេះ ដោយប្រការដូច្នេះថា :

រូបកាយនេះមិនត្រឹមតែជាទីប្រជុំចុះនៃរោគប៉ុណ្ណោះទេ ថែមទាំងជាទីកើតឡើងនៃសត្វដង្កូវទៀតផង ពីព្រោះនៅក្នុងវិសុទ្ធិមគ្គត្រង់មរណានុស្សតិ លោកសំដែងទុកថា :

**អយំ កាយោ ពហុសាធារណោ អសីតិយា តាវ កិមិកុលានំ សាធារណោ ។**

សេចក្តីថា រូបកាយនៃសត្វទាំងពួង ជាសាធារណៈទូទៅដល់ពួកដង្កូវទាំងឡាយ ៨០ ត្រកូល ដង្កូវដែលអាស្រ័យនូវស្បែកសម្បុរថ្ងៃ ក៏ទំពាស៊ីនូវស្បែកសម្បុរថ្ងៃ ដែលអាស្រ័យនៅក្នុងស្បែកបន្ទាប់សាច់ក៏ទំពាស៊ីនូវស្បែកបន្ទាប់សាច់ ដែលអាស្រ័យនៅសរសៃក៏ទំពាស៊ីសរសៃ ដែលអាស្រ័យនៅឆ្អឹងក៏ទំពាស៊ីឆ្អឹង ដែលអាស្រ័យនៅខួរក្នុងឆ្អឹងក៏ទំពាស៊ីខួរក្នុងឆ្អឹង ។

**ជាយន្តិ ជិយ្យន្តិ មិយ្យន្តិ ។**

ដង្កូវទាំងឡាយនោះកើតក្នុងកាយ ចាស់ក្នុងកាយ ស្លាប់ក្នុងកាយ បន្ទោបង់នូវឧច្ចារៈបស្សាវៈក្នុងកាយ ។

**កាយោ ចនេសំ សូតិឃរំចេវ គិលានសាលា ច**

## សុសានចិត្ត ខ្ទុកុដិចបស្សារខោណវិការ ២

កាយនៃយើងទាំងពួងនេះ ជាផ្ទះសម្រាប់ប្រសូតនៃសត្វដង្កូវជារោង សំរាប់ដាក់សត្វដង្កូវឈើ ជាព្រៃស្មសាន សម្រាប់ចោលសាកសពអសុភដង្កូវគួរតែសង្វេគវេទនាកាយនៃយើងគេទាំងឡាយនេះ ជួនកាលដង្កូវកំរើកជ្រួលជ្រើមឡើង ហើយក៏ដល់នូវសេចក្តីស្លាប់ ដោយដង្កូវកំរើកនោះក៏មានខាងក្នុងរាងកាយនេះនឹងមានតែពួកដង្កូវបៀតបៀនតែម្យ៉ាងក៏ទេ សឹងមានរោគច្រើនជាងរយជំពូកបៀតបៀនក្នុងកាយនេះទៀត ហើយក៏ជាទីសាធារណៈទូទៅសត្វទាំងឡាយខាងក្រៅ មានសត្វពស់ និងខ្លួយជាដើមជាបច្ច័យនៃសេចក្តីស្លាប់ រាងកាយនេះជាទីមុតត្រូវអំពីឧបទ្រវន្តរាយទាំងពួងផ្សេងៗ ។

កាយ (កុ+អាយ)ប្រែថា សភាវៈជាទីនៅនៃធម៌ប្រព្រឹត្តទៅមួយអន្លើដោយអាសវៈដែលបណ្ឌិតគួរខ្ពើម, ប្រទេសជាទីកើតនៃអាការៈមានសក់ជាដើមដែលបណ្ឌិតគួរខ្ពើម, (កាយ,សរីរៈ,ពួក,ក្រុម) ។

នៅក្នុងសុត្តន្តបិដក អង្គុត្តរនិកាយ នវកនិបាត ភាគ ៤៩ ទំព័រ ៦៩ ត្រង់សីហនាទវគ្គ :

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងប្រៀបកាយដូចជាបូសថា :

ម្នាលភិក្ខុទាំងឡាយ ដូចបូសរាប់ឆ្នាំមិនតែមួយមុខដំបៅមាន ៩ គឺ មុខដំបៅដែលមិនមានអ្នកណាទំលាយទាំង ៩ របស់បូសនោះទេ វត្ថុនីមួយៗគប្បីហូរចេញ, របស់មិនស្អាតក៏គប្បីហូរចេញ, ក្លិនអាក្រក់ក៏គប្បីផ្សាយ

ចេញ, របស់គួរខ្ពើមក៏គប្បីហូរចេញ, វត្ថុនីមួយក៏គប្បីជ្រាបចេញ, របស់មិនស្អាតក៏គប្បីជ្រាបចេញ, ក្លិនអាក្រក់ក៏គប្បីផ្សាយចេញ, របស់ដែលគួរខ្ពើមក៏គប្បីផ្សាយចេញអំពីមុខដំបៅនោះ ។ ម្នាលភិក្ខុទាំងឡាយ ពាក្យបួសនេះជាឈ្មោះរបស់កាយដែលប្រកបដោយមហាភូតរូប ៤ នេះ មានមាតាបិតាជាដែនកើត ចម្រើនដោយបាយ និងនំកុម្មាស មានសេចក្តីមិនទៀង មានកិរិយាច្រោះច្រាំ ឆក់ច្រចាច់ បែកធ្លាយវិនាសខ្ចាត់ខ្ចាយជាធម្មតា មុខដំបៅមាន ៩ គឺមុខដំបៅដែលមិនមានអ្នកណាទំលាយទាំង ៩ របស់កាយនេះទេ វត្ថុមួយតែងហូរចេញ, របស់មិនស្អាតក៏ហូរចេញ, ក្លិនអាក្រក់ក៏ហូរចេញ, របស់គួរខ្ពើមក៏ហូរចេញ, វត្ថុនីមួយក៏ជ្រាបចេញ, របស់មិនស្អាតក៏ជ្រាបចេញ, ក្លិនអាក្រក់ក៏ជ្រាបចេញ, របស់គួរខ្ពើមក៏ជ្រាបចេញអំពីមុខដំបៅនោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយគួរនឿយណាយក្នុងកាយនេះ ។

ហេតុដូច្នេះហើយ បានជានៅក្នុងព្រះគាថាធម្មបទ ត្រង់ជរាវគ្គព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងប្រារព្ធនាងឧត្តរាថេរីថា :

**បរិជិណ្ណមិទំ រូបំ រោគនិឌ្ឌំ បភង្គុណំ ភិជ្ជតិ បូតិសន្ទេហោ មរណន្តំ ហិ ជីវិតំ ។**

រូបនេះគ្រាំគ្រាទ្រុឌទ្រោមហើយ ជាទីអាស្រ័យនៅនៃរោគ ជារបស់ដែលផុយរលួយ កាយរបស់ខ្លួនជារបស់ដែលស្អុយគួរខ្ពើមរអើម នឹងបែកធ្លាយ

ព្រោះថា ជីវិតមានសេចក្តីស្លាប់នៅទីបំផុត ។

រូប (រូប+អ) ប្រែថា ធម្មជាតិតែងវិនាស, ធម្មជាតិដែលប្រែប្រួល ឬវិនាសដោយហេតុផ្សេងៗ មានក្តៅត្រជាក់ជាដើម, អ្វីៗដែលប្រាកដមើលឃើញ, (រាង,សណ្ឋាន,ទ្រង់ទ្រាយ,អង្គ,ខ្លួនប្រាណ,លំអ ។ល។) ។

**រូបមាន ២ យ៉ាង គឺ :**

**១.មហាភូតរូប** រូបដែលកើតឡើងធំ

**២.ឧបាទាយរូប** រូបដែលអាស្រ័យនឹងរូបធំ

រូបដែលប្រជុំដោយអាការៈធំៗ ព្រោងព្រាត ឬជាធម្មជាតិមាន កលមាយាច្រើនហៅថា មហាភូតរូប ។ មហាភូតរូបនេះ បានដល់ធាតុ ទាំង ៤ គឺ បឋវីធាតុ អាបោធាតុ តេជោធាតុ និង វាយោធាតុ ។

**បឋវីធាតុ** ធាតុដី (មាន ២០ មានកេសា សក់ជាដើម)

**អាបោធាតុ** ធាតុទឹក (មាន ១២ មានបិត្តំ ទឹកប្រមាត់ជាដើម)

**តេជោធាតុ** ធាតុភ្លើង (មាន ៤ មានសន្តប្បតិ្ត ធាតុភ្លើង អប់រំក្តៅស្រួលផ្សាយទៅក្នុងកាយជាប្រក្រតីជាដើម)

**វាយោធាតុ** ធាតុខ្យល់ (មាន ៦ មានឧទ្ធង្គមវាតោ ខ្យល់ បក់ពីខាងក្រោមឡើងលើជាដើម) ។

**ធាតុ** ប្រែថា សភាវៈ ឬ ធម្មជាតិទ្រទ្រង់ខ្លួនឯង ។

ធម្មជាតិឯណាដែលអាស្រ័យកាន់យកមាំ នូវមហាភូតរូបទាំង ៤ ហើយញុំាងផល គឺរូបជាខាងក្នុងខ្លះ ខាងក្រៅខ្លះ អោយកើតចំរើនច្រើនឡើងសមគួរតាមលំដាប់ ធម្មជាតិនោះឈ្មោះថា **ឧបាទាយ** ពក្ញាប់ថ្លានឹងរូបហៅថា "ឧបាទាយរូប" ។

ឧបាទាយរូបនោះ បានដល់រូបដែលអាស្រ័យនឹងមហាភូតរូប ដែលលោកចែកក្នុងអភិធម្មត្ថសង្គហៈមាន ២៤ បើរួបរួមជាពួកមាន ១០ ពួកគឺ បសាទរូប៥ ជាពួក១ គោចររូប៤ ជាពួក១ ភាវរូប២ ជាពួក១ ហទយរូប១ ជាពួក១ ជីវិតរូប១ ជាពួក១ អាហាររូប១ ជាពួក១ បរិច្ឆេទរូប១ ជាពួក១ វិញ្ញត្តិរូប២ ជាពួក១ វិការរូប៣ ជាពួក១ លក្ខណរូប៤ ជាពួក១ ។

## សេចក្តីអត្ថាធិប្បាយថា

**១.បសាទរូប៥** គឺ ចក្ខុប្បសាទ បានដល់វត្ថុសម្រេចខាងការឃើញរូប មានលក្ខណៈថ្លាស្អាតតាំងនៅកណ្តាលវង់ភ្នែក មានពណ៌ខ្មៅប្រមាណប៉ុនក្បាលចៃ ជាធម្មជាតិដូចជាកែវថ្លាអាចមើលឃើញរូបទាំងពួងបាន កាលបើចក្ខុប្បសាទពិការខូច ក៏មិនអាចមើលឃើញបានឡើយ ។ សោតប្បសាទ បានដល់វត្ថុដែលសម្រេចខាងការឮសម្លេងមានលក្ខណៈថ្លាស្អាត មានសណ្ឋានដូចវង់ចិញ្ចៀន មានពណ៌ក្រហមខ្ចីឡើងតាំងនៅក្នុងរន្ធត្រចៀក ។ ឃានប្បសាទ

បានដល់វត្ថុដែលសម្រេចខាងការធុំក្លិន មានលក្ខណៈថ្លាស្អាត មានសណ្ឋានដូចក្រចកសេះ តាំងនៅខាងក្នុងរន្ធនាសិក (ច្រមុះ) ។ ជិវ្ហាបសាទ បានដល់វត្ថុដែលសម្រេចខាងការលិទ្ធភ្លក្ស មានលក្ខណៈថ្លាស្អាត មានសណ្ឋានដូចផ្កាឧប្បល តាំងនៅពាក់កណ្តាលផ្ទាំងអណ្តាត ។ កាយប្បសាទ បានដល់វត្ថុដែលសម្រេចខាងការទទួលសម្ផស្ស គឺការប៉ះពាល់ មានលក្ខណៈថ្លាស្អាត តាំងនៅក្នុងឧបាទិន្នករូប គឺរូបដែលមានវិញ្ញាណអាស្រ័យនៅជាភារៈជ្រួតជ្រាបដូចប្រេងដែលជ្រលក់ជាប់ដោយសំឡី ។

**២.គោចររូប** បានដល់អារម្មណ៍ដែលទុកដូចជាអាហារ ចំណីរបស់បសាទរូបនោះមាន ៤ គឺ រូបជាវិស័យតភ្ជាប់នៃចក្ខុ ១ សំឡេងជាវិស័យតភ្ជាប់នៃសោតៈ ១ ក្លិនជាវិស័យតភ្ជាប់នៃឃានៈ ១ រសជាវិស័យតភ្ជាប់នៃជិវ្ហា ១ ។ ចំណែកខាងផោដ្ឋព្វជាវិស័យតភ្ជាប់នៃកាយ លោកពុំបានរាប់បញ្ចូលក្នុងគោចររូបនេះឡើយ ព្រោះកាយសង្គ្រោះចូលក្នុងរូបនោះហើយ ។

**៣.ភាវរូប** បានដល់រូបដែលកើតឡើងប្រាកដ មាន ២ យ៉ាងគឺ **ឥត្ថីភាវរូប** រូបដែលប្រាកដដោយភាពជាស្ត្រី ១ **បុរិសភាវរូប** រូបដែលប្រាកដដោយភាពជាបុរស ១ ។

**៤.ហទយរូប** បានដល់វត្ថុដែលសំរេចខាងការគិត គឺរូបបេះដូងដែលជាបន្ទប់មួយមានទឹកដក់នៅ អាចផ្តុំបញ្ញាចំហាយ បញ្ចេញសេចក្តីដឹង

សេចក្តីត្រិះរិះផ្សេងៗជាទីនាំឱ្យកើតវិញ្ញាណ និងសតិបញ្ញាដែលអាចជួយឱ្យរូបកាយមានចលនា (កំរើក) គ្រប់ឥរិយាបថទៅបាន ។

**៥.ជីវិតរូប** បានដល់ការរស់នៅដែលជាធម្មជាតិរក្សាធាតុទាំង ៤ ឱ្យមានសាមគ្គីជាមួយនឹងសហជាតធម៌ឯទៀត មានអស្សាសប្បស្សាសៈជាដើម ជាប្រយោជន៍ឱ្យរូបរស់នៅបាន ។

**៦.អាហាររូប** បានដល់អាហារមានបាយទឹកជាដើម ដែលឱជារស ជ្រួតជ្រាបផ្សព្វផ្សាយតាមសរីរាង្គកាយ អាចចិញ្ចឹម អាចជួយដល់រាងកាយ ធ្វើការឱ្យរាងកាយ ដើម្បីចំរើនរាងកាយឱ្យមានសាច់ឈាមធំធាត់មានកំលាំងឡើង ។

**៧.បរិច្ឆេទរូប** ឬ ហៅថា "អាកាសរូប" ដូច្នេះក៏បាន បានដល់ធម្មជាតិដែលបក់ផ្សាយ គឺជាខ្យល់ដ៏ល្អិតក្រៃលែង បិតនៅក្នុងរន្ធរបស់សរសៃក្នុងសាច់នៃរាងកាយ ព្រមទាំងទ្វារទាំងអស់ មានទ្វារមាត់ជាដើម ។ ធម្មជាតិនេះចាត់ជារូបបរមាណូ (ល្អិតយ៉ាងក្រៃលែង) ដែលពុំអាចមើលឃើញដោយមំសចក្ខុបានឡើយ ។

**៨.វិញ្ញត្តិរូប** បានដល់កិរិយាញាប់ញ័រ ឬ កំរើកកាយដែលអាចឈានទៅមុខ ថយក្រោយ បង់ចោល បត់ដៃជើង ងាកមុខបែរបាន ។ វិញ្ញត្តិរូបនេះ មាន ២ យ៉ាងគឺ **កាយវិញ្ញត្តិ** ការកំរើកកាយមានការ

ឈានដើរជាដើម ១ **វចីវិញ្ញត្តិ** ការកំរើកវាចាមានការបញ្ចេញសម្លេងនិយាយជាដើម ១ ។

**៩.វិការរូប** បានដល់ដំណើរប្រព្រឹត្តទៅដោយការប្រែប្រួលនៃរាងកាយ ដ៏រូបនេះមានកលមាយា ជួនកាលជួប្លេះ ជួនកាលជួប្លោះ មិនអាចឋិតនិច្ចនៅគង់ចំណាំបានឡើយ ។ វិការរូបនេះ មាន ៣ យ៉ាងគឺ **រូបលហុតា** ភាពនៃរូបស្រាលបណ្ដាលឱ្យមានសេចក្ដីខ្ចីឃ្មាតស្រួលល្អ ១ **រូបមុទុតា** ភាពនៃរូបទន់ភ្លន់ជាហេតុនាំឱ្យមានកាយចុញក្រាន់ ខ្ជិលច្រអូស ១ **រូបកម្មញ្ញតា** ភាពនៃរូបគួរដល់ការងារជាហេតុនាំឱ្យមានការប្រព្រឹត្តធ្វើការងារបានដោយងាយស្រួល ១ ។

**១០.លក្ខណរូប** បានដល់រូបដែលប្រកបដោយគ្រឿងចំណាំបានជារូបមានលក្ខណៈ គឺគ្រឿងសំគាល់ផ្សេងៗផ្ទាចំពោះរូបមួយៗ ។ លក្ខណរូបនេះមាន ៤ យ៉ាងគឺ **ឧបចយរូប** រូបដែលចំចំរើនឡើង ១, **សន្តតិរូប** រូបដែលចុះជាប់តគ្នា ១, **ជរតារូប** រូបដែលចាស់ទ្រុឌទ្រោម ១, **អនិច្ចតារូប** រូបដែលមិនទៀង ១ ។

**៤.មរណទុក្ខ** ទុក្ខព្រោះសេចក្ដីស្លាប់, មរណៈ ប្រែថា ស្លាប់, មច្ចុ ក៏ប្រែថា ស្លាប់ដែរ ប៉ុន្តែមរណៈជាធម្មាធិដ្ឋាន មច្ចុជាបុគ្គលាធិដ្ឋាន ។ សេចក្ដីស្លាប់នេះមាន ២ ក៏មាន ៣ ក៏មាន ៤ ក៏មាន ។

## ស្លាប់មាន ២ យ៉ាង គឺ :

**១.កាលមរណ** ស្លាប់ទៅតាមកាល

**២.អកាលមរណ** ស្លាប់មិនសមតាមកាល

## ស្លាប់មាន ៣ យ៉ាង គឺ :

**១.សតិមរណ** ស្លាប់សតិមុន

**២.ខណិកមរណ** ស្លាប់ ១ ខណៈចិត្ត ១ ខណៈចិត្ត

**៣.សមុច្ឆេទមរណ** ស្លាប់យ៉ាងដាច់ខាត គឺមិនកើតទៀតបានដល់ព្រះអរហន្ត, ព្រះអរិយបុគ្គល ។

## ស្លាប់មាន ៤ យ៉ាង គឺ :

**១.អាយុក្ខយមរណ** ស្លាប់ដោយអស់អាយុ

**២.កម្មក្ខយមរណ** ស្លាប់ដោយអស់កម្ម

**៣.ឧភយក្ខយមរណ** ស្លាប់ដោយអាយុ និងអស់កម្ម

**៤.ឧបច្ឆេទកកម្មនា** ស្លាប់ដោយកម្មចូលមកផ្តាច់បង់

មរណៈ ២ ប្រការ គឺ កាលមរណៈ ១ អកាលមរណៈ ១ ។ កាលមរណៈនោះ គឺស្លាប់ដោយអស់បុណ្យអស់អាយុ សត្វទាំងពួងដែលមានកុសលជាជនកម្មនាំឱ្យបដិសន្ធិក្នុង[illegible]ជាសុខ បើកុសលជាឧបត្ថម្ភកៈទ្រាំទ្រនោះ មិនបានទំនុកបំរុងរហូតទៅ បើទុកជាមានបច្ច័យ គឺអាហារដែល

ផអាយុនោះនៅមានបរិបូណ៌ក្ដី ក៏គង់មិនអាចនឹងវឌ្ឍនាការចំរើនទៅបាន នឹង ដល់នូវកិរិយាច្យុតិចាកខន្ធដាច់ជីវិតិន្ទ្រិយ ព្រោះហេតុរកកុសលឧបត្ថម្ភកៈតទៅពុំបាន មរណៈយ៉ាងនេះហៅថា បុញ្ញក្ខយមរណៈ ដ៏ស្លាប់ដោយអស់បុណ្យ ឯលោកអ្នកដីកាចារ្យចូលមកថា បុញ្ញក្ខយមរណៈ ស្លាប់ដោយអស់បុណ្យនេះ ថា ដោយសត្វដែលកើតក្នុងសម្បត្តិភព ដ៏ភពបរិបូណ៌ដោយសម្បត្តិ ថាបើ សត្វដែលកើតក្នុងវិបត្តិភព ដ៏ភពប្រកបដោយសេចក្ដីទុក្ខលំបាកដរាបដល់អស់ បាប គឺអកុសលកម្មនៃខ្លួន ហើយទើបធ្វើកាលកិរិយាចាកវិបត្តិភពនោះទៅ មរណៈយ៉ាងនេះហៅថា បាបក្ខយមរណៈ ស្លាប់ដោយអស់បាប ។

ឯអាយុក្ខយមរណៈនោះ ដ៏ស្លាប់ដោយអស់អាយុនោះ ព្រះអដ្ឋកថាលោកពោលថា សត្វដែលរកគតិសម្បត្តិ កាលសម្បត្តិ អាហារសម្បត្តិមិនបាន ដ៏មិនបានមានគតិបរិបូណ៌ដូចជាទេវតាដែលបរិបូណ៌ដោយគតិ មិនបានមានកាលដ៏បរិបូណ៌ដូចបុគ្គលក្នុងបឋមកប្បដែលបរិបូណ៌ដោយកាល មិនបានមានអាហារដ៏បរិបូណ៌ដូចជនក្នុងឧត្តរកុរុទ្វីប ដែលបរិបូណ៌ដោយអាហារ មានអាយុតិចប្រមាណ ១០០ ឆ្នាំ ដូចមនុស្សប្រុសស្រីក្នុងកាលសព្វថ្ងៃនេះក្ដី សត្វដែលបរិបូណ៌ដោយកាល និងអាហារ និងអាយុយឺនយូរច្រើនជាង ១ សែនឆ្នាំនោះក្ដី តែបណ្ដាសត្វដែលស្ថិតនៅដរាបដល់អស់អាយុហើយ ទើបធ្វើកាលកិរិយាទៅទាំងប៉ុន្មាន បានឈ្មោះថា កាលមរណៈ ដ៏ស្លាប់ក្នុងកាលដ៏គួរគប្បីស្លាប់ ។

រីឯអកាលមរណៈ គឺស្លាប់ក្នុងកាលដ៏មិនសមគួរនឹងស្លាប់ ព្រោះសត្វទាំងឡាយដែលមានខន្ធបែកធ្លាយដោយអំណាច ឧបច្ឆេទកកម្ម កម្មចូលទៅផិតផ្តាច់បង់នូវជីវិត ដូចស្តេចទុសីមាររាជ និងស្តេចកលាបុរាជជាដើម ដែលប្រទុស្តរាយផល់ខន្តីវាទីតាបស ហើយផែនដីបើកចន្លោះឱ្យធ្លាក់ចុះទៅក្នុងអវិចីនរកនោះ បានឈ្មោះថា អកាលមរណៈ ។ អកាលមរណៈ ស្លាប់ក្នុងកាលមិនគួរស្លាប់ មិនតែប៉ុណ្ណោះសត្វទាំងឡាយដែលមានបោរាណកកម្ម មានគេមកកាប់ មកវាយឱ្យស្លាប់ ដោយគ្រឿងសាស្ត្រាវុធធ្វើកាលកិរិយាទៅ ដោយសេចក្តីព្យាយាមដែលបុគ្គលដទៃ ឬ ឱ្យកើតមានអកុសលចិត្តប្រហារជីវិតនៃខ្លួន ដោយដៃខ្លួនឯងក្តី សេចក្តីស្លាប់យ៉ាងនេះក៏បានឈ្មោះថា អកាលមរណៈដែរ ក៏មរណៈទាំងពីរប្រការ គឺ កាលមរណៈ ១ និង អកាលមរណៈ ១ មានន័យដូចបានពណ៌នាមកនេះ សមគួរនឹងយកមកជាអារម្មណ៍ក្នុងកាលដែលចំរើនមរណានុស្សតិកម្មដ្ឋាននោះឯង ។ (មរណៈក្រៅពីនេះ សូមពិចារណាផងចុះ) សេចក្តីស្លាប់នេះ មិនរើសជាតិមិនរើសត្រកូល ឬថាក្មេងចាស់នោះបានឡើយ ឱ្យតែមានការកើតហើយ រីឯសេចក្តីស្លាប់ក៏ត្រូវតែមានជាប្រាកដ ។

ហេតុនេះហើយបានជានៅក្នុងសុត្តន្តបិដក ទីឃនិកាយ មហាវគ្គ ត្រង់មហាបរិនិព្វានសូត្រ ភាគ ១៦ ទំព័រ ២៥៦ ថា :

**ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយនា ។**

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងតែមានសេចក្តីស្លាប់នៅទីបំផុត ។

**យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យញ្ច អាមកំ សព្វំ ភេទបរិយន្តំ ឯវំ មច្ចាន ជីវិតំ ។**

ភាជន៍ដីដែលស្មូនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណាជីវិតរបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ ។

សត្វទាំងឡាយដែលកើតមកក្នុងលោកនេះ តែងមានជរា និងខណិកមរណៈជាប់ប្រឹតជាមួយនឹងខ្លួនមកគ្រប់រូបគ្រប់នាម ។

**យថាហិ អហិឆត្តកំ មកុលំ មត្ថកេន បំសុំ~ គហេត្វាន ឧគ្គច្ឆតិ**

ប្រៀបដូចក្រពុំផ្សិតដែលទុលឡើងផុតពីផែនដី តែងនាំយកមកនូវធូលីអាចម៍ដីឡើងមកផង ។

**តេសំ បដិសន្ធិចិត្តំ ឧប្បាទានន្តរមេវ ជរំ បត្វា ។**

សត្វទាំងឡាយ ដែលកាន់យកនូវបដិសន្ធិកំណើតក្នុងលោកនេះ ចាប់ផ្តើមអំពីបដិសន្ធិហើយ ក្នុងលំដាប់ឧប្បាទខណៈនៃបដិសន្ធិចិត្តនោះ ក៏ដល់នូវ

សេចក្តីជរា និងមរណៈៗជាប់ជិតតាមមកជាមួយនឹងខ្លួន ។

**[illegible] សិខរតោ បតិតោ សិលាវិយ ច**

ប្រៀបដូចដុំថ្ម ដែលបែកធ្លាយចុះចាកកំពូលភ្នំ តែងកាន់យកនូវដើមឈើ និងគុម្ពស្មៅដែលជាប់ជាមួយនឹងខ្លួនមកផង ។

**មរណំបិ សហជាតិយា អាគតំ ច**

កិរិយាកើត និងស្លាប់នេះ ជាប់មកព្រមគ្នាជាមួយសហជាតធម៌ ព្រោះថាកើតមានហើយ ស្លាប់ក៏មានផង ។

បុគ្គលដែលកើតមកនេះ តែងនឹងស្លាប់ទៅវិញដោយពិត ចាប់ដើមអំពីកើតឡើងហើយ ក៏បែរមុខឆ្ពោះទៅកាន់សេចក្តីស្លាប់ ដូចព្រះអាទិត្យឧត្តមធា ការរះឡើងហើយ ក៏បែរមុខឆ្ពោះទៅកាន់ទីអស្តង្គត មិនមានថយក្រោយត្រឡប់ចាកវិថីដំណើរនោះឡើយ ម្យ៉ាងវិញទៀតឧបមាដូចទឹកដែលហូរចុះមកអំពីភ្នំ ប្រព្រឹត្តទៅដោយរហ័សមិនអាចត្រឡប់ក្រោយ តែបណ្តាដើមឈើ និងដើមស្មៅដែលធ្លាក់ចុះមកក្នុងខ្សែទឹកនោះ សូម្បីតែវត្ថុណាមួយនឹងអាចត្រឡប់វិលក្រោយគ្មានឡើយ សេចក្តីនេះមានឧបមាដូចម្តេចមិញ ? មានឧបមេយ្យដូចអាយុសង្ខារសត្វទាំងពួង ដែលកន្លងទៅៗមិនត្រឡប់ក្រោយ តាំងមុខឆ្ពោះទៅកាន់សេចក្តីស្លាប់មិនវេរាដូច្នោះឯង ហេតុដូច្នេះហើយ បានជាព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា :

យមេករត្តឹ បឋមំ គព្ភេ វសតិ មាណវោ អព្ភុដ្ឋិតោវ សោ យាតិ ស គច្ឆំ ន និវត្តតីតិ ៕

ថា សត្វដែលនៅក្នុងគភ៌នៃមាតា ចាប់ផ្តើមអំពីខណៈតាំងបដិសន្ធិក្នុងវេលារាត្រីនោះ ហើយក៏តាំងប្រែទៅៗ កាលដើមជាកលលរូប ហើយប្រែទៅជាអព្វុទ ជាបេសិ ជាឃនៈ ចេះតែប្រែប្រួលទៅៗ ដរាបដល់មរណៈ ភាពជាទីបំផុត និងរកទៀងប្រាកដមិនមាន ប្រៀបដូចពពកដែលតាំងឡើងហើយ ក៏ដល់នូវភាវៈអណ្តែតឃ្លាតទៅៗ ដរាបដល់សូន្យបាត់ ។

សព្វោយំ លោកសន្និវាសោ ជាតិយា អនុគតោ ជរាយ អនុសដោ ព្យាធិនា អភិភូតោ មរណេន អព្ភាហតោ ៕

សត្វលោកទាំងឡាយដែលអាស្រ័យនៅក្នុងលោកទាំងអស់ តែងមានជាតិទុក្ខ [illegible] ធ្វើឱ្យវង្វេងភ្លាត់ស្មារតី ជរាទុក្ខតែងចងរួតរឹតឱ្យដល់នូវ [illegible] ព្យាធិទុក្ខជាអ្នកឈឺឆ្អាលញាំញី បៀតបៀនឱ្យឈឺចាប់សព្វរាងកាយ មរណៈទុក្ខជាអ្នកគ្របសង្កត់ បំបែកទំលាយផ្តាច់ផ្តិលជីវិតិន្ទ្រិយ ឱ្យវិនាសសាបសូន្យទៅ ។

ហេតុដូចពានរៀបរាប់មកនេះ ក៏ជាគ្រឿងសំរាប់ពិចារណាឱ្យមានសេចក្តីសង្វេគក្នុងរូបកាយ ហើយជាគ្រឿងពិចារណាដើម្បីឱ្យនឿយណាយចាកកិលេសកាម និងវត្ថុកាម ទូន្មានចិត្តកុំឱ្យមានការជាប់ជំពាក់ច្រើនហួសហេតុ

ទៅនឹងវត្ថុទាំងនោះ ជាពិសេសបំផុតត្រូវប្រឹងប្រែងស្វែងរកទួរទីពឹងសំរាប់ខ្លួនឯង ពោលគឺបុណ្យកុសល ជំរះចិត្តឱ្យបានថ្លាស្អាតសង្វាតព្យាយាម ទោះជាមិនមានបង ប្អូន កូនចៅ នៅជិត នៅក្បែរក៏ដោយ តែសូមមានបុណ្យកុសលនៅក្បែរខ្លួនជានិច្ច គ្មានអ្វីជាទីពឹងក្រៅអំពីបុណ្យឡើយ ។

**បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោតិ បាណិនំ ។**

មានតែបុណ្យកុសលទេជាទីពឹងរបស់សត្វទាំងឡាយក្នុងបរលោក។

## បុណ្យកឋិនទាន

ពាក្យថា **កឋិន** មកពី **កឋៈ** ធាតុ ដែលប្រែថា កម្រ ឬរស់នៅបានដោយកម្រ, ពោលសរសើរ, ប្រជុំនូវរូបធម៌ និង..ាមកម៉, ស្អិតល្មួរភ្ជាប់ខ្លួន, សង្គ្រោះទុកក្រសោបទុក ។

ប្រែថា កម្រ មានន័យថាក្រនឹងធ្វើអោយឡើងជាកឋិនពេញអង្គសម្បូចរិត្តបាៈថា **កឋតិ កិច្ឆេន ជីវតីតិ កឋិនំ** សភាវៈឯណាដែលរស់នៅបានដោយកម្រ សភាវៈនោះឯងហៅថា កឋិន ព្រោះលោកមានសេចក្ដីប្រៀបធៀបប្រដូចទៅនឹងឈើស្ងួត ដែលបុគ្គលបានកាត់ចេញអំពីដើម ហើយយកទៅបោះភ្ជាប់ទៅនឹងផែនដី ឈើនោះឯងរមែងដុះលូតលាស់យ៉ាងណា ឬក៏រស់នៅបានដោយកម្រយ៉ាងណា វិកិច្ចដែលកើតឡើង ឬតាំងឡើងជាកឋិនពេញទីនោះបានដោយកម្រពន់ពេកយ៉ាងនោះដែរ ។

ប្រែថា ពោលសរសើរ ពីព្រោះចីវរទានដែលពុទ្ធបរិស័ទយកមកធ្វើជាកឋិននោះ ជាទានវិសេសជាងទានដទៃដែលព្រះអរិយបុគ្គលទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម តែងពោលសរសើរចំពោះកឋិនទាន ដែលបុគ្គលបានធ្វើហើយដោយសទ្ធាជ្រះថ្លា ព្រោះតែបុគ្គលនោះបានអោយសេចក្ដីសុខស្រួលដល់ភិក្ខុសង្ឃក្នុងសាសនាដែលបានទទួលនូវអានិសង្ស ៥ ប្រការនោះឯង ។

ប្រែថា ប្រជុំនូវរូបធម៌ និងនាមធម៌ នោះគឺ រូបធម៌ បានដល់ភិក្ខុសង្ឃ ដែលលោកបានចូលកាន់ព្រះវស្សា គឺចូលកាន់នៅក្នុងបរិមិកវស្សូបនាយិកា ការចាំវស្សាខាងដើមដែលហៅថា វស្សាទីមួយ ក្នុងវត្តនីមួយៗ មានភិក្ខុសង្ឃជាបញ្ចវគ្គក្តី ឬ ក៏លើសជាងនេះក្តី ព្រមទាំងត្រៃចីវរដែលកើតឡើងប្រកបដោយចីវរកាល នេះហៅថារូបធម៌, ឯនាមធម៌បានដល់វស្សាបីខែ អត្ថារៈ គឺការក្រាលគ្រងប្រកបដោយ [illegible] [illegible]មោទនាញត្តិ ប្រគល់សំពត់កឋិន ពាក្យក្រើនកឋិន បច្ចុទ្ធ [illegible] [illegible] ប៉ុណ្ណោះ ជាដើមហៅថានាមធម៌ ។

ប្រែថា ស្ថិតស្ថេរភ្ជាប់ខ្លួន វិគ្គហៈថា **ចិរះឋ្ថាន កឋិនំ** កឋិន គឺការតាំងនៅស្ថិតស្ថេរភ្ជាប់ខ្លួនអស់រយៈកាល ៥ ខែ ដោយអំណាចនៃកឋិនទាននោះឯង ។

ប្រែថា សង្គ្រោះទុក ក្រសោបទុក នោះគឺជាការអោបក្រសោបនូវអានិសង្ស ៥ មិនអោយឃ្លាតទៅកាន់ទីដទៃបាន សមដូចវិគ្គហៈពោលថា

**បញ្ច អានិសំសេ អញ្ញត្ត គន្តុំ អនត្វា កថតិ សង្គណ្ហាតីតិ កឋិនំ** ធម្មជាតិឯណាដែលសង្គ្រោះទុកក្រសោបទុក ឬ ក្រៀកទុកនូវអានិសង្ស ៥ មិនអោយទៅកាន់ដទៃបានយ៉ាងណា ធម្មជាតិនោះឯងហៅថា កឋិន ។ កឋិននេះអាចអោយសម្រេចផលដល់បុគ្គលពីរផ្នែក គឺទាយកទាយិកាដែលជាអ្នកធ្វើក៏បានទទួលនូវអានិសង្សដ៏ធំធេង ចំណែកបដិគ្គាហកៈភិក្ខុ អ្នកទទួលក្រាលគ្រង និងអនុមោទនា ក៏បានទទួលនូវអានិសង្ស ៥ ប្រការពេញលេញគ្រប់គ្រាន់ដរាបដល់អស់នៃកឋិនខេត្ត ។ បើសិនជាបម្រួញអោយខ្លីមកមានន័យថា ជាកិច្ចមួយក្នុងព្រះពុទ្ធសាសនា ដែលកើតឡើងតាមពុទ្ធានុញ្ញាតសំរាប់ហ៊ុមទុក ក្រៀកទុកអានិសង្សទាំង ៥ របស់ភិក្ខុ ។ ឧទាហរណ៍ ដូចពាក្យថា ក្រោល ឬ ឈើស្នឹង ដែលសំរាប់ហ៊ុំម និងចងក្រៀកសត្វពាហណៈទុកយ៉ាងណា កឋិនក៏យ៉ាងនោះដែរ ។

បន្ទាប់អំពីកឋិនសព្ទនេះទៅ នឹងលើកអំពីបុព្វហេតុ ហេតុខាងដើមដែលនាំអោយព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតអោយធ្វើបុណ្យកឋិននេះឡើងសំដែងទុកក្នុងវិន័យបិដក មហាវគ្គ ពតិយភាគ កឋិនក្ខន្ធកៈ ភាគ ៨ ។

## រឿងភិក្ខុ ៣០ រូប

ក្នុងបឋមពោធិកាល ដែលព្រះបរមសាស្តាទ្រង់ឱ្យភិក្ខុប្រើប្រាស់តែបង្សុកូលចីវរ ពុំទាន់ទ្រង់អនុញ្ញាតឱ្យប្រើគហបតីចីវរនៅឡើយនោះ ។ សម័យ

មួយ កាលដែលទ្រង់គង់ចាំវស្សានៅវត្តជេតពន ជាអារាមរបស់អនាថ-បិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី ។ គ្រានោះ មានភិក្ខុ ៣០ អង្គ ឈ្មោះថា ភទ្ទវគ្គីយត្ថេរក្នុងដែនបាវេយ្យ ជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ។ល។ ក៏នាំគ្នាចេញពីទីនោះមកកាន់ក្រុងសាវត្ថីដើម្បីគាល់បំរើព្រះដ៏មានព្រះភាគ ទើបតែមកដល់ពាក់កណ្ដាលផ្លូវ ជួនជាដល់ថ្ងៃចូលព្រះវស្សា នឹងស្រូតមកទៀតមិនទាន់ ក៏នាំគ្នាស្វែងរកសេនាសនៈនៅចាំវស្សាទៀបក្រុងសាកេត នាពាក់កណ្ដាលផ្លូវនោះទៅ ។ ភិក្ខុទាំងនោះមានសេចក្ដីអផ្សុកជាខ្លាំង ដោយគិតឃើញថាព្រះដ៏មានព្រះភាគទ្រង់គង់នៅទីជិតចម្ងាយ ៦ យោជន៍ទៀតសោះ មិនសមបើយើងទាំងឡាយមកស្តុនដំណើរ មិនបានទៅគាល់បំរើព្រះអង្គ ។

លុះដល់ថ្ងៃចេញព្រះវស្សា បវារណាស្រេចហើយ លោកក៏នាំគ្នាស្រូតចេញអំពីទីនោះមកទៀត ទទួលរដូវនោះមានភ្លៀងរលឹម ជោកជាំនៅឡើយ តាមផ្លូវដែលទៅមកពោរពេញដោយទឹក និងភក់រអិលប៉ប៉ិចប៉ប៉ាច់ ។ល។ លុះដល់ក្រុងសាវត្ថីហើយ ក៏ចូលទៅកាន់វត្តជេតពន ដែលព្រះដ៏មានព្រះភាគទ្រង់គង់នៅ ក្រាបថ្វាយបង្គំព្រះមានព្រះភាគរួចហើយ ក៏អង្គុយក្នុងទីដ៏សមគួរ លំដាប់នោះព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលរាក់ទាក់ទៅរកភិក្ខុទាំងនោះថា : ម្នាលភិក្ខុទាំងឡាយ ! សរីរយន្តរបស់អ្នក ទាំងឡាយល្មមអត់សង្កត់បានឬទេ ? ល្មមប្រព្រឹត្តទៅបានឬទេ ? អ្នកទាំងឡាយមានសេចក្ដីព្រមព្រៀងស្មោះស្ម័គ្រឥតមានវិវាទទាស់ទែងគ្នាឬទេ ? អ្នកទាំងឡាយ

នៅចាំវស្សាសោត ស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតឬទេ ? ភិក្ខុទាំងឡាយក៏ក្រាបថ្វាយបង្គំទូលតាមដំណើរនោះរួចហើយ ក៏ក្រាបបង្គំទូលសេចក្ដីលំបាករបស់ខ្លួន ដែលមានមកតាមផ្លូវដោយសព្វគ្រប់តាមដំណើរ ។

លំដាប់នោះព្រះមានព្រះភាគទ្រង់សំដែងនូវធម្មកថា ប្រារព្ធអំពីសង្សារវដ្តមិនមានទីបំផុត, ប្រោសប្រទានដល់ភិក្ខុទាំងនោះ, លុះចប់ធម៌ទេសនាហើយ ភិក្ខុទាំងនោះក៏បានសម្រេចព្រះអរហន្តទាំងអស់អង្គ ហើយនាំគ្នាហោះតាមអាកាសទៅកាន់ទីលំនៅរបស់ខ្លួនអស់ទៅ ។ បន្ទាប់ពីនោះមក ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា . បើសិនជាតថាគតបានអនុញ្ញាតកឋិនត្ថារកិច្ចទុកអំពីគ្រាមុន ម្ល៉េះសមភិក្ខុទាំងនោះនឹងបានលះចីវរមួយទុកនៅទីកន្លែងជាប់មកតែស្បង់ និងចីពរប៉ុណ្ណោះ មានអត្តភាពស្រាលមិនលំបាកយ៉ាងនេះសោះឡើយ ហើយកឋិនត្ថារកិច្ចនេះសោត ព្រះពុទ្ធទាំងឡាយរាល់ព្រះអង្គក៏តែងតែទ្រង់អនុញ្ញាតទុកដល់សាវកពុំដែលលះផង ព្រះមានជោគទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក ទ្រង់អនុញ្ញាតកឋិនត្ថារកិច្ចនេះ ព្រះពុទ្ធដីកាថា:

**អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ អត្ថត កឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ ។**

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យពួកភិក្ខុ ដែលបាននៅចាំវស្សារួចហើយក្រាលកឋិនបាន ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ

បានក្រាលកឋិនហើយ នឹងសម្រេចអានិសង្ស ៥ ប្រការ ។

## កឋិនទានប្លែកពីចីវរទានដោយហេតុ ៥ យ៉ាង គឺ ៖

**១.ប្លែកដោយកាល** កាលដែលព្រះមានព្រះភាគទ្រង់អនុញ្ញាតឱ្យធ្វើកឋិននោះ គឺមាន ២៩ ថ្ងៃ រាប់ពីថ្ងៃ ១ រោច ខែអស្សុជ រហូតដល់ថ្ងៃ ១៥ កើត ខែកត្តិក ។ រយៈកាលនេះឯងដែលពាក្យសាមញ្ញលោកហៅថា រដូវកឋិន ។ ក្នុងរដូវនេះ បើសិនជាពុទ្ធបរិស័ទប្រាថ្នាធ្វើបុណ្យកឋិន គឺអាចធ្វើបាន ប៉ុន្តែបើសិនជាធ្វើក្រៅអំពីថ្ងៃទាំង ២៩ នេះពុំបានឡើយ ហើយតាមបណ្តាវត្តនីមួយៗទទួលបានតែម្តង ចំណែកភិក្ខុវិញក៏ទទួលក្រាលគ្រងកឋិន និងអនុមោទនា ក៏បានតែម្តងដែរ មិនអាចទទួលម្តងទៀតបានទេ ។

**២.ប្លែកដោយវត្ថុ** សំពត់ដែលគេយកធ្វើជាអង្គកឋិននោះគឺបានតែស្បង់ ចីពរ សង្ឃាដី ដែលគេយកសំពត់នោះធ្វើឱ្យត្រឹមត្រូវតាមពុទ្ធបញ្ញត្តិ ។ សំពត់ក្រៅពីនោះពុំបានឡើយ ហើយសំពត់ទាំង ៣ មុខទៀតសោត នឹងយកទាំងអស់ជាអង្គកឋិនពុំបាន គឺបានតែមួយមុខ ទោះបីជាទាយកវេរប្រគេនចីវរមួយគ្រែក៏ដោយ ភិក្ខុអ្នកក្រាលគ្រងជ្រើសរើសយកតែវត្ថុមួយមកធ្វើជាកឋិន បើសិនជាលោកចង់ក្រាលគ្រងស្បង់ក៏បាន, ចីពរក៏បាន, សង្ឃាដីក៏បាន អោយតែក្រាលយកតែមួយមិនអាចយកទាំងអស់បានទេ ដើម្បី

ក្រាលគ្រងឱ្យត្រឹមត្រូវតាមវិនយប្បញ្ញត្តិ ។

**៣.ខ្ពែកដោយអំពើ** ទាយកទាយិកាដែលជាអ្នកធ្វើ គប្បីធ្វើ អោយត្រឹមត្រូវតាមព្រះវិន័យ ហើយភិក្ខុសង្ឃអ្នកក្រាលគ្រង និងអនុមោទនា អោយត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត ទើបឡើងជាកឋិនពេញ លក្ខណៈបាន ។

**៤.ខ្ពែកដោយបដិគ្គាហកៈ** អ្នកដែលទទួលសំពត់កឋិន គឺបាន តែភិក្ខុ ក្រៅអំពីភិក្ខុពុំបានឡើយ ហើយភិក្ខុនោះសោតទៀត លុះត្រាតែបាន ចាំវស្សាគ្រប់ ៣ ខែ ក្នុងវត្តណាមួយ ទើបទទួលក្រាលគ្រងអនុមោទនា កឋិនក្នុងវត្តនោះបាន បើភិក្ខុពុំបានចាំវស្សា ឬ បានចាំវស្សាដែរ ប៉ុន្តែដាច់ វស្សាគឺពុំអាចក្រាលគ្រងកឋិនបានឡើយ ។

**៥.ខ្ពែកដោយអានិសង្ស** គឺទាយកទាយិកាអ្នកធ្វើក៏បាននូវ អានិសង្ស ភិក្ខុសង្ឃអ្នកទទួលក្រាលគ្រង និងអនុមោទនា ក៏បាននូវអានិសង្ស ៥ អស់រយៈពេល ៥ ខែ ។

## អានិសង្ស ៥ គឺ :

**១.អនាមន្តចារោ** ភិក្ខុត្រាច់ចរទៅកាន់ទីដទៃដោយមិនបាច់លា ភិក្ខុផងគ្នា គឺរួចចាកអាបត្តិនៅក្នុងចារិត្តសិក្ខាបទទី ៦ អចេលកវគ្គ សុទ្ធិកបាចិត្តិយ ។

**២.អសមាទានចារោ** ភិក្ខុត្រាច់ទៅកាន់ទីឯទៃដោយមិនបាច់យកត្រៃចីវរគ្រប់ទាំង ៣ ទៅជាមួយបាន ដោយរួចចាកអាបត្តិនៅក្នុងទុតិយកឋិន សិក្ខាបទទី ២ ចីវរវគ្គ និស្សគ្គិយបាចិត្តិយ ។

**៣.គណភោជនំ** ភិក្ខុទទួលឆាន់គណភោជនបាន គឺភោជនដែលគេនិមន្តចំពោះឈ្មោះភត្ត រួចចាកអាបត្តិនៅក្នុងគណភោជនៈ សិក្ខាបទទី ២ នៃភោជនវគ្គ សុទ្ធិកបាចិត្តិយ ។

**៤.យាវទត្ថចីវរំ** ភិក្ខុទុកដាក់អតិរេកចីវរបានតាមត្រូវការ រួចចាកអាបត្តិក្នុងបឋមកឋិន សិក្ខាបទទី ១ នៃចីវរវគ្គ និស្សគ្គិយបាចិត្តិយ ។

**៥.យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ** ចីវរណាដែលកើតឡើងក្នុងអាវាសនោះ ចីវរនោះនឹងមានដល់ភិក្ខុទាំងនោះ ។

អានិសង្សរបស់ភិក្ខុអ្នកក្រាលគ្រងអនុមោទនា គឺមាន ៥ នេះឯង ដូចបានរៀបរាប់ខាងលើនេះស្រេច ។ ហេតុនេះបានជាលោកពោលថាកឋិនទានជាចីវរទានដែលវិសេសវិសាលប្រសើរជាងចីវរទានដទៃ ពីព្រោះពុទ្ធបរិស័ទទាំងឡាយបានឱ្យនូវអានិសង្សទាំង ៥ ប្រការដល់ពួកភិក្ខុ ដូចជាបានឱ្យនូវសេចក្តីសុខស្រួលដល់បដិគ្គាហកៈអ្នកទទួលទាននោះ រមែងជួបប្រទះនៃសេចក្តីសុខវិញមិនខាន សមដូចពុទ្ធដីកាព្រះអង្គទ្រង់ត្រាស់ថា : **សុខស្ស**

**ទាតា មេធាវី សុខំ សោ អធិគច្ឆតិ** ជនអ្នកមានប្រាជ្ញាណាមួយ បានឱ្យសេចក្តីសុខស្រួលដល់អ្នកដទៃ ជននោះឯងរមែងបានជួបប្រទះនឹងសេចក្តីសុខស្រួលវិញជាពិតប្រាកដពុំខានឡើយ ។

ហេតុនេះបុគ្គលណាមួយបានធ្វើបុណ្យកឋិនទាន ដែលនាំឱ្យភិក្ខុសង្ឃបាននូវអានិសង្ស ៥ ប្រការនោះ បុគ្គលទាំងនោះតែងតែទទួលបាននូវសេចក្តីសុខក្នុងមនុស្សលោក និងទេវលោកទៅក្នុងអនាគតជាតិ ទាយកទាយិការមែងទទួលនូវអានិសង្សវិញមិនខាន ។

## អានិសង្សរបស់បុណ្យ ៥ យ៉ាង គឺ :

**១.តិក្ខបញ្ញោ វិសារទោ** ដោយអំណាចនៃបុណ្យ រមែងជាបរិបូណ៌ទៅដោយបញ្ញាដ៏ច្រើន ។

**២.សុរូបតា** ដោយអំណាចនៃបុណ្យ រមែងជាអ្នកមានរូបល្អ។

**៣.សុវណ្ណតា** ដោយអំណាចនៃបុណ្យ រមែងជាអ្នកមានពណ៌សម្បុរកាយស្អាតល្អ ។

**៤.សុសណ្ឋានោ** ដោយអំណាចនៃបុណ្យ រមែងជាអ្នកមានរូបរាងទ្រង់ទ្រាយស្អាតល្អ ។

**៥.ចក្កវត្តិ រាជាហោតិ** ដោយអំណាចនៃបុណ្យ រមែងបានកើតជាស្តេចចក្រពត្តិក្នុងភពណាមួយមិនខាន ។

ដូច្នេះហើយជនទាំងឡាយឯណា ដែលប្រាថ្នានូវសេចក្ដីសុខ បានឱ្យនូវចីវរទាន ជនទាំងឡាយនោះឯង រមែងរួចចាកសេចក្ដីទុក្ខ ហើយមិនបានទៅកាន់អបាយភូមិទាំង ៤ មាននរក ប្រេត អសុរកាយ សត្វតិរច្ឆានជាដើម ហើយនឹងបានសោយសម្បត្តិជាទិព្វក្នុងទេវលោកអស់កាលដ៏យូរអង្វែង លុះច្យុតអំពីទេវលោកមក នឹងបានកើតជាស្ដេចមានកម្លាំងរិទ្ធិច្រើនបរិបូណ៌ដោយរតនៈ ៧ ប្រការ ហើយបានជាធំក្នុងទ្វីបទាំងបួន តែងតែកើតក្នុងត្រកូលពីរ គឺខត្តិយត្រកូល ១ ព្រាហ្មណ៍ត្រកូល ១ ហើយមិនបានទៅកើតក្នុងត្រកូលថោកទាបឡើយ នេះជាផលរបស់កឋិន បើចេញបួសបានជាឯហិភិក្ខុ ឬ ឯហិភិក្ខុនីក្នុងសាសនា ព្រះពុទ្ធអង្គណាមួយមិនខានឡើយ ។

## បុណ្យចូលព្រះវស្សា

ពាក្យថា **វស្សា** មកអំពីពាក្យបាលីថា **វស្សៈ** ប្រែថា ភ្លៀង ឬ រដូវភ្លៀងដែលមានកំណត់រយៈពេល ៤ ខែ គឺរាប់ពីថ្ងៃ ១ រោច ខែអាសាឍ រហូតដល់ថ្ងៃ ១៥ កើត ខែកត្តិក រយៈពេលនេះឯងហៅថា វស្សានរដូវ ។

បានជាព្រះបរមសាស្ដានៃយើង ព្រះអង្គទ្រង់អនុញ្ញាតអោយភិក្ខុសង្ឃមានកិច្ចចូលចាំព្រះវស្សានោះ ពីព្រោះមានបុព្វហេតុ ហេតុខាងដើម ២ យ៉ាងគឺ :

១-ភិក្ខុទាំងឡាយត្រាច់ចរទៅកាន់ទីកន្លែងផ្សេងៗចម៉ែនោះ មានខ្លះ មិនខ្លះ មានការដើរជាន់នៅភូតគាម ពិជគាម និងចញ្ញជាតិផ្សេងៗ ដែលជាហេតុនាំអោយអ្នកស្រុកតិះគន់តិះដៀល និងពោលនូវទោសដែលមានប្រការផ្សេងៗ ។

២-ជាវដូវភ្លៀងជោកជាំផង ព្រះពុទ្ធអង្គមានពុទ្ធបំណងកុំអោយបព្វជិតក្នុងសាសនា លំបាកក្នុងការធ្វើដំណើរទៅមក គឺឱ្យចាំវស្សាតែមួយកន្លែងអស់រយៈពេល ៣ ខែ ។

## ព្រះអង្គទ្រង់អនុញ្ញាតឱ្យភិក្ខុចូលចាំវស្សា

មានសំដែងទុកក្នុង វិន័យបិដក មហាវគ្គ ទុតិយភាគ វស្សូបនាយិកក្ខន្ធកៈ ភាគ ៧ :

សម័យនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅវត្តវេឡុវ័ន កលន្ទកនិវាបស្ថានទៀបក្រុងរាជគ្រឹះ ។ គ្រានោះឯង ការនៅចាំវស្សា ព្រះមានព្រះភាគមិនទាន់បានបញ្ញត្តិដល់ភិក្ខុទាំងឡាយនៅឡើយ ភិក្ខុទាំងនោះក៏ត្រាច់ដើរទៅកាន់ចារិកអស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវខ្លះ មនុស្សទាំងឡាយ ក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកសមណៈសាក្យបុត្រ មិនសមបើនឹងដើរទៅកាន់ចារិកអស់ហេមន្តរដូវខ្លះ អស់គិម្ហរដូវខ្លះ អស់វស្សានរដូវ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀនឥន្ទ្រិយដែលមានជីវៈតែមួយញ៉ាំងសត្វតូចៗជាច្រើនឱ្យដល់នូវសេចក្តីវិនាសសោះ សូម្បីពួកបរិព្វាជក

មានលទ្ធិដទៃទាំងនេះ ដែលជាពោលធម៌អាក្រក់ ម្ដេចគង់នៅសម្ងំឈប់សម្រាកនៅចាំវស្សា សូម្បីទាំងពួកសត្វស្លាបនេះទៀតសោត ក៏គង់ធ្វើសំបុកលើចុងឈើទាំងឡាយ ហើយសម្ងំឈប់សម្រាកនៅចាំវស្សាដែរ ចំណែកឯពួកសមណៈជាសក្យបុត្តនេះ នៅតែដើរទៅកាន់ចារិក អស់ហេមន្តរដូវខ្លះ គិម្ហរដូវខ្លះ វស្សានរដូវខ្លះ ដើរជាន់ស្មៅស្រស់ទាំងឡាយ បៀតបៀនវត្ថុដែលមានជីវិតមានឥន្ទ្រិយតែមួយ ញ៉ាំងសត្វតូចៗជាច្រើនឱ្យដល់សេចក្ដីវិនាស ។ កាលមនុស្សទាំងឡាយកំពុងពោលទោសតិះដៀលបន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ គ្រានោះឯងភិក្ខុទាំងនោះ ក្រាបទូលសេចក្ដីនោះចំពោះព្រះដ៏មានព្រះភាគ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវធម្មីកថាក្នុងវេលានោះឯង រួចហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមក អនុញ្ញាតថា **អនុជានាមិ ភិក្ខវេ វស្សំ ឧបគន្តុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអោយភិក្ខុចូលចាំវស្សា ។ កិច្ចដែលព្រះសម្មាសម្ពុទ្ធទ្រង់កំណត់អោយចាំវស្សានោះឯងហៅថា : **វស្សូបនាយិកា ២**

**វស្សូបនាយិកា** ការចូលវស្សា ២ យ៉ាង គឺ :

១-**បុរិមិកាវស្សូបនាយិកា** ការចូលវស្សាខាងដើម ព្រះអង្គទ្រង់អនុញ្ញាតអោយភិក្ខុចូលចាំវស្សាខាងដើម រាប់ចាប់តាំងពីថ្ងៃ ១ រោជ ខែអាសាឍ ឬ ខែទុតិយាសាឍ រហូតដល់ថ្ងៃ ១៥ កើត ខែអស្សុជ

វស្សាទី ១ នេះ បើភិក្ខុក្នុងសាសនាបានចាំវស្សាហើយ អាចទទួលក្រាលគ្រង និងអនុមោទនាបានកឋិនបាន ។

**២.បច្ឆិមិកាវស្សូបនាយិកា** ការចូលវស្សាខាងចុង ព្រះអង្គទ្រង់អនុញ្ញាតឱ្យភិក្ខុចូលចាំវស្សាទី ២ រាប់អំពីថ្ងៃ ១ រោជ ខែស្រាពណ៍ រហូតដល់ថ្ងៃ ១៥ កើត ខែកត្តិក វស្សាទី ២ ចុងក្រោយនេះ បើភិក្ខុបានចាំហើយ គឺគ្មានសិទ្ធិទទួលក្រាលគ្រង ឬ អនុមោទនាកឋិនបានទេ ។ម្យ៉ាងទៀត មុននឹងចូលវស្សា ១ ខែ ព្រះអង្គទ្រង់បានអនុញ្ញាតអោយភិក្ខុស្វែងរកនូវសំពត់សំរាប់ងូតទឹកភ្លៀង ដើម្បីប្រើប្រាស់ពេលចូលវស្សានោះ ពីថ្ងៃ ១ រោជ ខែជេស្ឋ រហូតដល់ថ្ងៃ ១៥ កើត ខែអាសាឍ ចំណែកពុទ្ធបរិស័ទវិញ បានដឹងឮនូវពុទ្ធានុញ្ញាតនេះហើយ ក៏នាំគ្នាធ្វើនូវសំពត់ងូតទឹកភ្លៀង ព្រមទាំងប្រេង ទៀន ដែលជាគ្រឿងប្រទីប ដើម្បីដង្ហែរយកទៅវេរប្រគេនចំពោះភិក្ខុសង្ឃក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ជារៀងរាល់ឆ្នាំមិនដែលដាច់ រហូតដល់សម័យបច្ចុប្បន្ននេះ ដើម្បីងាយស្រួលមិនឱ្យភិក្ខុសង្ឃលំបាកក្នុងការស្វែងរកសំពត់ ហើយក៏ដើម្បីឱ្យខ្លួនបានបំពេញកុសល ឬបានធ្វើនូវចីវរទាន ដែលជាទានមួយសំរាប់ជួយឧបត្ថម្ភគាំទ្រព្រះពុទ្ធសាសនាផ្នែកព្រះវិន័យផង ព្រោះចីវរទាន គឺជាបច្ច័យមួយសំរាប់ទ្រទ្រង់ការពារបិទបាំងរាងកាយ និងការពារនូវកំដៅ ត្រជាក់ ដែលបានបូជាជូនចំពោះមាតាបិតា ឬវេរប្រគេនគ្រៃចីវរដល់បដិគ្គាហកៈ រមែងបាននូវផលានិសង្សដ៏ច្រើន ទាំង

បច្ចុប្បន្ន ទាំងអនាគត ។ ការឱ្យបដិក្ខាហារៈ អ្នកទទួលទានបានសម្បុរល្អក្នុងបច្ចុប្បន្ន ហើយទាយកអ្នកឱ្យទាន រមែងបានសម្បុរល្អ សម្បូណ៌ស្រៀងស្ញ៉ែកពាក់ក្នុងកាលជាអនាគត ។

មានសំដែងទុកក្នុងសុ.សំយុត្តនិកាយ សគាថវគ្គ ភាគ ២៩ ទំព័រ ៨០ :

កាលដែលព្រះសម្មាសម្ពុទ្ធទ្រង់គង់ព្រះជន្មនៅឡើយ ទេវតាបានក្រាបបង្គំទូលសួរថា **កិំទទោ ហោតិ វណ្ណទោ** បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន បុគ្គលឱ្យអ្វីទើបឈ្មោះថាអោយពណ៌សម្បុរ ?

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **វត្ថទោ ហោតិ វណ្ណទោ** បុគ្គលឱ្យសំពត់ជាទាន ឈ្មោះថា អោយពណ៌សម្បុរ ។ ការឱ្យពណ៌សម្បុរជាទាន បានឈ្មោះថា ឱ្យវណ្ណៈទាន ដល់អ្នកទទួលទានក្នុងជាតិជាបច្ចុប្បន្ន ហើយអ្នកម្ចាស់ទាននោះ តែងតែបានជាអ្នកមានសម្បុរល្អ សម្បូណ៌ស្រៀងស្ញ៉ែកពាក់ និងទ្រព្យសម្បត្តិក្នុងជាតិជាអនាគត ។

## រឿងនាងខ្ញុំម្នាងន្ទី

ក្នុងកាលដែលកន្លងទៅហើយ មាននាងកញ្ញាម្នាក់ជាកូនអ្នកទំលេក្រ នៅនគរពារាណសី ។ ថ្ងៃមួយនៅរដូវចូលឆ្នាំ នាងបានឃើញពួកកញ្ញាកូនអ្នកមាន គេស្ញ៉ែកពាក់សំពត់ពណ៌ក្រហមល្អៗ ដើរលេងកំសាន្តតាមប្រពៃណីស្រុក ។ នាងចង់បានល្អដូចគេក៏សុំលាមាតាបិតាទៅរកស៊ីឈ្នួលគេនៅភូមិ

មួយដើម្បីយកសំពត់ពណ៌ក្រហម ១ ត្បូង ។

នាងទៅរកស៊ីឈ្នួលនៅផ្ទះគហបតីម្នាក់ គេថាលុះតែធ្វើការឱ្យគេគ្រប់ ៣ ឆ្នាំ ទើបគេឱ្យសំពត់ពណ៌ក្រហម ១ ត្បូង ។ នាងកញ្ញាក៏សុខចិត្តស៊ីឈ្នួលគេតាមកាលបរិច្ឆេទនោះ តែដោយនាងយកចិត្តទុកដាក់ធ្វើការឱ្យគេបានល្អពេញចិត្តគេ នាងធ្វើការត្រឹមតែមួយឆ្នាំក៏គេឱ្យសំពត់ក្រហមមួយត្បូងព្រមទាំងសំពត់ដទៃខ្លះផង ហើយនាងក៏ត្រឡប់មកផ្ទះវិញ ដល់ពាក់កណ្ដាលផ្លូវ នាងបានឃើញព្រះអរហន្តមួយអង្គ ជាសាវ័កនៃព្រះពុទ្ធកស្សបដែលចោរដណ្ដើមយកស្បង់ចីវរអស់ លោកខ្វាស់ស្លឹកឈើស្លៀកដណ្ដប់និមន្តដើរមកជិតនាង ។ នាងអាណិតលោកបានប្រគេនសំពត់មួយអាវដល់លោក ។ កាលលោកយកទៅស្លៀកហើយ នាងឃើញពណ៌ល្អ ក៏ប្រគេនមួយអាវឱ្យលោកដណ្ដប់ហើយនាងឃើញលោកមានរស្មីល្អ ដូចព្រះអាទិត្យមើបរះ ក៏ធ្វើសេចក្ដីប្រាថ្នាថា ដោយអំណាចផល[illegible]ទាននេះ នាងខ្ញុំទៅកើតជាខាងមុខ សូមឱ្យមានរូបល្អអស្ចារ្យ បុ[illegible]បានឃើញឱ្យភ័ន្តស្មារតី កុំឱ្យទប់ចិត្តបានព្រះថេរៈធ្វើអនុមោទនា ហើយនិមន្តជៀសចេញទៅ ។

ដោយផលានិសង្សនោះ លុះនាងអស់អាយុទៅបានទៅកើតជាទេពធីតាក្នុងទេវលោក អស់អាយុពីទេវលោកមក បានកើតជាកូនសេដ្ឋីអ្នកមានទ្រព្យ ៨០ កោដិ ឈ្មោះសិរិវឌ្ឍសេដ្ឋី នៅអរិដ្ឋបុរីក្នុងសិវរដ្ឋ នាងមានរូបល្អណាស់ អ្នកស្រុកហៅថា ស្រីកែវ ។ លុះនាងពេញរូបរាងឡើងជនណាបានឃើញក៏ភ័ន្តភាំងស្មារតីរកគិតអ្វីមិនឃើញហាក់ដូចជាឆ្កួត ហេតុនេះបានជាអ្នកស្រុកហៅថា នាងឧម្មាទន្តី (ស្រីធ្វើអោយគេឆ្កួត) ។

សេដ្ឋីជាបិតាបានថ្វាយដំណឹងនោះចំពោះព្រះរាជា។ ទ្រង់ព្រះសណ្តាប់ ក៏ទ្រង់សព្វព្រះរាជហឫទ័យ ទ្រង់ចាត់ឱ្យពួកព្រាហ្មណ៍ទៅពិនិត្យលក្ខណៈ បើឃើញល្អត្រឹមត្រូវមែន ទ្រង់នឹងឱ្យដណ្តឹងយកធ្វើជាព្រះទេពី ។ លុះព្រាហ្មណ៍ទាំងនោះទៅដល់ផ្ទះនាង សេដ្ឋីជាបិតាបានរៀបចំភោជនាហារឱ្យបរិភោគ ។ ពេលពួកព្រាហ្មណ៍កំពុងបរិភោគ សេដ្ឋីឱ្យនាងជាកូនតែងខ្លួនចេញមកបង្ហាញខ្លួនឱ្យព្រាហ្មណ៍ពិនិត្យមើល ។ លំអរបស់នាងនោះ ចោលស្រមោលសម្ផស្ស ទៅប៉ះខ្សែចក្ខុរបស់ពួកព្រាហ្មណ៍ ធ្វើអោយពួកព្រាហ្មណ៍ទាំងនោះភ័ន្តស្មារតី ដោយកិលេសគ្របសង្កត់ ព្រាហណ៍ខ្លះដាក់បាយលើក្បាល ខ្លះញាត់ទៅក្នុងត្រចៀក ខ្លះទះជញ្ជាំង ដូចជាមនុស្សឆ្កួត ។

នាងឧម្មាទន្តីឃើញអាការៈដូច្នោះ ក៏បណ្តេញព្រាហ្មណ៍ទាំងនោះឱ្យចេញទៅ ។ ដោយខ្មាសគេខ្លាំងពេក ព្រាហ្មណ៍ទាំងនោះទូលព្រះរាជាថា នាងនោះជាស្រីកាឡកណ្ណីឆ្កួត មិនល្អទេ ។ ព្រះរាជាទ្រង់ក៏ឈប់ត្រូវការ ក្រោយពីនោះមិនយូប៉ុន្មាន នាងបានជាភរិយារបស់អភិបារកៈអាមាត្យ ជាមនុស្សសំណព្វរបស់ព្រះរាជា ។ ថ្ងៃមួយជាថ្ងៃនក្ខត្តឫក្ស ព្រះរាជាទ្រង់គង់ព្រះរាជយានដើរប្រទក្សិណព្រះនគរ ។ នាងឧម្មាទន្តីឈរនៅបង្អួចផ្ទះមើលក្បួនហែព្រះរាជា ។ ព្រះរាជាទតឃើញនាង ទ្រង់ជ្រាបថា នាងហ្នឹងហើយជាស្រីកែវ ដែលទ្រង់ឱ្យព្រាហ្មណ៍ទៅពិនិត្យនោះ ក៏ទ្រង់ព្រះវិតក្កៈជាខ្លាំង ផ្ទំមិនលក់ សោយមិនបាន ស្គមព្រះអង្គ ព្រោះទ្រង់ចង់បាននាងជាទេពី តែទ្រង់ជ្រាបថា នាងបានជាភរិយាមហាអាមាត្យទៅហើយ ក៏ទ្រង់លាក់សេចក្តីស្នេហានោះទុកក្នុងព្រះទ័យ ពុំឱ្យនរណាដឹងឡើយ ។

មហាអាមាត្យដឹងរឿងនោះ ក៏ចាត់ឱ្យមនុស្សម្នាក់ទៅជ្រកសម្ងំក្នុងព្រៃក្រោយខ្ទមទេព្រឹក្សមួយ ហើយខ្លួនមហាអាមាត្យ ធ្វើជាទៅបន់ទេព្រឹក្សនោះ សួរពីរឿងព្រះអាការរោគរបស់ព្រះរាជា ។ មហាអាមាត្យទៅដល់ខ្ទមទេព្រឹក្សសួរថា "លោកតា ! ព្រះរាជាទ្រង់ប្រឈួនដោយអាការរោគអ្វីបានជាទ្រង់ធ្ងន់ធ្ងរពុំលក់ សោយពុំបាន ? " ។ អ្នកដែលនៅក្រោយទេព្រឹក្សឆ្លើយថា "ព្រះរាជាទ្រង់ប្រឈួនព្រោះរោគស្នេហា ដោយស្រឡាញ់នាងស្រីកែវជាភរិយារបស់លោកហ្នឹងឯង" ។ មហាអាមាត្យទូលព្រះរាជាតាមដំណើរនោះ ព្រះរាជាទ្រង់ពិចារណាថា សេចក្ដីស្នេហារបស់អញ ៗ លាក់ទុកតែក្នុងដួងចិត្តមិនឱ្យនរណាដឹងទេ ម្ដេចក៏ទេពតាទេព្រឹក្សដឹងនូវរឿងហោមកភាពរបស់អាត្មាអញបាន ហើយទ្រង់កាត់សេចក្ដីស្នេហានេះចោលចេញទៅ ។

ឯនាងឧម្មាទន្តី ដែលមានរូបល្អត្រកូលខ្ពស់បានជាភរិយារបស់..មាត្យ មានទ្រព្យសម្បត្តិច្រើន ដោយផលវត្ថុទានជាវណ្ណទាន ដែលនាងបានប្រគេនសំពត់ចីវរដល់ព្រះអរហន្តពីជាតិមុននោះឯង ។

**គោសាធនោ** ហៃសាធុសប្បុរសផងទាំងឡាយ បុគ្គលឯណានីមួយដែលបានធ្វើវត្ថុទាន កុំថាឡើយដល់សំពត់ធំៗ សូម្បីតែសំពត់បិតបួស ឬបិតដំបៅដែលជាបរិក្ខារតូចតាចនេះ ក៏រាប់បញ្ចូលក្នុងចីវរទានដែរ ដែលជាទានដ៏ប្រសើរបំផុត ។

## កំណើតនៃសំពត់សាដក

សំដែងទុកក្នុង . វិន័យបិដក មហាវគ្គ ពតិយភាគ ចីវរក្ខន្ធកៈ ភាគ ៨ ទំព័រ ១២៥ ។

# រឿងនាងវិសាខា

បានឮមកថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ វេលានោះ នាងវិសាខាមិគារមាតាបានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ កាលនាងវិសាខាអង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងវិសាខា ឱ្យឃើញច្បាស់ ឱ្យកាន់យកតាម ឱ្យអាចហ៊ាន ឱ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ នាងវិសាខា ក៏បានក្រាបបង្គំទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលភត្តរបស់ខ្ញុំព្រះអង្គដើម្បីឆាន់ក្នុងថ្ងៃស្អែកជាមួយនឹងភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លំដាប់នោះ នាងវិសាខាបានដឹងច្បាស់ថា ព្រះអង្គទ្រង់ទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ សម័យនោះឯង លុះរាត្រីនោះកន្លងទៅហើយ-មានភ្លៀងធំធ្លាក់ចុះសព្វទ្វីបទាំង ៤ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ភ្លៀងធ្លាក់ចុះក្នុងវត្តជេតពនយ៉ាងណា ភ្លៀងធ្លាក់ក្នុងទ្វីបទាំង ៤ ក៏យ៉ាងនោះដែរ អ្នកទាំងឡាយចូរងូតជំរះកាយគ្រប់ៗគ្នាទៅចុះ ព្រោះភ្លៀងធំធ្លាកសព្វទ្វីបទាំង ៤ នេះជាទីបំផុតត្រឹមនេះហើយ ។ ភិក្ខុទាំងនោះ ទទួលស្ដាប់ព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះករុណាព្រះអង្គ ហើយនាំគ្នាដាក់ចីវរចេញងូតទឹកភ្លៀងជំរះកាយ ដីងូតទឹកអាក្រាតកាយ ។ គ្រានោះ នាង

វិសាខាបានឱ្យជនតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម ហើយបង្គាប់ឱ្យទាសីថា នែហង ! ហងចូរទៅកាន់អារាម ហើយក្រាបបង្គំទូលភត្តកាល ដ៏ពេលដែលគួរឆាន់ចង្ហាន់ថា បពិត្រព្រះអង្គដ៏ចម្រើន កាលនេះជាកាលគួរហើយ ភត្តក៏សម្រេចហើយ ។ ទាសីនោះក៏ទទួលស្ដាប់ពាក្យនាងវិសាខាដោយពាក្យថា ចាំសអ្នកជាម្ចាស់ ហើយទៅកាន់អារាមក៏បានឃើញពួកភិក្ខុដាក់ចីវរចេញ ដ៏អាក្រាតកាយកំពុងងូតទឹកភ្លៀងជំរះកាយ លុះឃើញហើយគិតថា ក្នុងអារាមនេះគ្មានពួកភិក្ខុទេ មានតែពួកអាជីវករកំពុងងូតទឹកភ្លៀងជំរះកាយ រួចហើយក៏ត្រឡប់ចូលទៅកាន់សំណាក់នាងវិសាខាវិញ ក៏និយាយពាក្យនេះនឹងនាងវិសាខាថា បពិត្រអ្នកម្ចាស់ ! ក្នុងអារាមគ្មានពួកភិក្ខុទេ មានសុទ្ធតែពួកអាជីវករកំពុងងូតទឹកភ្លៀងជំរះកាយ ។ លំដាប់នោះនាងវិសាខាជាបណ្ឌិតជាស្រីឆ្លាត ជាអ្នកប្រាជ្ញ បានរិះគិតយ៉ាងនេះថា ច្បាស់ជាលោកម្ចាស់ទាំងឡាយដាក់ចីវរចេញ ហើយងូតទឹកភ្លៀងជំរះកាយ ឯទាសីជាស្រីល្ងង់សំគាល់ថា ក្នុងអារាមគ្មានភិក្ខុទេ ។ នាងវិសាខាក៏បង្គាប់ឱ្យទាសីទៅម្ដងទៀត ។ កាលនោះ ភិក្ខុទាំងនោះងូតទឹកឱ្យត្រជាក់ខ្លួន មានកាយដ៏ស្រួល ហើយនាំគ្នាយកចីវរទាំងឡាយចូលកាន់លំនៅដូចដែលវិញ ។ ឯទាសីនោះទៅកាន់អារាមមិនឃើញពួកភិក្ខុក៏គិតថា ក្នុងអារាមនេះគ្មានភិក្ខុសោះ មានតែអារាមទទេ ហើយក៏ត្រឡប់ទៅកាន់សំណាក់នាងវិសាខាវិញ បាននិយាយពាក្យនេះនឹងនាងថា បពិត្រអ្នកម្ចាស់ ! ក្នុងអារាមគ្មានភិក្ខុសោះ មានតែអារាមទទេ ។ លំដាប់នោះ នាងវិសាខា ជាបណ្ឌិត ជាស្រីឆ្លាត

ជាអ្នកប្រាជ្ញ បានរិះគិតយ៉ាងនេះថា ច្បាស់ជាលោកម្ចាស់ទាំងឡាយងូតទឹកឱ្យត្រជាក់ខ្លួនមានកាយដ៏ស្រួល ហើយនាំយកចីវរទាំងឡាយចូលទៅកាន់លំនៅដូចដែល ហើយនាងក៏បង្គាប់ឱ្យទាសីទៅម្តងទៀត ។

គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ចូរអ្នករាល់គ្នារៀបចំបាត្រ និងចីវរចុះ ព្រោះដល់ពេលចង្ហាន់ហើយ ភិក្ខុទាំងនោះទទួលស្តាប់ព្រះបន្ទូលរបស់ព្រះដ៏មានព្រះភាគ ដោយពាក្យថាព្រះករុណាព្រះអង្គ លុះវេលាព្រឹកឡើងព្រះទ្រង់ស្បង់ស្បង់ប្រដាប់ដោយបាត្រ និងចីវរ ហើយទ្រង់បំបាត់ព្រះអង្គអំពីវត្តជេតពន ទៅប្រាកដក្លោងទ្វាររបស់នាងវិសាខាដោយឆាប់រហ័ស ប្រៀបដូចបុរសមានកំលាំងលាដៃដែលខ្លួនបត់ចូល ឬ បត់ដៃដែលខ្លួនលាចេញ ។ ព្រះដ៏មានព្រះភាគទ្រង់គង់លើអាសនៈដែលគេតាក់តែងថ្វាយជាមួយនឹងភិក្ខុសង្ឃ គ្រានោះនាងវិសាខាគិតថា អើហ្ន៎ (ហេតុនេះ) អស្ចារ្យពេកណាស់ អើហ្ន៎ (ហេតុនេះ) ចំឡែកពេកណាស់ ព្រះតថាគតមានឫទ្ធិច្រើនមានអានុភាពច្រើន ព្រោះថាជំនន់ប្រមាណត្រឹមជង្គង់ខ្លះ ត្រឹមចង្កេះខ្លះ កំពុងហូរទៅៗ សូម្បីតែជើង ឬចីវររបស់ភិក្ខុមួយអង្គក៏គ្មានទទឹកឡើយ ហើយក៏មានចិត្តរីករាយខ្ពស់ឡើង រួចអង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដោយខាទនីយ និងភោជនីយាហារដ៏ឧត្តមដោយដៃខ្លួនឯង គ្រាតែភិក្ខុសង្ឃហាមឃាត់ លុះកំណត់ដឹងថាព្រះមានព្រះភាគឆាន់ហើយ ដាក់ព្រះហស្តចុះចាកបាត្រហើយ នាងក៏អង្គុយក្នុងទីដ៏សមគួរ ។

នាងវិសាខាអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះនឹងព្រះ

ដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមទូលពរ ៨ ប្រការ អំពីព្រះអង្គ ។

**ពរទាំង ៨ ប្រការ គឺ :**

**១.សូមប្រគេនវស្សិកសាដក** សំពត់សំរាប់ងូតទឹកភ្លៀង

**២.សូមប្រគេនអាគន្តុកភត្ត** ភត្តសំរាប់ភិក្ខុទើបមកដល់ថ្មី

**៣.សូមប្រគេនគមិកភត្ត** ភត្តសំរាប់ភិក្ខុមានដំណើរទៅ

**៤.សូមប្រះគេនគិលានភត្ត** ភត្តសំរាប់ភិក្ខុមានជំងឺ

**៥.សូមប្រគេនគិលានុបដ្ឋាកភត្ត** ភត្តសំរាប់ភិក្ខុអ្នកបំរើភិក្ខុ មានជំងឺ

**៦.សូមប្រគេនគិលានភេសជ្ជៈ** ថ្នាំសំរាប់ភិក្ខុមានជំងឺ

**៧.សូមប្រគេនធុវយាគូ** បបរជានិច្ច

**៨.សូមប្រគេនឧទកសាដក** សំពត់សំរាប់ងូតទឹកដល់ភិក្ខុនីសង្ឃដរាបដល់អស់ជីវិត ។

ព្រះអង្គក៏បានអនុញ្ញាតទូលពរ ៨ ប្រការឱ្យដល់នាងវិសាខា ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់អនុមោទនា ចំពោះនាងវិសាខាដោយគាថាទាំងឡាយនេះថា **យា អន្នបានំ ទទតី បមោទិតា សីលូបបន្នា សុគតស្ស សាវិកា ទទាតិ ទានំ អភិភុយ្យ មច្ឆរំ សោវគ្គិកំ សោកនុទំ សុខាវហំ ទិព្វំ ពលំ សា លភតេ ច អាយុំ អាគម្ម មគ្គំ វិរជំ អនង្គណំសា សា**

បុញ្ញកាមា សុខិនី អនាមយា សគ្គម្ហិ កាយម្ហិ ចិរំ
បមោទតីតិ ។ ស្រីណាជាអ្នកឱ្យបាយនឹងទឹក មានចិត្តរីករាយមានសីល
បរិបូណ៌ ជាសាវិការបស់ព្រះសុគត គ្របសង្កត់នូវសេចក្តីកំណាញ់បាន ហើយ
ឱ្យនូវទាន ស្រីនោះឯងតែងតែបាននូវផល ពីអារម្មណ៍ដ៏ប្រសើរដោយប្រពៃ
មានរូបជាឃើម បានបន្ទោបង់នូវសេចក្តីសោក នាំមកនូវសេចក្តីសុខ
កំឡាំង និងអាយុជាទិព្វ ស្រីនោះជាស្រីមានសេចក្តីប្រាថ្នានូវបុណ្យ មាន
សេចក្តីសុខ ឥតមានទុក តែងរីករាយក្នុងស្ថានសួគ៌អស់កាលជាអង្វែង ព្រោះ
អាស្រ័យនូវមគ្គចិត្តដ៏ប្រាសចាកធុលី មិនមានកិលេសនោះឯង ។

កាលព្រះដ៏មានព្រះភាគទ្រង់អនុមោទនាចំពោះនាងវិសាខា ដោយ
គាថាទាំងនេះហើយ ទ្រង់ក្រោកចាកអាសនៈយាងចៀសចេញទៅ ព្រោះ
និទាននេះ ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់
ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះថា ម្នាលភិក្ខុទាំងឡាយ តថាគត
អនុញ្ញាត វស្សិកសាដកៈ អាគន្តុកភត្ត គមិកភត្ត គិលានភត្ត គិលានុ-
បដ្ឋាកភត្ត គិលានភេសជ្ជៈ ធុវយាគូ និង ឧទកសាដិកៈ ជារបស់
ភិក្ខុនីសង្ឃ ។

យើងខ្ញុំជាកូន ខ្ចៅ យុនសំរ៉ង ខ្ចៅ យ៉ាតណៃ ខ្ចៅសុខផល ខ្ចៅ វិសាល ខ្ចៅ រ៉ាមុន ខ្ចៅ ភារាដា ខ្ចៅ ចំរើន ខ្ចៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook

ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក **ខ្ចៅ ពាញ** និង ឧបាសិកា **ឈរ យឿន**

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

## មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ **គីម វាសនា**

កញ្ញា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្ចៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា

www.elibraryofcambodia.org